រដ្ឋសភា
ចូល
លេខ...៤៣២...
ថ្ងៃទី......ឆ្នាំ២០០៦ ម៉ោង......
បញ្ជូនទៅ......

# ច្បាប់

# ស្តីពី

# ចរាចរណ៍ផ្លូវគោក

6/63

## មាតិកា

# ច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោក

ទំព័រ

**ជំពូកទី ១ : បទប្បញ្ញត្តិទូទៅ**..........................................១
មាត្រា ១ : វិសាលភាព ..........................................១
មាត្រា ២ : គោលបំណង ..........................................១
មាត្រា ៣ : ការគោរពបទប្បញ្ញត្តិច្បាប់ចរាចរណ៍..........................................១
មាត្រា ៤ : ការប្រកាន់ស្តាំ..........................................១
មាត្រា ៥ : ការកំណត់និយមន័យនៃពាក្យដែលប្រើក្នុងច្បាប់ចរាចរណ៍..........................................១
**ជំពូកទី ២ : សញ្ញាចរាចរណ៍** ..........................................៤
មាត្រា ៦ : សញ្ញាចរាចរណ៍ ..........................................៤
មាត្រា ៧ : សញ្ញាបញ្ជារបស់ភ្នាក់ងារចរាចរណ៍..........................................៤
មាត្រា ៨ : លំដាប់អាទិភាព នៃសញ្ញាចរាចរណ៍..........................................៥
**ជំពូកទី ៣ : អ្នកបើកបរយានជំនិះ** ..........................................៥
មាត្រា ៩ : ល័ក្ខខ័ណ្ឌនៃអ្នកបើកបរយានយន្ត..........................................៥
មាត្រា ១០ : ការប្រើប្រាស់ទ្រូងផ្លូវ..........................................៦
មាត្រា ១១ : ការប្រើប្រាស់គន្លងផ្លូវ..........................................៧
មាត្រា ១២ : ការឈប់នៅពេលភ្លើងក្រហម..........................................៧
មាត្រា ១៣ : ការបើកបរត្រង់ផ្លូវរង្វង់មូល ផ្លូវមានខឿន ឬមាន
រូបសំណាកនៅលើទ្រូងផ្លូវ..........................................៨
មាត្រា ១៤ : ការបើកបរទន្ទឹមគ្នា និងបើកបរកាត់ក្បួនដង្ហែផ្សេងៗ..........................................៨
មាត្រា ១៥ : ការសណ្តោងយានជំនិះ ..........................................៨
មាត្រា ១៦ : កន្លែងរថយន្តក្រុងឈប់..........................................៨
មាត្រា ១៧ : ល្បឿនបើកបរសម្រាប់យានជំនិះ..........................................៩
មាត្រា ១៨ : ការបន្ថយល្បឿនយានជំនិះ ..........................................១០
មាត្រា ១៩ : ការរក្សាទុកចន្លោះសុវត្ថិភាព..........................................១១
មាត្រា ២០ : ការជែង..........................................១១
មាត្រា ២១ : ការជៀស..........................................១៣
មាត្រា ២២: ការកំណត់សិទ្ធិអាទិភាពនៅផ្លូវប្រសព្វ..........................................១៥

មាត្រា ២៣ : ការឆ្លងកាត់ផ្លូវរថភ្លើង ........................................១៦

មាត្រា ២៤ : ការឈប់ និងការចតនៅលើផ្លូវថ្នល់ ........................................១៧

មាត្រា ២៥ : ការបើកទ្វារយានជំនិះ........................................១៩

មាត្រា ២៦ : ការប្តូរទិសនៃយានជំនិះ ........................................១៩

មាត្រា ២៧ : ករណីមានថ្មើរជើងឆ្លងកាត់........................................២១

**ជំពូកទី ៤ : ការប្រើភ្លើង និងស្នូរស័ព្ទយានជំនិះ........................................២២**

មាត្រា ២៨ : ការប្រើប្រាស់ភ្លើងសញ្ញាយានជំនិះ........................................២២

មាត្រា ២៩ : ការប្រើប្រាស់ស្នូរស័ព្ទយានជំនិះ........................................២៥

មាត្រា ៣០ : ការប្រើភ្លើងសញ្ញ និងសញ្ញស្នូរស័ព្ទយានពិសេស........................................២៥

មាត្រា ៣១ : ការហាមបំពាក់ភ្លើងបំភ្លឺ ឬភ្លើងលំអរផ្សេងៗ ........................................២៧

**ជំពូកទី ៥ : ថ្មើរជើង និងអ្នកជិះ ឬអ្នកដឹកសត្វ........................................២៧**

មាត្រា ៣២ : ថ្មើរជើង និងអ្នកអូស ឬអ្នករុញរទេះដៃ........................................២៧

មាត្រា ៣៣ : ក្បួនដង្ហែផ្សេងៗ........................................២៨

មាត្រា ៣៤ : អ្នកជិះ ឬដឹកសត្វ........................................២៨

**ជំពូកទី ៦ : ករណីមានគ្រោះថ្នាក់ចរាចរណ៍........................................២៩**

មាត្រា ៣៥ : សមត្ថកិច្ចរបស់នគរបាលចរាចរណ៍........................................២៩

មាត្រា ៣៦ : អ្នកបើកបរ ឬអ្នកប្រើប្រាស់ផ្លូវដែលពាក់ព័ន្ធនឹងគ្រោះថ្នាក់ចរាចរណ៍....២៩

មាត្រា ៣៧ : គ្រោះថ្នាក់ចរាចរណ៍បណ្តាលឱ្យខូចខាតតែសម្ភារៈ........................................៣០

មាត្រា ៣៨ : គ្រោះថ្នាក់ចរាចរណ៍បណ្តាលឱ្យរងរបួស ឬបាត់បង់ជីវិត..............៣០

មាត្រា ៣៩ : គ្រោះថ្នាក់ចរាចរណ៍ដែលភាគីម្ខាងជាភ្នាក់ងារទូត ឬបេសកកម្មទូត....៣០

**ជំពូកទី ៧ : ការគ្រប់គ្រងយាន និងការដឹកជញ្ជូន........................................៣១**

មាត្រា ៤០ : ប្រភេទប័ណ្ណបើកបរយានយន្ត........................................៣១

មាត្រា ៤១ : លក្ខខណ្ឌប័ណ្ណបើកបរ........................................៣២

មាត្រា ៤២ : សុពលភាពនៃប័ណ្ណបើកបរ........................................៣៣

មាត្រា ៤៣ : ពិន្ទុ នៃប័ណ្ណបើកបរ........................................៣៤

មាត្រា ៤៤ : ករណីដែលពាក់ព័ន្ធនឹងប័ណ្ណពិន្ទុ........................................៣៦

មាត្រា ៤៥ : ប័ណ្ណបើកបរសម្រាប់ជនបរទេស........................................៣៧

មាត្រា ៤៦ : ការគ្រប់គ្រងសាលាបង្រៀនបើកបរយានយន្ត........................................៣៨

មាត្រា ៤៧ : ការផ្តល់ផ្លាកលេខ និងប័ណ្ណសម្គាល់យានយន្ត........................................៣៨

មាត្រា ៤៨ : ការត្រួតពិនិត្យលក្ខណបច្ចេកទេសយានយន្ត..............................៣៩
មាត្រា ៤៩ : ការគ្រប់គ្រងយានដ្ឋានជួសជុល និងកែច្នៃតម្លើងយានយន្ត..............៤០
មាត្រា ៥០ : ការធ្វើអាជីវកម្មដឹកជញ្ជូន..................................................៤០
មាត្រា ៥១ : សុពលភាព នៃលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន ..............៤១
មាត្រា ៥២ : សំណុំលិខិតសំរាប់ធ្វើអាជីវកម្មដឹកជញ្ជូន..............................៤១
មាត្រា ៥៣ : ការរៀបចំផ្ទុកទំនិញ និងមនុស្ស.........................................៤១
មាត្រា ៥៤ : ការកំរិតទំងន់ និងទំហំយានដឹកជញ្ជូនទំនិញ..........................៤៣
មាត្រា ៥៥ : ប្រាក់ថ្លៃសេវា និងប្រាក់ពិន័យ..............................................៤៤
**ជំពូកទី ៨ : គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក**................៤៥
មាត្រា ៥៦ : សមាសភាព និងតួនាទីភារកិច្ច នៃ គ.ស.ច.គ..........................៤៥
មាត្រា ៥៧ : ថវិកាដោយឡែក របស់ គ.ស.ច.គ........................................៤៥
**ជំពូកទី ៩ : សមត្ថកិច្ចរបស់មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក**...................៤៥
មាត្រា ៥៨ : មន្ត្រីអនុវត្តច្បាប់ចរាចរណ៍..................................................៤៥
មាត្រា ៥៩ : សិទ្ធិប្តឹងតវ៉ារបស់ជនប្រព្រឹត្តបទល្មើស...................................៤៦
មាត្រា ៦០ : ការឃាត់យានជំនិះដើម្បីត្រួតពិនិត្យ........................................៤៦
មាត្រា ៦១ : ការដកហូតប័ណ្ណបើកបរ....................................................៤៦
មាត្រា ៦២ : ការឃាត់ខ្លួនអ្នកបើកបរ និងយានជំនិះ...................................៤៧
មាត្រា ៦៣ : ការបញ្ជូនសំណុំរឿងគ្រោះថ្នាក់ចរាចរណ៍ទៅតុលាការ..................៤៧
មាត្រា ៦៤ : ការផ្តន្ទាទោសពិន័យអន្តរការណ៍............................................៤៧
មាត្រា ៦៥ : ការទុកជាមោឃៈ ឬហូតប័ណ្ណបើកបរ......................................៤៨
មាត្រា ៦៦ : ករណីឃាត់យានជំនិះ ដើម្បីធ្វើការផាកពិន័យ...........................៤៩
មាត្រា ៦៧ : ករណីឃាត់យានជំនិះ និងរៀបចំសំណុំរឿងបញ្ជូនទៅតុលាការ.........៤៩
មាត្រា ៦៨ : សមត្ថកិច្ចរៀបចំបែបបទកត់ត្រាអង្កេត និងពិន័យបទល្មើសចរាចរណ៍......៥០
**ជំពូក ១០ : ទោសប្បញ្ញត្តិ**..............................................................៥០
មាត្រា ៦៩ : ការទទួលខុសត្រូវទាំងផ្នែកព្រហ្មទណ្ឌ និងរដ្ឋប្បវេណីរបស់អ្នកបើកបរ..៥០
មាត្រា ៧០ : ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី របស់កម្មសិទ្ធិករ ឬអ្នកគ្រប់គ្រង
យានជំនិះ.................................................................................៥០
មាត្រា ៧១ : បទល្មើស និងអំពើល្មើសចរាចរណ៍ ......................................៥១
មាត្រា ៧២ : ករណីមន្ត្រី ឬភ្នាក់ងារនគរបាលចរាចរណ៍ប្រើសិទ្ធិអំណាចរំលោភ......៥១

មាត្រា ៧៣ : ករណីប័ណ្ណបើកបរត្រូវព្យួរទុក ឬទុកជាមោឃៈ........................៥១

មាត្រា ៧៤ : ករណីបើកបរយាន ដែលគ្មានប័ណ្ណបើកបរ ឬប័ណ្ណបើកបរ
ត្រូវព្យួរទុក ឬទុកជាមោឃៈ........................................៥២

មាត្រា ៧៥ : ករណីរារាំងដល់ការឃាត់យានជំនិះ........................................៥២

មាត្រា ៧៦ : ករណីបើកបរយានជំនិះក្នុងពេលស្រវឹង........................................៥២

មាត្រា ៧៧ : ករណីប្រើប្រាស់ឯកសារក្លែងក្លាយ ........................................៥២

មាត្រា ៧៨ : ការប្រើប្រាស់មធ្យោបាយណាមួយជាឧបសគ្គដល់ចរាចរណ៍សាធារណៈ..៥២

មាត្រា ៧៩ : ករណីប្រើប្រាស់យានជំនិះគ្មានប័ណ្ណសម្គាល់យាន និងផ្លាកលេខ........៥៣

មាត្រា ៨០ : ករណីបង្កឱ្យមានរបួសដោយអចេតនាបណ្ដាលឱ្យអសមត្ថភាពការងារ....៥៣

មាត្រា ៨១ : ករណីបង្កឱ្យមានរបួសដោយអចេតនាបណ្ដាលឱ្យពិការអចិន្ត្រៃយ៍........៥៣

មាត្រា ៨២ : ករណីបង្កឱ្យស្លាប់ដោយអចេតនា........................................៥៤

មាត្រា ៨៣ : ករណីបង្កឱ្យមានរបួស ពិការ ឬស្លាប់ដោយចេតនា....................៥៤

មាត្រា ៨៤ : ការផ្ទុកទម្ងន់លើសកម្រិតកំណត់........................................៥៤

មាត្រា ៨៥ : ករណីក្មេងអាយុតិចជាង៦ឆ្នាំដើររហេតរហូតលើផ្លូវថ្នល់....................៥៥

មាត្រា ៨៦ : ករណីលែងសត្វចិញ្ចឹមឱ្យដើររហេតរហូតលើផ្លូវថ្នល់........................៥៥

មាត្រា ៨៧ : ការដាក់ពិន័យរដ្ឋបាលចំពោះមន្ត្រីរាជការ........................................៥៥

មាត្រា ៨៨ : បទលហុ........................................................................៥៦

មាត្រា ៨៩ : ការព្រមាន........................................................................៥៩

មាត្រា ៩០ : ការជៀសផុតពីបណ្ដឹងអាជ្ញា........................................................៥៩

**ជំពូកទី ១១ : អន្តរប្បញ្ញត្តិ** ........................................................៥៩

មាត្រា ៩១ : ការប្ដូរពីផ្លាកលេខរដ្ឋ នគរបាល និងខេមរភូមិន្ទ មកផ្លាកលេខឯកជន..៥៩

មាត្រា ៩២ : ការអនុវត្តនីទោសប្បញ្ញត្តិ ........................................................៥៩

មាត្រា ៩៣ : ការអនុវត្តន៍ចំណុចទី៧ និងចំណុចទី៨ នៃមាត្រា៩........................៥៩

មាត្រា ៩៤ : ការអនុវត្តន៍មាត្រា៤៣ និងមាត្រា៤៤........................................៥៩

**ជំពូកទី ១២ : អវសានប្បញ្ញត្តិ**........................................................៦០

មាត្រា ៩៥ : ការទុកជានិរាករណ៍........................................................៦០

នស/រកម/០២០៧/០០៧

# ព្រះរាជក្រម

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៥ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី២ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

163

# ច្បាប់

# ស្តីពី

# ចរាចរណ៍ផ្លូវគោក

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកនេះ មានវិសាលភាពគ្របដណ្តប់រាល់ការធ្វើចរាចរណ៍លើផ្លូវថ្នល់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ច្បាប់នេះ មានគោលបំណង :

-រក្សាសណ្តាប់ធ្នាប់ សុវត្ថិភាព ក្នុងការធ្វើចរាចរណ៍នៅលើផ្លូវថ្នល់ដែលបើកឱ្យធ្វើចរាចរណ៍ជាសាធារណៈទូទាំងព្រះរាជាណាចក្រកម្ពុជា

-ការពារអាយុជីវិតមនុស្ស សត្វ និងការពារបរិស្ថាន

-ទប់ស្កាត់ការប៉ះពាល់សុខភាពមនុស្ស និងការខូចខាតទ្រព្យសម្បត្តិរដ្ឋ និងឯកជន

-ទប់ស្កាត់ការប្រព្រឹត្តបទល្មើស ដែលបណ្តាលមកពីការប្រើប្រាស់ផ្លូវថ្នល់ ។

**មាត្រា ៣ .-**

អ្នកប្រើប្រាស់ផ្លូវថ្នល់ ត្រូវគោរពឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់នេះ ។

**មាត្រា ៤ .-**

ការបើកបរយានជំនិះគ្រប់ប្រភេទក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវប្រកាន់ស្តាំជានិច្ច ។ គ្រប់យានជំនិះដែលមានចលនានៅលើផ្លូវថ្នល់ ត្រូវតែមានអ្នកបើកបរ ។

**មាត្រា ៥ .-**

ដើម្បីអនុវត្តច្បាប់ចរាចរណ៍នេះ ពាក្យខាងក្រោមត្រូវកំណត់និយមន័យដូចតទៅ :

-ពាក្យថា ផ្លូវថ្នល់ ហៅកាត់ថា ផ្លូវ គឺជាទំហំទាំងមូលនៃទ្រូងផ្លូវរួមជាមួយជាយផ្លូវ ឬ ចិញ្ចើមផ្លូវ

-ពាក្យថា ទ្រូងផ្លូវ គឺជាផ្នែកមួយនៃផ្លូវ ទុកសម្រាប់យានជំនិះគ្រប់ប្រភេទធ្វើចរាចរណ៍

-ពាក្យថា ជាយផ្លូវ គឺជាផ្នែកសងខាងនៃទ្រូងផ្លូវដែលនៅក្រៅទីប្រជុំជនហើយ អាចចតយានជំនិះនៅទីនោះបានក្នុងករណីចាំបាច់

-ពាក្យថា ចិញ្ចើមផ្លូវ គឺជាជាយផ្លូវនៅក្នុងទីប្រជុំជនដែលរៀបចំទុកសម្រាប់ថ្មើរជើងធ្វើដំណើរ ប៉ុន្តែមិនអាចចតយានជំនិះនៅទីនោះបានទេ

-ពាក្យថា គន្លងផ្លូវ គឺជាចំណែកមួយនៃទ្រូងផ្លូវខ័ណ្ឌដោយគំនូសដាច់ៗឬ គំនូសបង្ហួតតាមបណ្តោយទ្រូងផ្លូវដែលមានទទឹងគ្រប់គ្រាន់ អាចឱ្យយានជំនិះគ្រប់ប្រភេទធ្វើចរាចរណ៍បានមួយជួរ

-ពាក្យថា ទីប្រជុំជន គឺជាទីកន្លែងដែលមានអាគារ ឬ គេហដ្ឋានសង់ជិតៗគ្នា ហើយផ្លូវចេញ ឬ ចូលនៅទីនោះ មានដាក់ផ្លាកសញ្ញាឈ្មោះទីប្រជុំជនសម្គាល់ ការចូល ឬ ឈ្មោះទីប្រជុំជនដែលមានគំនូសបន្ទាត់ទ្រូងពណ៌ក្រហមសម្គាល់ការចេញពីទីប្រជុំជនតាមផងផ្លូវ និងមានមនុស្សធ្វើចរាចរណ៍ឆ្លងកាត់ទៅមកច្រើន

-ពាក្យថា ផ្លូវប្រសព្វ គឺជាទីកន្លែងប្រសព្វនៃផ្លូវពីរ ឬ ច្រើនដែលមានផ្ទៃរាបតែមួយ និងមិនកំណត់មុំនៃអ័ក្សរបស់ទ្រូងផ្លូវឡើយ ។ ផ្លូវប្រសព្វអាចមានរាងជា +, X, T, Y ឬ រង្វង់មូលជាដើម

-ពាក្យថា ផ្លូវរង្វង់មូល គឺជាទីកន្លែងប្រសព្វនៃផ្លូវពីរ ឬ ច្រើន ហើយដែលនៅចំកណ្តាលមានខឿនរូបសំណាក ឬវិមានផ្សេងៗ និងមានទ្រូងផ្លូវឯកទិសព័ទ្ធជុំវិញដោយមានសញ្ញាព្រួញប្រាប់ទិសចរាចរណ៍

-ពាក្យថា ផ្លូវសាធារណៈ គឺជាផ្លូវសម្រាប់បើកឱ្យធ្វើចរាចរណ៍ទូទៅជាសាធារណៈ

-ពាក្យថា ផ្លូវឯកជន គឺជាផ្លូវកសាងដោយឯកជន ដែលចែកចេញជាពីរប្រភេទដូចខាងក្រោម :

ក-ផ្លូវឯកជនបើកឱ្យធ្វើចរាចរណ៍ជាសាធារណៈ គឺជាផ្លូវបើកឱ្យធ្វើចរាចរណ៍ទូទៅ ដែលបានសាងសង់ ឬ ជួសជុលដោយឯកជនតាមកិច្ចសន្យាជាមួយរដ្ឋ ។

ខ-ផ្លូវឯកជនមិនបើកឱ្យធ្វើចរាចរណ៍ជាសាធារណៈ គឺជាច្រកផ្លូវសម្រាប់បម្រុងទុកបម្រើការងារក្នុងទីបរិវេណណាមួយ ដូចជាច្រកគេហដ្ឋាន រោងចក្រ សហគ្រាស អគារ ឬ ទីលានបរិវេណផ្សេងៗ ។

-ពាក្យថា ផ្លូវលំ គឺជាផ្លូវដី ដែលតភ្ជាប់ពីផ្លូវជាតិ ឬ ផ្លូវខេត្ត ឆ្ពោះទៅភូមិ ឬ ឃុំនៅជនបទ

-ពាក្យថា ឈប់ គឺជាការនៅស្ងៀមនៃយានជំនិះលើទ្រូងផ្លូវមួយរយៈពេលចាំបាច់ ដែលមានអ្នកបើកបរស្ថិតនៅជាប់នឹងចង្កូត ឬក្បែរយានជំនិះខ្លួន ដើម្បីឱ្យអ្នកដំណើរ ឬយានជំនិះដទៃទៀតឆ្លងកាត់ ឬដើម្បីអែបខាងផាក់ទំនិញ ឬអ្នកដំណើរឡើងចុះ

-ពាក្យថា ចត គឺការទុកឱ្យយានជំនិះនៅស្ងៀមក្នុងរយៈពេលយូរ ឬ ឆាប់ដែលអ្នកបើកបរអាចដើរចោលយានជំនិះរបស់ខ្លួនបាន

-ពាក្យថា អ្នកបើកបរ គឺជាអ្នកបញ្ជាយានជំនិះគិតទាំងអ្នកជិះសត្វ អ្នកដឹកសត្វ និងអ្នកបរសត្វនៅលើផ្លូវ

-ពាក្យថា យានជំនិះ គឺជាយានសម្រាប់ដឹកមនុស្ស ឬទំនិញនៅលើផ្លូវ ឬសម្រាប់សណ្តោង ឬ ត្រូវគេសណ្តោង

-ពាក្យថា យានយន្ត គឺជាយានដែលធ្វើចរាចរណ៍ ដោយម៉ាស៊ីននៅលើផ្លូវដូចជា ទោចក្រយានយន្ត ត្រីចក្រយានយន្ត រថយន្ត ត្រាក់ទ័រ និងយានយន្តឬករណ៍

-ពាក្យថា យានយន្តឬករណ៍ គឺជាយានយន្តពិសេសដែលមានឧបករណ៍គ្រឿងចក្របំពាក់បន្ថែមដោយគ្មានផ្ទុកមនុស្ស ឬ គ្មានផ្ទុកទំនិញនៅក្រៅកាប៊ីន ដូចជារថយន្តលាយស៊ីម៉ង់ត៍ ឬ រថយន្តសម្រាប់បម្រើការងារសាងសង់ផ្លូវ ស្ពាន ជាដើម

-ពាក្យថា អ្នកប្រើប្រាស់ផ្លូវ គឺជាអ្នកបើកបរយាន និងអ្នកថ្មើរជើងដែលធ្វើដំណើរនៅលើផ្លូវ

-ពាក្យថា ទម្ងន់ទទេរបស់យាន គឺជាទម្ងន់របស់យានដែលគ្មានមនុស្ស ឬ គ្មានទំនិញ ប៉ុន្តែមានប្រេងឥន្ធនៈសម្រាប់ផ្តល់ឱ្យយាន មានឧបករណ៍ជួសជុល និងកង់បម្រុង

-ពាក្យថា ទម្ងន់ផ្ទុកអតិបរមារបស់យាន គឺជាផលបូកទម្ងន់ផ្ទុកមនុស្ស និងទម្ងន់ផ្ទុកទំនិញ ដែលកំណត់ដោយរោងចក្រផលិតយាន

-ពាក្យថា ទម្ងន់សរុបអតិបរមារបស់យាន គឺជាផលបូកសរុបទម្ងន់ទទេរបស់យានជាមួយនឹងទម្ងន់ផ្ទុកអតិបរមារបស់យាន ។ បើសិនជាយានមានសណ្តោង ទម្ងន់សរុបអតិបរមារបស់យាន គឺជាផលបូកនៃទម្ងន់សរុបអតិបរមារបស់យាននីមួយៗ

-ពាក្យថា ទម្ងន់សរុបអនុញ្ញាតអតិបរមារបស់យាន គឺជាផលបូកទម្ងន់ទទេរបស់យានជាមួយនឹងទម្ងន់ផ្ទុកមនុស្ស និងទម្ងន់ផ្ទុកទំនិញ ។ បើសិនជាយានមានសណ្តោងទម្ងន់សរុបអនុញ្ញាត អតិបរមារបស់យាន គឺជាផលបូកនៃទម្ងន់សរុបអតិបរមារបស់យាននីមួយៗ

-ពាក្យថា ទម្ងន់សរុបជាក់ស្តែងរបស់យាន គឺជាផលបូកទម្ងន់ទទេរបស់យានជាមួយនឹងទម្ងន់ផ្ទុកមនុស្ស និងទម្ងន់ផ្ទុកទំនិញជាក់ស្តែង

-ពាក្យថា រ៉ឺម៉ក គឺជាយានសម្រាប់ផ្ទុកភ្ជាប់ជាមួយរថយន្ត
-ពាក្យថា សឺមីរ៉ឺម៉ក គឺជាយានសម្រាប់ផ្ទុកភ្ជាប់នឹងក្បាលរថយន្តសណ្តោង ។

# ជំពូកទី ២
# សញ្ញាចរាចរណ៍

**មាត្រា ៦ .-**

សញ្ញាចរាចរណ៍រួមមានផ្លាកសញ្ញាចរាចរណ៍នៅតាមផ្លូវ ភ្លើងសញ្ញាចរាចរណ៍ គំនូសសញ្ញាចរាចរណ៍នៅលើផ្លូវ សញ្ញាបញ្ជារបស់ភ្នាក់ងារចរាចរណ៍ និងសញ្ញាផ្សេងៗទៀត ។

ផ្លាកសញ្ញាចរាចរណ៍ ភ្លើងសញ្ញាចរាចរណ៍ និងគំនូសសញ្ញាចរាចរណ៍នៅលើផ្លូវត្រូវរៀបចំជាប្រព័ន្ធទាក់ទងស៊ីចង្វាក់គ្នាជាហូរហែនៅតាមកន្លែងមានសារៈប្រយោជន៍ដែលធ្វើឱ្យអ្នកប្រើប្រាស់ផ្លូវងាយស្រួលមើលឃើញ ។

សញ្ញាគ្រោះថ្នាក់នៅតាមដងផ្លូវដែលមានលក្ខណៈមិនអចិន្ត្រៃយ៍ ត្រូវដាក់ក្នុងចម្ងាយសមស្របល្មមគ្រប់គ្រាន់តាមប្រភេទផ្លូវ ចំណាត់ថ្នាក់ផ្លូវ និងស្ថានភាពផ្លូវ ដែលអាចធ្វើឱ្យអ្នកបើកបរមានស្មារតីប្រុងប្រយ័ត្នជាមុនបាន ។

ហាមបិទក្រដាស ឬរបស់ផ្សេងៗទៀត ឬគូសវាសនៅលើផ្លាកសញ្ញា ឬប្រើប្រាស់ទម្រផ្លាកសញ្ញា ឬនៅលើសម្ភារៈអ្វីផ្សេងៗទៀត ដែលប្រើប្រាស់សម្រាប់សញ្ញាចរាចរណ៍ដែលជាហេតុធ្វើឱ្យអ្នកបើកបរមិនអាចមើលឃើញសញ្ញាចរាចរណ៍ច្បាស់បានល្អ ឬយល់ខ្លឹមសារសញ្ញាចរាចរណ៍មិនបានត្រឹមត្រូវ ឬធ្វើឱ្យអ្នកបើកបរចាំងភ្នែក ។

រូបភាព និងខ្លឹមសារស្តីពីសញ្ញាចរាចរណ៍ផ្លូវគោក ត្រូវកំណត់នៅក្នុងប្រកាសរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ៧ .-**

សញ្ញាបញ្ជារបស់ភ្នាក់ងារចរាចរណ៍ មានអត្ថន័យដូចខាងក្រោម :

-ដៃស្តាំលើកឡើងលើ បាតដៃលាទៅមុខបែរទៅរកយានជំនិះដែលធ្វើចលនាមករកភ្នាក់ងារចរាចរណ៍ជាសញ្ញាឱ្យប្រុងប្រៀបឈប់ លើកលែងតែអ្នកបើកបរណាដែលមិនអាចឈប់ ដោយសុវត្ថិភាពគ្រប់គ្រាន់ អាចបន្តដំណើរទៅទៀតបាន

-ដៃទាំងពីរ ឬដៃមួយសន្ធឹងតាមបណ្តោយស្មា មានន័យថាបញ្ឈប់ចរាចរណ៍នៃ

យានដែលមានចលនាមកពីមុខភ្នាក់ងារ ឬ មកពីក្រោយខ្នងភ្នាក់ងារ

-ក្នុងកាយវិការដដែលនេះ យានជំនិះទាំងឡាយដែលមកពីខាងឆ្វេង ឬពីខាងស្តាំ ភ្នាក់ងារត្រូវអនុញ្ញាតឱ្យឆ្លងកាត់

-ភ្នាក់ងារចរាចរណ៍កាន់ចង្កៀងភ្លើងក្រហម ឬ ដំបងភ្លើងក្រហម ចង្អុលដាក់យានជំនិះណាមួយ មានន័យថា បញ្ឈប់ចរាចរណ៍យានដែលត្រូវចង្អុលចំនោះ

-ភ្នាក់ងារនគរបាលចរាចរណ៍ អាចប្រើកញ្ចែជំនួយក្នុងការធ្វើសញ្ញាចរាចរណ៍ខាងលើ ។

**មាត្រា ៨ .—**

លំដាប់សិទ្ធិអាទិភាពត្រូវបានកំណត់ដូចតទៅ :

១-ផ្លាកសញ្ញាចរាចរណ៍ មានសិទ្ធិអាទិភាព លើបទប្បញ្ញត្តិចរាចរណ៍ ។

២-ភ្លើងសញ្ញាចរាចរណ៍ មានសិទ្ធិអាទិភាពលើផ្លាកសញ្ញាចរាចរណ៍ ។

៣-សញ្ញាបញ្ជារបស់ភ្នាក់ងារចរាចរណ៍ មានសិទ្ធិអាទិភាពលើភ្លើងសញ្ញាចរាចរណ៍ គំនូសសញ្ញាចរាចរណ៍នៅលើទ្រូងផ្លូវ ផ្លាកសញ្ញាចរាចរណ៍នៅតាមដងផ្លូវ និងបទប្បញ្ញត្តិចរាចរណ៍ទាំងឡាយ ។

## ជំពូកទី ៣
## អ្នកបើកបរយានជំនិះ

**មាត្រា ៩ .—**

គ្រប់អ្នកបើកបរយានយន្តគ្រប់ប្រភេទ ត្រូវអនុវត្តនូវវិធានការដូចខាងក្រោម :

១-អ្នកបើកបរយានយន្តដែលមានទំហំស៊ីឡាំងចាប់ពី ៤៩ សង់ទីម៉ែត្រគូបឡើងទៅ ត្រូវមានប័ណ្ណបើកបរតាមប្រភេទយានយន្ត ។

២-នៅពេលបើកបរយានជំនិះ អ្នកបើកបរត្រូវមានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ច ហើយស្ថិតក្នុងស្ថានភាពដែលអាចធ្វើសកម្មភាពបើកបរបានយ៉ាងស្រួល និងរាប់រហ័សជាពិសេសលទ្ធភាពនៃការធ្វើចលនាមិនត្រូវឱ្យមានការរំខានឡើយ ។ ហាមផ្ទុកអ្នកដំណើរ ទំនិញ ឬ វត្ថុផ្សេងៗ ដែលនាំឱ្យ បាំងភ្នែកអ្នកបើកបរ ។

៣-អ្នកបើកបរ និងអ្នកដំណើរដែលជិះនៅកៅអីខាងមុខនៃរថយន្ត ត្រូវពាក់ខ្សែក្រវ៉ាត់សុវត្ថិភាពជាដាច់ខាត ។

៤-អ្នកបើកបររទេះយន្ត ត្រីចក្រយានយន្ត និងរទេះយន្តសណ្តោងរ៉ឺម៉ក ត្រូវពាក់មួកការពារសុវត្ថិភាព ។

៥-ហាមផ្ទុកមនុស្ស ឬ ទំនិញពីមុខអ្នកបើកបរ ។

៦-ហាមក្មេងអាយុក្រោម ១០ ឆ្នាំ អង្គុយនៅកៅអីខាងមុខនៃរថយន្តដោយគ្មានមនុស្សចាស់អង្គុយជាមួយ ឬនិងគ្មានពាក់ខ្សែក្រវ៉ាត់សុវត្ថិភាព ។

៧-ទារកអាយុតិចជាង ១០ខែ ត្រូវដាក់ក្នុងកៅអីសម្រាប់ទារកដេក និងមានខ្សែក្រវ៉ាត់សុវត្ថិភាព ចងផ្នែកកៅអីនេះឱ្យជាប់ទៅនឹងកៅអីក្រោយនៃរថយន្ត ។

៨-កុមារមានអាយុចាប់ពី ១០ខែ ទៅ ៤ឆ្នាំ ត្រូវអង្គុយក្នុងកៅអីសម្រាប់កុមារដែលមានខ្សែក្រវ៉ាត់សុវត្ថិភាពចងផ្នែកកៅអីនេះ ឱ្យជាប់ទៅនឹងកៅអីក្រោយនៃរថយន្ត ។

៩-ហាមធ្វើឱ្យរំខានដល់អ្នករស់នៅជាប់តាមដងផ្លូវ និងអ្នកប្រើប្រាស់ផ្លូវ ។

១០-ហាមពិសាជាតិស្រវឹងដែលមានអត្រាជាតិអាកុលចាប់ពី ០,២៥ មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី ០,៥ ក្រាមក្នុងមួយលីត្រឈាមឡើងទៅ ។

១១-ហាមបើកបរយានដែលមានកង់ច្រវ៉ាក់ដែកផ្ទាល់លើថ្នល់ផ្លូវ ។ យានជំនិះប្រភេទនេះ ត្រូវដឹកតាមយានដែលមានប្រភេទកង់កៅស៊ូ ។

១២-ហាមប្រើទូរស័ព្ទនៅពេលកំពុងបើកបរយានយន្ត ។ ទូរស័ព្ទអាចប្រើប្រាស់បាន បើមានឧបករណ៍ភ្ជាប់ទំនាក់ទំនង ឬត្រូវឈប់យានយន្តដើម្បីប្រើទូរស័ព្ទ ។

**មាត្រា១០ .-**

នៅលើថ្នល់ផ្លូវដែលមានទិសចរាចរណ៍ពីរ ហើយដែលគ្មានគំនូសសញ្ញាបែងចែកទិសចរាចរណ៍ អ្នកបើកបរត្រូវប្រើប្រាស់ពាក់កណ្តាលថ្នល់ផ្លូវផ្នែកខាងស្តាំ ដោយបើកបរកៀកទៅខាងស្តាំ ។

នៅលើថ្នល់ផ្លូវឯកទិស ដែលគ្មានគំនូសសញ្ញាបែងចែកគន្លងផ្លូវ អ្នកបើកបរត្រូវបើកបរកៀកទៅខាងស្តាំលើកលែងតែត្រូវការបត់ឆ្វេង ។ អ្នកបើកបរអាចប្រើប្រាស់ថ្នល់ផ្លូវខាងឆ្វេង បាននៅពេលដែង ឬឈប់ ។ ដោយឡែកនៅក្នុងទីប្រជុំជនការប្រើប្រាស់ ថ្នល់ផ្លូវត្រូវកំណត់ដោយប្រកាសក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ១១ .-**

នៅលើគន្លងផ្លូវតម្រូវសម្រាប់យានជំនិះប្រភេទណាមួយ អ្នកបើកបរយានជំនិះប្រភេទផ្សេងទៀត មិនត្រូវបើកបរចូលក្នុងគន្លងនេះទេ លើកលែងតែត្រូវចាកចេញ ឬ ចូលទៅក្នុងគន្លងផ្លូវរបស់ខ្លួន ។

នៅលើទ្រូងផ្លូវដែលមានទិសចរាចរណ៍ពីរហើយមានគំនូសបែងចែកទ្រូងផ្លូវ អ្នកបើកបរត្រូវប្រកាន់យកចំណែកផ្លូវខាងស្តាំ ។

នៅលើទ្រូងផ្លូវឯកទិសដែលមានគន្លងផ្លូវពីរ ឬច្រើន អ្នកបើកបរត្រូវប្រកាន់យកគន្លងផ្លូវខាងស្តាំបំផុត ។ ក្នុងករណីមានចរាចរណ៍ចង្អៀតខ្លាំង អ្នកបើកបរអាចបើកបរបានលើគ្រប់គន្លងផ្លូវ ។

នៅលើទ្រូងផ្លូវដែលមានទិសចរាចរណ៍ពីរផ្ទុយគ្នា ហើយនៅលើចំណែកផ្លូវនៃទិសនីមួយៗដែលមានគន្លងផ្លូវពីរ ឬច្រើន អ្នកបើកបរត្រូវប្រកាន់យកគន្លងផ្លូវខាងស្តាំបំផុត ។ ក្នុងករណីមានចរាចរណ៍ចង្អៀតខ្លាំងអ្នកបើកបរអាចបើកបរបានលើគ្រប់គន្លងផ្លូវតាមទិសចរាចរណ៍ ។

ក្នុងករណីមានចរាចរណ៍ចង្អៀតខ្លាំង ដូចមានចែងនៅវាក្យខណ្ឌ ៣ និងវាក្យខណ្ឌ ៤ ខាងលើ យានជំនិះនៅក្នុងគន្លងណាមួយលឿនជាងយានជំនិះនៅក្នុងគន្លងណាមួយទៀតមិនចាត់ទុកជាការជែងឡើយ ។ ចំពោះអ្នកបើកបរយានដែលមានទម្ងន់សរុបលើសពី ៣,៥តោន ត្រូវប្រកាន់យកគន្លងផ្លូវខាងស្តាំជានិច្ច លើកលែងមានការបត់ឆ្វេង ឬនៅពេលជែងអាចប្រើប្រាស់គន្លងផ្លូវផ្សេងទៀតបាន ។ ដោយឡែកនៅក្នុងទីប្រជុំជន ការប្រើប្រាស់ទ្រូងផ្លូវត្រូវកំណត់ដោយប្រកាសក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ១២ .-**

នៅពេលភ្លើងសញ្ញាចរាចរណ៍បញ្ចេញពន្លឺពណ៌លឿងជាសញ្ញាឱ្យប្រុងប្រយ័ត្នត្រៀមឈប់ ឬ ចេញដំណើរទៅមុខ ពណ៌បៃតងជាសញ្ញាអនុញ្ញាតឱ្យយានជំនិះចេញដំណើរ ពណ៌ក្រហមគឺជាសញ្ញាឃាត់ឱ្យឈប់ ។

នៅពេលភ្លើងសញ្ញាចរាចរណ៍បញ្ចេញពន្លឺក្រហមគឺជាសញ្ញាឃាត់ឱ្យឈប់ អ្នកបើកបរត្រូវឈប់នៅមុខខ្សែបន្ទាត់គំនូសជាប់ពណ៌សកាត់ទទឹងទ្រូងផ្លូវ ឬមុខគំនូសសម្រាប់ថ្មើរជើងឆ្លងកាត់ ។ បើគ្មានឧបសគ្គនៅខាងមុខ យានជំនិះខាងស្តាំបំផុតអាចបត់ស្តាំបាននៅត្រង់ចំណុចភ្លើងក្រហមណា ដែលមានសញ្ញាអនុញ្ញាតបត់ស្តាំ ។

**មាត្រា ១៣ .—**

អ្នកបើកបរត្រូវរាងតាមស្តាំដៃ នៅគ្រប់រង្វង់មូល ឬ ខឿនបែងចែកទ្រូងផ្លូវ ដែលជាឧបសគ្គនៃចលនាត្រង់ទៅមុខរបស់យានជំនិះ លើកលែងតែមានកំណត់ផ្ទុយ ។

**មាត្រា ១៤ .—**

អ្នកបើកបរមិនត្រូវបើកបរទន្ទឹមគ្នានៅលើទ្រូងផ្លូវ ឬគន្លងផ្លូវតែមួយបានទេ ។ អ្នកបើកបរមិនត្រូវបើកបរកាត់ក្បួនយោធា ឬក្បួននគរបាល ឬក្បួនដង្ហែជាផ្លូវផ្សេងៗ ។

**មាត្រា ១៥ .—**

បែបបទនៃការសណ្តោងត្រូវអនុវត្តតាមបញ្ញត្តិដូចខាងក្រោម :

-ចំពោះការផ្តក់សណ្តោងយានជំនិះ អ្នកបើកបរត្រូវប្រើខ្សែកាប ឬដងដែក ឬឧបករណ៍សម្រាប់ផ្តក់ដែលធានាជាប់មាំល្អ និងងាយស្រួលក្នុងការបត់បែន

-ហាមអ្នកបើកបរប្រើខ្សែសណ្តោងចំពោះយាន ដែលមានទម្ងន់សរុបលើសពី ៥តោន ឡើងទៅ

-ហាមអ្នកបើកបរ សណ្តោងយានលើសពីមួយគ្រឿង ឬសណ្តោងយាន ដែលមានសណ្តោងរ៉ឺម៉ក ឬ សឺមីរ៉ឺម៉ក

-ហាមសណ្តោងទោចក្រយាន ឬ ទោចក្រយានយន្ត

-ហាមអ្នកបើកបរសណ្តោងរថយន្តគ្រប់ប្រភេទ ដែលមានអ្នកដំណើរនៅក្នុងនោះ ក្រៅពីអ្នកកាន់ចង្កូត

-រថយន្តដែលមានសណ្តោងរ៉ឺម៉ក ឬសឺមីរ៉ឺម៉កត្រូវមានសញ្ញាត្រីកោណសមបាត ដែលមានកញ្ចក់ចាំងពន្លឺពណ៌លឿងពីរ ដាក់នៅកាងរថយន្តខាងមុខអមសងខាងផ្លាកលេខ ។

បច្ចេកទេសនៃការផ្តក់សណ្តោងរ៉ឺម៉ក ឬសឺមីរ៉ឺម៉ក និងការដោះរ៉ឺម៉ក ឬសឺមីរ៉ឺម៉កចេញពីរថយន្ត ឬក្បាលរថយន្ត ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ១៦ .—**

នៅកន្លែងរថយន្តក្រុងឈប់នៅក្នុងទីប្រជុំជន អ្នកបើកបរយានជំនិះប្រភេទផ្សេងពីរថយន្តក្រុង ត្រូវបន្ថយល្បឿន ហើយបើចាំបាច់ត្រូវឈប់ ដើម្បីទុកឱ្យរថយន្តក្រុងចេញ ចូល ឬឈប់បានដោយងាយស្រួល ។

**មាត្រា ១៧ .–**

ល្បឿនបើកបរយានជំនិះត្រូវកំណត់តាមល័ក្ខខ័ណ្ឌ ដូចមានចែងខាងក្រោមនេះ :

១-ល្បឿនបើកបរសម្រាប់យានជំនិះទូទៅ :

ក-នៅក្នុងទីប្រជុំជន :

- អ្នកបើកបរត្រូវប្រើល្បឿនអតិបរមា ៣០ គីឡូម៉ែត្រក្នុងមួយម៉ោង ចំពោះទោចក្រយានយន្ត និងត្រីចក្រយានយន្ត ។

-អ្នកបើកបរត្រូវប្រើល្បឿនអតិបរមា ៤០ គីឡូម៉ែត្រក្នុងមួយម៉ោង ចំពោះរថយន្តគ្រប់ប្រភេទ ។

ខ-នៅក្រៅទីប្រជុំជន :

អ្នកបើកបរត្រូវប្រើល្បឿនអតិបរមា ៩០ គីឡូម៉ែត្រក្នុងមួយម៉ោង ចំពោះយានយន្តគ្រប់ប្រភេទ លើកលែងតែយានដឹកជញ្ជូនទំនិញ ដែលមានទម្ងន់សរុបអតិបរមាលើសពី ៣,៥ តោន ត្រូវកំណត់ល្បឿនអតិបរមាត្រឹម ៧០ គីឡូម៉ែត្រក្នុងមួយម៉ោង និងយានដែលមានសណ្តោងរ៉ឺម៉ក ត្រូវកំណត់ល្បឿនអតិបរមាត្រឹម ៦០ គីឡូម៉ែត្រក្នុងមួយម៉ោង ។

២-ល្បឿនបើកបរសម្រាប់យានជំនិះដឹកវត្ថុធាតុមានគ្រោះថ្នាក់ :

ក-នៅក្នុងទីប្រជុំជន :

-អ្នកបើកបរទោចក្រយានយន្ត និងត្រីចក្រយានយន្ត ត្រូវប្រើល្បឿនអតិបរមា ៣០ គីឡូម៉ែត្រក្នុងមួយម៉ោង ។

-អ្នកបើកបររថយន្ត ត្រូវប្រើល្បឿនអតិបរមា ៤០ គីឡូម៉ែត្រក្នុងមួយម៉ោង ។

ខ-នៅក្រៅទីប្រជុំជន :

អ្នកបើកបរត្រូវប្រើល្បឿនអតិបរមា ៧០ គីឡូម៉ែត្រក្នុងមួយម៉ោង ចំពោះយានយន្ត ដែលមានទម្ងន់សរុបអតិបរមាមិនលើសពី ៣,៥ តោន និងលើសពី ៣,៥ តោន ចំពោះរថយន្តប្រើប្រាស់ប្រព័ន្ធហ្វ្រាំងទប់នឹងភាពគាំងកង់ ។

ល្បឿនអតិបរមាត្រូវកំណត់ត្រឹម៦០ គីឡូម៉ែត្រក្នុងមួយម៉ោង ចំពោះយានដែលមានទម្ងន់សរុបអតិបរមាលើស៣,៥ តោន ដែលគ្មានប្រព័ន្ធហ្វ្រាំងទប់នឹងភាពគាំងកង់ ។

៣-ល្បឿនសម្រាប់យានយន្តបើកបរលើផ្លូវយន្តបថ :

ក-នៅក្នុងតំបន់ប្រជុំជន :

អ្នកបើកបរយានយន្តគ្រប់ប្រភេទ ត្រូវប្រើល្បឿនអតិបរមា ៦០ គីឡូម៉ែត្រក្នុងមួយម៉ោង ។

ខ-នៅក្រៅតំបន់ប្រជុំជន :

អ្នកបើកបរត្រូវប្រើល្បឿនអតិបរមា ១០០ គីឡូម៉ែត្រក្នុងមួយម៉ោង ចំពោះយានយន្តគ្រប់ប្រភេទ លើកលែងតែយានដឹកជញ្ជូនទំនិញ ដែលមានទម្ងន់សរុបអតិបរមាលើសពី ៣,៥ តោន ត្រូវកំណត់ល្បឿនអតិបរមាត្រឹម ៨០ គីឡូម៉ែត្រក្នុងមួយម៉ោង និងយានដែលមានសណ្តោងរ៉ឺម៉ក ត្រូវកំណត់ល្បឿនអតិបរមាត្រឹម ៧០ គីឡូម៉ែត្រក្នុងមួយម៉ោង ។

៤-ល្បឿនបើកបរសម្រាប់យានជំនិះ មានសិទ្ធិអាទិភាព :

បទប្បញ្ញត្តិដែលមានចែងក្នុងចំណុចទី ១ ចំណុចទី ២ និងចំណុចទី ៣ នៃមាត្រានេះមិនអនុវត្តចំពោះអ្នកបើកបរយានយន្តប៉ូលីសនគរបាល ប៉ូលីសយោធា កងអាវុធហត្ថ យានយន្តពន្លត់អគ្គិភ័យ យានយន្តសង្គ្រោះរបស់មន្ទីរពេទ្យ និងយានយន្តខ្លះទៀតដែលបន្លឺសូរស័ព្ទ ភ្លើងសញ្ញា ពិសេសនៅពេលកំពុងបំពេញភារកិច្ចឡើយ ។

អ្នកបើកបរមិនត្រូវប្រើល្បឿនយឺតខុសប្រក្រតី ដោយគ្មានមូលហេតុត្រឹមត្រូវ ដែលធ្វើឱ្យរំខានដល់យានជំនិះដទៃទៀតទេ ។ អ្នកបើកបរដែលប្រើល្បឿនយឺត ត្រូវបើកបរអែបទៅខាងស្តាំ ដើម្បីទុកឱ្យអ្នកបើកបរដែលប្រើល្បឿនលឿនជែងពីខាងឆ្វេងបានដោយងាយស្រួល ។ អ្នកបើកបរណាដែលត្រូវបង្ខំចិត្តបន្ថយល្បឿនឱ្យយឺតខុសប្រក្រតី ត្រូវឱ្យដំណឹងដល់អ្នកបើកបរផ្សេង ទៀតដោយប្រើភ្លើងសញ្ញាអាសន្ន ហើយត្រូវបើកបរអែបទៅខាងស្តាំបំផុតនៃទ្រូងផ្លូវ ។

**មាត្រា ១៨ .-**

ក្នុងគ្រប់ករណីអ្នកបើកបរត្រូវម្ចាស់ការលើល្បឿនបើកបររបស់ខ្លួនជានិច្ច ហើយត្រូវបើកបរក្នុងល្បឿនសមស្របទៅតាមសណ្ឋានភូមិសាស្ត្រ សភាពផ្លូវ ស្ថានភាពអាកាសធាតុ សភាពចរាចរណ៍ ស្ថានភាពយាន និងការផ្ទុករបស់យាន ដើម្បីអាចបញ្ឈប់យានបានទាន់ពេលវេលា និងដោយគ្មានគ្រោះថ្នាក់ ។

អ្នកបើកបរត្រូវបន្ថយល្បឿន ក្នុងករណីដូចខាងក្រោម :

១-នៅពេលជៀសគ្នា នៅលើផ្លូវចង្អៀត ។

២-នៅពេលជៀស ឬជែងរថយន្តដឹកជញ្ជូនអ្នកដំណើរ ឬរថយន្តដឹកជញ្ជូនកុមារដែលកំពុងឈប់ដាក់អ្នកដំណើរ ឬកុមារឡើងចុះ ។



3/63

៣-ពេលទៅជិតដល់ស្ពាន ឬ ជិតដល់ផ្លូវរថភ្លើងឆ្លងកាត់ ។

៤-នៅពេលអាកាសធាតុមិនល្អ ដែលមិនអាចមើលឃើញបានឆ្ងាយ និងច្បាស់ ។

៥-នៅពេលប្តូរទិសចរាចរណ៍ ។

៦-នៅត្រង់ផ្លូវបត់ ផ្លូវកោង ផ្លូវរអិល ផ្លូវប្រសព្វ ឬរង្វង់មូល ។

៧-នៅពេលជិតដល់ទួលខ្ពស់ ឬពេលចុះចំណោត ។

៨-នៅពេលជៀស ឬជែង ក្បួនយានកំពុងឈប់ ឬនៅពេលជៀស ឬជែងក្បួនដង្ហែផ្សេងៗ ។

៩-នៅពេលមានវត្ថុច្រងេងច្រងាង ឬមានផ្ទះសង់ច្រើនកៀកជាប់ខ្លោងផ្លូវ ។

១០-ក្នុងគ្រប់ករណី ដែលមានផ្លាកសញ្ញាឱ្យបន្ថយល្បឿន ឬសញ្ញាគ្រោះថ្នាក់ ។

១១-កាលណាមានយានជំនិះរបស់នគរបាល យោធា ឬអាវុធហត្ថ យានពន្លត់អគ្គិភ័យ យានសង្គ្រោះរបស់មន្ទីរពេទ្យ និងយានយន្តដែលមានបន្ទឺស្ទរស័ព្ទ ឬភ្លើងសញ្ញា អ្នកប្រើប្រាស់ផ្លូវទាំងអស់ត្រូវបន្ថយល្បឿន ហើយបើកអែបមកខាងស្តាំ បើចាំបាច់ត្រូវឈប់នៅកៀនបំផុតដែលអាចធ្វើទៅបាន ដើម្បីសម្រួលផ្លូវឱ្យយានទាំងនេះធ្វើដំណើរទៅមុខ ដោយសុវត្ថិភាព ។

១២-នៅកន្លែងមានសាលារៀនដែលមានទីតាំងស្ថិតនៅក្បែរផ្លូវមិនលើសពី ៥០ ម៉ែត្រ ។

**មាត្រា ១៩ .-**

យានជំនិះមួយដែលធ្វើចរាចរណ៍នៅពីក្រោយយានជំនិះមួយផ្សេងទៀត ត្រូវរក្សាទុកចន្លោះសុវត្ថិភាពគ្រប់គ្រាន់ ដើម្បីជៀសវាងការប៉ះទង្គិចនៅពេលដែលយានជំនិះខាងមុខបន្ថយល្បឿន ឬឈប់ដោយចៃដន្យ ។ ត្រូវរក្សាឱ្យកាន់តែវែងចន្លោះសុវត្ថិភាពនេះ នៅពេលដែលល្បឿនយានកាន់តែលឿន ។ នៅក្រៅទីប្រជុំជន យានជំនិះទាំងឡាយដែលមានទម្ងន់សរុបអតិបរមាលើសពី ៣,៥ តោន ឬមានបណ្តោយយានវែងលើសពី ៧ ម៉ែត្របើកបរបន្តគ្នាក្នុងល្បឿនដូចគ្នា ចម្ងាយចន្លោះពីយានមួយទៅយានមួយ ត្រូវឃ្លាតគ្នាយ៉ាងតិច ៥០ ម៉ែត្រ ។

**មាត្រា ២០ .-**

ក្នុងការជែង អ្នកបើកបរត្រូវអនុវត្តដូចខាងក្រោម :

១-អ្នកបើកបរយានជំនិះគ្រប់ប្រភេទ ត្រូវជែងគ្នានៅខាងឆ្វេង ។ ប៉ុន្តែអ្នកបើកបរអាចជែងខាងស្តាំបាន បើសិនជាអ្នកបើកបរយានដែលត្រូវគេជែងនោះ បាននឹងកំពុងធ្វើសញ្ញាប្តូរទិសខាងឆ្វេង ហើយឈប់ ឬត្រៀមដើម្បីបត់ឆ្វេង ។

២-មុននឹងជែង អ្នកបើកបរត្រូវដឹងច្បាស់ថា ការជែងនេះឥតបណ្ដាលឱ្យមានគ្រោះថ្នាក់អ្វីឡើយ ដោយត្រូវអនុវត្តដូចខាងក្រោម ៖

ក-ឃើញច្បាស់ថា នៅខាងមុខគ្មានឧបសគ្គហើយអាចបរចូលទៅក្នុងចរន្តចរាចរណ៍ប្រក្រតីវិញបាននៅពេលជែងរួច ដោយមិនរំខានដល់ការធ្វើចរាចរណ៍របស់អ្នកដទៃឡើយ ។

ខ-គ្មានអ្នកបើកបរយានជំនិះណាមួយ ដែលនៅពីក្រោយខ្លួនចាប់ផ្ដើមសុំជែងខ្លួន ។

គ-គ្មានឱ្យសញ្ញាសុំជែងយានផ្សេងទៀត ពីអ្នកបើកបរយានជំនិះខាងមុខខ្លួន ។

ឃ-ត្រូវដឹងច្បាស់ថាល្បឿនសមាមាត្ររវាងយានទាំងពីរ អាចឱ្យជែងក្នុងរយៈពេលខ្លីបំផុតបាន ។

ង-ត្រូវធ្វើសញ្ញាសុំជែង ដោយប្រើសញ្ញាប្ដូរទិសខាងឆ្វេង ហើយក្នុងករណីចាំបាច់ ត្រូវប្រើបន្ថែមភ្លើងគូត ហ្វាផ្លាស់គ្នានៅពេលយប់ ឬស៊ីផ្លេនៅពេលថ្ងៃ លើកលែងតែក្នុងទីប្រជុំជន ដែលការប្រើប្រាស់ស៊ីផ្លេសុំជែង ត្រូវហាមឃាត់ ។

ច-ត្រូវដឹងច្បាស់ថា អ្នកបើកបរយានជំនិះខាងក្រោយ និងខាងមុខបានដឹងអំពីការសុំជែងរបស់ខ្លួនហើយ ។

៣-អ្នកបើកបរយានខាងមុខនៅពេលដឹងថាយានខាងក្រោយសុំជែងត្រូវពិនិត្យចំណែកផ្លូវខាងមុខខ្លួន បើគ្មានឧបសគ្គអ្វីទេ ត្រូវឱ្យសញ្ញាប្ដូរទិសខាងស្ដាំ ឬលើកដៃឆ្វេងឡើងលើបត់ទៅស្ដាំ និងបន្ថយល្បឿនអែបទៅខាងស្ដាំ ជាសញ្ញាឱ្យអ្នកបើកបរយានខាងក្រោយដែលសុំជែងដឹងថាអាចជែងបាន ។

ក្នុងករណីអ្នកបើកបរខាងមុខពិនិត្យឃើញថា នៅចំណែកផ្លូវខាងមុខខ្លួនមិនទំនេរ ឬមានឧបសគ្គ ត្រូវធ្វើសញ្ញាប្ដូរទិសខាងឆ្វេង ឬលាតដៃឆ្វេងសន្ធឹងត្រង់ទៅខាងក្រៅ ជាសញ្ញាឱ្យដឹងថា ការជែងពុំទាន់អាចធ្វើទៅបានទេ ។

៤-នៅពេលជែង ត្រូវបង្កើនល្បឿន និងទុកចន្លោះឃ្លាតពីគ្នាយ៉ាងតិច ១ ម៉ែត្រ ។

៥-នៅលើទ្រូងផ្លូវគ្មានគំនូសបង្គត អ្នកបើកបរយានអាចជែង ដោយប្រើប្រាស់ទ្រូងផ្លូវមួយចំហៀងទៀតបាន លុះត្រាតែធ្វើនេះមិនធ្វើឱ្យមានគ្រោះថ្នាក់ ឬរំខានដល់យានដែលបើកបរផ្ទុយនឹងទិសរបស់ខ្លួន ។

៦-នៅពេលជែងផុត អ្នកបើកបរត្រូវធ្វើសញ្ញាប្ដូរទិសខាងស្ដាំវិញ ដើម្បីឱ្យដំណឹង

ថា ខ្លួនត្រូវចូលក្នុងចរន្តចរាចរណ៍របស់ខ្លួនវិញ ។

៧-ក្នុងករណីផ្លូវ មានគន្លងផ្លូវច្រើនតាមទិសចរាចរណ៍តែមួយសម្រាប់ទិសដៅផ្សេងគ្នា យានស្ថិតនៅគន្លងណាមួយបើកបរលឿនជាងយាននៅគន្លងណាមួយទៀតមិនចាត់ទុកជាការជែងឡើយ ។

ហាមជែងគ្នា នៅក្នុងករណីខាងក្រោម :

-ជែងគ្នាជាបីជួរ(ជែងលើរថយន្តដែលកំពុងជែងគ្នា)

-នៅកន្លែងមានសញ្ញាហាមជែង

-នៅត្រង់ផ្លូវកោង ឬផ្លូវឡើងទួល លើកលែងតែការជែងនេះអាចទុកឱ្យផ្នែកផ្លូវខាងឆ្វេង គំនូសបង្គួតកណ្តាលនៅទំនេរបាន

-នៅជិត ឬត្រង់ផ្លូវបត់ ផ្លូវខ្វែង ផ្លូវរង្វិល

-នៅត្រង់កំពូលផ្លូវចោត ផ្លូវតូចចង្អៀត ឬផ្លូវដាក់សញ្ញាបន្ថយល្បឿន

-នៅលើស្ពាន ឬពេលចុះចំណោត

-នៅកន្លែងការដ្ឋាន

-នៅជិត ឬត្រង់កំណាត់ផ្លូវ ដែលទុកសម្រាប់ថ្មើរជើងឆ្លងកាត់

-នៅផ្លូវក្រោមស្ពាន ឬផ្លូវក្នុងរូង

-នៅពេលមើលឃើញមិនច្បាស់ ដូចជាពេលភ្លៀងខ្លាំង ឬចុះអ័ព្ទខ្លាំង ឬដីហុយខ្លាំង

-នៅជិត ឬត្រង់ផ្លូវថ្នល់កាត់ផ្លូវរថភ្លើងដែលគ្មានរបាំង

-នៅលើផ្លូវដែលមានទឹកលិច ។

**មាត្រា ២១ .–**

ក្នុងការជៀស :

១-អ្នកបើកបរយានជំនិះគ្រប់ប្រភេទ ត្រូវជៀសគ្នាដោយប្រកាន់ស្តាំដៃរៀងៗខ្លួន ។

២-នៅមុនពេលជៀសគ្នា អ្នកបើកបរទាំងសងខាង ត្រូវជឿជាក់ថា ការជៀសគ្នានេះមិនបណ្តាលឱ្យមានគ្រោះថ្នាក់អ្វីឡើយ ។

៣-ដើម្បីជៀសគ្នា អ្នកបើកបរត្រូវអែបខាងស្តាំដៃរៀងៗខ្លួន ដោយទុកផ្លូវទំនេរនៅឆ្វេងដៃរបស់ខ្លួនឱ្យបានធំបំផុតដែលអាចធ្វើទៅបាន ។

៤-ពេលជៀសគ្នានៅលើផ្លូវចង្អៀត ឬនៅលើផ្លូវដែលអាចមានគ្រោះថ្នាក់ អ្នក

បើកបរត្រូវបន្ថយល្បឿនរៀងៗខ្លួន ។ ក្នុងករណីចាំបាច់ យានជំនិះទាំងពីរត្រូវឈប់ ហើយបើជាយានជំនិះប្រភេទដូចគ្នា យានជំនិះណាចង់ទៅមុន ត្រូវធ្វើសញ្ញាសុំផ្លូវដោយលើកដៃ ឬដោយស៊ីផ្លេនៅពេលថ្ងៃ ឬប្រើភ្លើងហ្វា ភ្លួតជាសញ្ញានៅពេលយប់ ហើយរង់ចាំយានជំនិះ ដែលមកពីមុខបញ្ចេញសញ្ញាយល់ព្រមឱ្យទៅមុន ទើបធ្វើដំណើរទៅបាន ។ ប៉ុន្តែបើសិនជាយានប្រភេទខុសគ្នា អ្នកបើកបរយានធុនធំត្រូវទុកផ្លូវឱ្យយានដែលមានទំហំតូចជាងយានរបស់ខ្លួនធ្វើដំណើរទៅមុន ។

៥-ពេលជៀសគ្នានៅលើផ្លូវតូចដែលបរបានយានជំនិះតែមួយ ហើយមានកន្លែងមួយ ដែលអាចជៀសគ្នាបាន យានជំនិះណាដែលមកដល់កន្លែងនេះមុន ត្រូវឈប់រង់ចាំនៅកន្លែងនេះ ដើម្បីទុកឱ្យយានជំនិះមួយទៀតជៀសបានស្រួល ។

៦-ក្នុងករណីខ្វេងផ្លូវចង្អៀត មិនអាចជៀសគ្នាបាន ហើយចាំបាច់មានយានណាមួយ ត្រូវថយក្រោយ ត្រូវអនុវត្តដូចខាងក្រោម ៖

ក-ចំពោះយានជំនិះប្រភេទដូចគ្នា យានជំនិះណាចង់ទៅមុន ត្រូវធ្វើសញ្ញាសុំផ្លូវ ហើយត្រូវមានការយល់ព្រមថយក្រោយពីយានមួយទៀត ។

ខ-ចំពោះយានគ្មានសណ្តោង និងយានមានសណ្តោង យានគ្មានសណ្តោងត្រូវថយក្រោយ ។

គ-ចំពោះយានធុនស្រាល និងធុនធ្ងន់ យានធុនស្រាលត្រូវថយក្រោយ ។

ឃ-ចំពោះរថយន្តដឹកទំនិញ និងរថយន្តដឹកអ្នកដំណើរ រថយន្តដឹកទំនិញត្រូវថយក្រោយ ។

៧-ពេលជៀសគ្នានៅលើផ្លូវចោតហើយចង្អៀត យានជំនិះចុះចំណោត ត្រូវឈប់ដើម្បីទុកឱ្យយានជំនិះឡើងចំណោតទៅមុន ។

៨-ក្នុងការជៀសគ្នា យានជំនិះណាមើលឃើញ នៅលើចំណែកផ្លូវរបស់ខ្លួនមានឧបសគ្គ ដូចជាផ្លូវខូច ឬមានយានជំនិះឈប់ស្ងៀមយានជំនិះនោះត្រូវឈប់ ដើម្បីទុកឱ្យយានជំនិះមួយទៀតទៅមុន ។

៩-នៅលើស្ពានចង្អៀត ដែលបើកបរបានតែរថយន្តមួយគ្រឿង រថយន្តធុនធំត្រូវទុកសិទ្ធិឱ្យរថយន្តធុនស្រាលទៅមុន ។

១០-មុនពេលជៀសគ្នា នៅពេលយប់ក្រៅទីប្រជុំជន ហើយគ្មានចង្កៀងអគ្គិសនី យានជំនិះទាំងពីរ ត្រូវបិទភ្លើងហ្វាហើយបើកភ្លើងភ្លូតវិញ ។

## មាត្រា ២២ .-

ការកំណត់សិទ្ធិអាទិភាពនៅផ្លូវប្រសព្វដូចខាងក្រោមនេះ :

១-គ្រប់អ្នកបើកបរនៅពេលទៅជិតដល់ផ្លូវប្រសព្វ ត្រូវបន្ថយល្បឿន និងពិនិត្យមើលចលនាចរាចរណ៍នៅលើទ្រូងផ្លូវ ដែលខ្លួនត្រូវឆ្លងកាត់នោះហើយត្រូវធ្វើដំណើរឆ្លងកាត់ដោយប្រុងប្រយ័ត្នបំផុត បើផ្លូវខាងមុខមិនស្រឡះល្អ ។ ក្នុងករណីចាំបាច់ ត្រូវធ្វើសញ្ញាឱ្យដំណឹងដល់អ្នកបើកបរ ដែលមកពីផ្លូវផ្សេងទៀត ដោយប្រើសញ្ញាស្នូរស័ព្ទពេលថ្ងៃ និងប្រើភ្លើងសញ្ញាកូត ហ្វាឆ្លាស់គ្នា នៅពេលយប់ ។ នៅលើផ្លូវបាត់សិទ្ធិ អ្នកបើកបរត្រូវបើកបរក្នុងល្បឿនមួយដែលអាចបញ្ឈប់យានខ្លួនបាន ដើម្បីផ្តល់សិទ្ធិដល់យានដែលនៅលើផ្លូវមានសិទ្ធិទៅមុន ។

២-ទោះជានៅត្រង់ផ្លូវប្រសព្វ មានភ្លើងសញ្ញាចរាចរណ៍ពណ៌បៃតង ដែលអនុញ្ញាតឱ្យធ្វើចរាចរណ៍ទៅមុខបានក៏ដោយ ក៏អ្នកបើកបរមិនត្រូវបើកចូលទៅក្នុងផ្លូវប្រសព្វឡើយបើសិនជាអំពើនេះអាចតម្រូវឱ្យខ្លួនបញ្ឈប់យានជិះនៅក្នុងផ្លូវប្រសព្វដោយសារតែមានចរាចរណ៍ចង្អៀតខ្លាំង ។ ក្នុងករណីបែបនេះ អ្នកបើកបរត្រូវឈប់នៅមុខផ្លូវប្រសព្វ ដើម្បីកុំឱ្យស្ទះចរាចរណ៍យាន ដែលមកពីទិសផ្សេងទៀត ។

៣-នៅផ្លូវប្រសព្វដែលគ្មានសញ្ញាសិទ្ធិអាទិភាព អ្នកបើកបរត្រូវទុកសិទ្ធិឱ្យអ្នកបើកបរយានដែលមកពីស្តាំរបស់ខ្លួនទៅមុន ។ ប៉ុន្តែក្នុងករណីផ្លូវប្រសព្វបែកជាបីដែលគ្មានសញ្ញាសិទ្ធិអាទិភាព អ្នកបើកបរយាននៅផ្លូវដែលចប់ត្រូវទុកសិទ្ធិឱ្យអ្នកបើកបរយាននៅលើផ្លូវបន្តទៅមុន ។

៤-អ្នកបើកបរដែលទៅដល់រង្វង់មូល ទោះជាខ្លួនស្ថិតនៅលើផ្លូវប្រភេទណាក៏ដោយ ត្រូវផ្តល់សិទ្ធិអាទិភាពឱ្យអ្នកបើកបរដែលស្ថិតនៅក្នុងទ្រូងផ្លូវឯកទិសក្រវាត់រង្វង់មូលដែលមានសញ្ញាបង្ហាញទិសទៅមុន ។

៥-នៅពេលទៅដល់ផ្លូវប្រសព្វដែលមានដាក់សញ្ញាសម្គាល់សិទ្ធិអាទិភាព អ្នកបើកបរ ត្រូវទុកផ្លូវឱ្យយានជិះដែលស្ថិតនៅលើផ្លូវមានសិទ្ធិអាទិភាពធ្វើដំណើរទៅមុនហើយអាចឆ្លងកាត់ផ្លូវប្រសព្វនោះបាន តែនៅពេលណាដែលខ្លួនជឿជាក់ថាពុំមានគ្រោះថ្នាក់អ្វីឡើយ។

៦-នៅពេលទៅដល់ផ្លូវប្រសព្វ ដែលមានដាក់សញ្ញា "ឈប់" អ្នកបើកបរត្រូវឈប់ស្ងៀម នៅមុខគំនូសកាត់ទទឹងទ្រូងផ្លូវ ដើម្បីទុកឱ្យយានជិះ និងថ្មើរជើងដែលនៅលើផ្លូវមានសិទ្ធិធ្វើដំណើរទៅមុន ហើយអាចឆ្លងកាត់ផ្លូវប្រសព្វនេះ តែនៅពេលណាដែលខ្លួនជឿជាក់ថាពុំមានគ្រោះថ្នាក់អ្វីឡើយ ។

៧-ដោយឡែកអ្នកបើកបរត្រូវតែទុកឱ្យយានជំនិះបម្រើការរបស់នគរបាល យោធា អាវុធហត្ថ យានពន្លត់អគ្គិភ័យ ឬយានសង្គ្រោះរបស់មន្ទីរពេទ្យដែលកំពុងបំពេញភារកិច្ច ដោយឱ្យសញ្ញាសូរស័ព្ទ និងសញ្ញាភ្លើងពិសេសឱ្យដឹងពីការមកដល់របស់ខ្លួនទៅមុន ។

៨-យានជំនិះដែលកំពុងបំពេញភារកិច្ចដូចខាងក្រោម មានសិទ្ធិអាទិភាពតាមលំដាប់ដូចតទៅ :

-យានពន្លត់អគ្គិភ័យ

-យានសង្គ្រោះរបស់មន្ទីរពេទ្យ

-យាននគរបាល យោធា អាវុធហត្ថ ឬក្បួនយានដែលមាននគរបាលចរាចរណ៍នាំមុខ។

៩-មុននឹងបើកបរចេញពីផ្លូវឯកជន ដែលមិនបើកឱ្យធ្វើចរាចរណ៍ជាសាធារណៈ ដូចជា ពីច្រកគេហដ្ឋាន រោងចក្រ អគារ ឬទីលានផ្សេងៗ អ្នកបើកបរត្រូវមានការប្រុងប្រយ័ត្នខ្ពស់បំផុត និងត្រូវទុកសិទ្ធិអាទិភាពឱ្យយានជំនិះ ឬអ្នកថ្មើរជើង ដែលកំពុងធ្វើចរាចរណ៍លើផ្លូវបើកឱ្យធ្វើចរាចរណ៍ជាសាធារណៈទៅមុន ។

១០-អ្នកបើកបរចេញមកពីផ្លូវលំ ឬផ្លូវដី ត្រូវទុកសិទ្ធិឱ្យអ្នកបើកបរលើផ្លូវផ្សេងទៀត ដែលមិនមែនជាផ្លូវលំ ឬផ្លូវដីទៅមុន ។

១១-នៅត្រង់ផ្លូវប្រសព្វ បើខ្នងផ្លូវមួយ មានចែកជាច្រើនគន្លងផ្លូវ ហើយមានគន្លងផ្លូវមួយ ឬច្រើនត្រូវបម្រុងសម្រាប់យានជំនិះប្រភេទខ្លះធ្វើចរាចរណ៍ បទប្បញ្ញត្តិស្តីពីអាទិភាពចរាចរណ៍ដែលមានចែងក្នុងមាត្រានេះ ត្រូវអនុវត្តចំពោះអ្នកបើកបរដែលធ្វើចរាចរណ៍នៅលើគន្លងផ្លូវ ប្រភេទនេះ លើកលែងតែយានជំនិះដែលមានចែងក្នុងចំណុចទី ៧ និងចំណុចទី ៨ ។

**មាត្រា ២៣ .-**

ក្នុងការឆ្លងកាត់ផ្លូវរថភ្លើង :

១-អ្នកបើកបរត្រូវមានការប្រុងប្រយ័ត្នខ្ពស់ និងត្រូវបន្ថយល្បឿននៅពេលជិតដល់ផ្លូវរថភ្លើង ។

២-អ្នកបើកបរ មិនត្រូវបរយានជំនិះរបស់ខ្លួនកាត់ផ្លូវរថភ្លើងឡើយ បើដឹងថាយានជំនិះរបស់ខ្លួនមានបញ្ហាបច្ចេកទេស ឬស្ថានភាពចរាចរណ៍មិនអនុគ្រោះ អាចប្រថុយទៅនាំឱ្យស្ទះនៅកន្លែងនោះ ។



3/63

៣-នៅកន្លែងផ្លូវថ្នល់កាត់ផ្លូវរថភ្លើង មានដាក់របារ ឬរបាំង អ្នកបើកបរមិនត្រូវបរចូលទៅទីនោះ នៅពេលដែលរបាំងនោះបិទ ឬកំពុងបិទ ឬកំពុងបើកឡើយ ។

៤-នៅកន្លែងផ្លូវថ្នល់កាត់ផ្លូវរថភ្លើងពុំមានរបារ ឬរបាំង ឬផ្លាកសញ្ញា ឬភ្លើងសញ្ញាអ្វីទាំងអស់ អ្នកបើកបរអាចបើកបរកាត់ទីនោះបាន លុះត្រាជឿជាក់ថាពុំមានរថភ្លើងណាមួយមកដល់ឡើយ ។

៥-នៅកន្លែងមានឆ្មាំ នៅត្រង់ផ្លូវរថភ្លើងឆ្លងកាត់ អ្នកបើកបរត្រូវស្តាប់បញ្ជាឆ្មាំ ហើយមិនត្រូវបង្កឱ្យមានឧបសគ្គដល់ការបិទបើករបារ ឬរបាំងឡើយ ។

៦-កាលណាមានរថភ្លើងមកជិតដល់ អ្នកប្រើប្រាស់ផ្លូវគ្រប់រូប ត្រូវឈប់ជាបន្ទាន់ដើម្បីទុកផ្លូវឱ្យរថភ្លើងធ្វើចរាចរណ៍ទៅមុន ។ គង្វាលសត្វទាំងអស់ ត្រូវរកវិធីទប់ស្កាត់ហ្វូងសត្វពាហនៈកុំឱ្យឆ្លងកាត់ផ្លូវរថភ្លើងជាដាច់ខាត ។

៧-កាលណារថភ្លើងបន្លឺសញ្ញាជិតមកដល់ អ្នកបើកបរគ្រប់រូប ត្រូវឈប់យ៉ាងតិច ២ ម៉ែត្រ ពីរបាំង ហើយបើគ្មានរបាំង មិនត្រូវឈប់តិចជាង ៥ ម៉ែត្រ ពីផ្លូវរថភ្លើងឡើយ ។

៨-ក្នុងករណី ដែលយានជំនិះគាំងដំណើរ ឬហ្វូងសត្វធ្វើដំណើរចូលមកជ្រុលទៅលើផ្លូវរថភ្លើង អ្នកបើកបរ ឬគង្វាលសត្វ ត្រូវរិះរកមធ្យោបាយយ៉ាងណាកុំឱ្យមានកើតជាឧបសគ្គដល់រថភ្លើង ឬត្រូវឱ្យដំណឹងដល់ភ្នាក់ងារទទួលខុសត្រូវផ្លូវរថភ្លើងដែលនៅជិតបំផុតនូវគ្រោះថ្នាក់ ដែលនឹងអាចកើតឡើងបាននោះ បើសិនជាខ្លួនមិនអាចបញ្ចៀសឧបសគ្គលើផ្លូវរថភ្លើងដោយខ្លួនឯងបាន ។

**មាត្រា ២៤ .-**

ក្នុងការឈប់ និងការចត នៅលើផ្លូវថ្នល់ :

១-គ្រប់យានជំនិះ ដែលឈប់ ឬចត មិនត្រូវបង្កឱ្យរំខានដល់យានជំនិះផ្សេងៗទៀត ដែលកំពុងធ្វើចរាចរណ៍ ។

២-នៅក្នុងទីប្រជុំជន គ្រប់យានជំនិះ ត្រូវឈប់ ឬចតនៅតាមទិសដែលខ្លួនកំពុងធ្វើចរាចរណ៍ ដោយអនុវត្តតាមបទប្បញ្ញត្តិដូចខាងក្រោម :

-ចំពោះទ្រូងផ្លូវដែលមានទិសចរាចរណ៍ពីរត្រូវចត ឬឈប់ខាងស្តាំតាមទិសចរាចរណ៍របស់ខ្លួន

-ចំពោះទ្រូងផ្លូវឯកទិស ត្រូវចតឬឈប់ខាងស្តាំ ឬខាងឆ្វេងតាមទិសចរា-ចរណ៍លើកលែងតែមានផ្លាកសញ្ញាផ្ទុយ ។

៣-នៅក្រៅទីប្រជុំជន យានជំនិះត្រូវចត ឬឈប់សត្វពាហនៈត្រូវឈប់ក្រៅថ្នល់ផ្លូវ បើអាចធ្វើទៅបាន ។ បើគ្មានទីណាផ្សេងទៀត ដែលអាចចតបានក្រៅពីថ្នល់ផ្លូវទេនោះ ត្រូវអនុវត្តតាមបទប្បញ្ញត្តិ ដែលមានចែងក្នុងចំណុចទី ២ នៃមាត្រានេះ ។

៤-នៅពេលយប់ ឬនៅកន្លែងហាមឈប់ ឬចត គ្រប់រថយន្ត និងរ៉ឺម៉កដែលខូចគាំង ឬត្រូវបង្ខំឱ្យឈប់ ឬចតនៅលើថ្នល់ផ្លូវ ត្រូវដាក់សញ្ញាជាដំណឹងក្នុងចម្ងាយគ្រប់គ្រាន់ដល់អ្នកប្រើប្រាស់ផ្លូវផ្សេងទៀត ។

៥-នៅក្នុងទីប្រជុំជន គ្រប់យានជំនិះ ត្រូវឈប់ ឬចតដាក់ទំនិញ ឬមនុស្សឡើងចុះនៅចម្ងាយមិនលើស ២៥ សង់ទីម៉ែត្រពីគែមចិញ្ចើមផ្លូវ និងយ៉ាងតិច៥ម៉ែត្រពីផ្លូវប្រសព្វ ឬផ្លូវបត់ ឬផ្លូវកោង និងចន្លោះយ៉ាងតិច ១០ ម៉ែត្រពីផ្លូវប្រសព្វ ឬផ្លូវបត់ឬផ្លូវកោងនៃមហាវិថី ។ នៅក្រៅទីប្រជុំជន យានទាំងអស់ត្រូវឈប់ ឬចតយ៉ាងតិចបំផុត ១០ ម៉ែត្រពីផ្លូវប្រសព្វ ឬផ្លូវបត់ ឬផ្លូវកោង ។

៦-ក្នុងការចត មុនពេលដើរឆ្ងាយពីយានជំនិះរបស់ខ្លួន អ្នកបើកបរត្រូវចាប់ហ្វ្រាំងដៃ ឬមានវិធានការផ្សេងៗ ដើម្បីការពារគ្រោះថ្នាក់ជាយថាហេតុ នៅពេលដែលខ្លួនអវត្តមាន ។

៧-ការចត ឬឈប់យានជំនិះ ត្រូវហាមឃាត់ ក្នុងករណីដូចខាងក្រោម :

-នៅលើថ្នល់ផ្លូវ ចិញ្ចើមផ្លូវ ដែលទុកបម្រុងឱ្យថ្មើរជើង និងក្នុងចន្លោះយ៉ាងតិច ៥ ម៉ែត្រពីមុខគំនូសឆ្នូតកាត់ទទឹងថ្នល់ផ្លូវសម្រាប់អ្នកថ្មើរជើង ឬនៅលើគំនូសនេះ

-លើកន្លែងបម្រុងទុកសម្រាប់ការឈប់ ឬចត នៃយានប្រភេទខ្លះ

-នៅចន្លោះគែមថ្នល់ផ្លូវ និងខ្សែបន្ទាត់បង្អួត បើសិនជានៅចន្លោះខ្សែគំនូសបង្អួត និងយានចតនេះតិចជាង ៣ ម៉ែត្រ ដែលមិនអាចឱ្យយានមួយផ្សេងទៀតបរបានដោយឥតឆ្លងកាត់ ឬ ជាន់លើខ្សែគំនូសបង្អួត

- នៅជិតបង្គោលភ្លើងសញ្ញាចរាចរណ៍ ឬផ្លាកសញ្ញាចរាចរណ៍ ដែលធ្វើឱ្យបាំងភ្នែក អ្នកប្រើប្រាស់ផ្លូវ មិនអាចមើលឃើញសញ្ញាចរាចរណ៍ទាំងនេះបានទេ

- នៅគ្រប់ទីកន្លែងដែលយាននេះ ធ្វើឱ្យរាំងស្ទះដល់ច្រកចូលចត ឬការឈប់នៃយានដទៃទៀត

-នៅលើស្ពាន លើផ្លូវក្រោមស្ពាន លើផ្លូវក្នុងរូង លើផ្លូវចោតខ្លាំង លើផ្លូវប្រសព្វ លើផ្លូវកាត់រថភ្លើង លើផ្លូវក្នុងរង្វង់មូល ឬផ្លូវកោងខ្លាំង ដែលមិនអាចមើលយានផ្សេងទៀតពីចម្ងាយបាន

-នៅចន្លោះតិចជាង ២០ ម៉ែត្រពីមុខផ្លូវរថភ្លើងឆ្លងកាត់

-នៅចន្លោះតិចជាង ១០ ម៉ែត្រពីមុខ និងពីក្រោយទីតាំងបូមទឹករបស់យានពន្លត់អគ្គិភ័យ និងនៅមុខស្ថានីយ៍អ្នកពន្លត់អគ្គិភ័យ

- លើច្រកចេញចូលនៃអគារសាធារណៈ

- នៅមុខច្រកចេញ ចូលផ្ទះឯកជន លើកលែងតែយានរបស់ម្ចាស់ផ្ទះ

-ជាពីរជួរទន្ទឹមគ្នា

-នៅលើគែមថ្នល់ផ្លូវម្ខាង បើនៅគែមម្ខាងទៀត ដែលឈមមុខគ្នាជាកន្លែងទុក សម្រាប់ឱ្យយានជំនិះចត លើកលែងតែក្នុងករណីដែលអាចចតបានទាំងសងខាង

- នៅកន្លែងដែលមានសញ្ញាហាមឈប់ ឬហាមចត

- នៅលើថ្នល់ផ្លូវថ្មល់លើសពី ៧២ ម៉ោង

-នៅចន្លោះតិចជាង ១០ ម៉ែត្រពីមុខ និងពីក្រោយផ្លាកសញ្ញាកន្លែងរបស់រថយន្តក្រុងឈប់

-នៅចន្លោះតិចជាង ១ ម៉ែត្រពីមុខ ឬពីក្រោយរថយន្តដែលឈប់ ឬចតបន្តកន្ទុយគ្នា

-នៅជិតផ្លូវប្រសព្វ ឬផ្លូវបត់ ។

**មាត្រា ២៥ .-**

ការបើកទ្វារយានជំនិះដើម្បីចុះ ឬឡើង ធ្វើបានតែពេលណាដែលមិនបង្កឱ្យមានគ្រោះថ្នាក់ដល់អ្នកដទៃដែលកំពុងប្រើប្រាស់ផ្លូវនោះឡើយ និងត្រូវមានការប្រុងប្រយ័ត្នជាប់ជានិច្ច ជាពិសេសចំពោះការបើកទ្វារចុះ ឬឡើងនៅទ្វារខាងឆ្វេងយាន ។

**មាត្រា ២៦ .-**

មុននឹងផ្លាស់ប្តូរទិសដៅនៃយានរបស់ខ្លួន ដូចជាក្នុងការបត់ឆ្វេង ឬបត់ស្តាំពេលប្តូរគន្លងផ្លូវ ពេលអែបខាងដើម្បីឈប់ ឬចត អ្នកបើកបរត្រូវបន្ថយល្បឿន និងត្រូវជឿជាក់ជាមុនថាមិនបណ្តាលឱ្យមានគ្រោះថ្នាក់ ហើយត្រូវឱ្យសញ្ញាយ៉ាងច្បាស់ និងគ្រប់គ្រាន់ជាដំណឹងដល់អ្នកដទៃ ដែលកំពុងប្រើប្រាស់ផ្លូវនោះដែរ ។

មុនពេលចេញដំណើរពីចំណត អ្នកបើកបរត្រូវឱ្យសញ្ញាយ៉ាងច្បាស់ និងគ្រប់គ្រាន់ជាដំណឹងដល់អ្នកដទៃដែលកំពុងប្រើប្រាស់ផ្លូវនោះ ដោយត្រូវជឿជាក់ថា ការចេញដំណើររបស់យានយន្តគ្មានបណ្តាលឱ្យមានគ្រោះថ្នាក់ដល់អ្នកដទៃឡើយ ។

លើកលែងតែមានបញ្ជារបស់នគរបាលចរាចរណ៍ ឬគំនូសសញ្ញាចរាចរណ៍នៅលើផ្ទៃផ្លូវក្នុងការបត់ឆ្វេង បត់ស្តាំ បត់ត្រឡប់ក្រោយ ឬថយក្រោយ អ្នកបើកបរត្រូវគោរពតាមការណែនាំដូចខាងក្រោម៖

១-ការបត់ឆ្វេង៖

-មុននឹងធ្វើការបត់ឆ្វេង ត្រូវក្រឡេកមើលក្រោយតាមកញ្ចក់មើលក្រោយ ពិសេសតាមកញ្ចក់ខាងឆ្វេង ដើម្បីឱ្យដឹងទីតាំង និងចលនាចរាចរណ៍នៅពីខាងក្រោយ

-ត្រូវធ្វើសញ្ញាប្តូរទិសទៅខាងឆ្វេងឱ្យបានចម្ងាយគ្រប់គ្រាន់ ពីកន្លែងដែលត្រូវបត់ និងបន្ថយល្បឿន ហើយបើគ្មានឧបសគ្គអ្វីទេ ត្រូវបើកអែបគំនូសបង្គួកកណ្តាលផ្ទៃផ្លូវ

-នៅពេលរៀបនឹងបត់ឆ្វេង ត្រូវមើលឆ្វេង ស្តាំ និងមើលឆ្វេងម្តងទៀត ពិសេសមើលចរាចរណ៍យានមកពីទិសផ្ទុយ ។ បើផ្លូវទំនេរត្រូវបត់ដោយប្រុងប្រយ័ត្ន ពិសេសចំពោះថ្មើរជើងដែលកំពុងឆ្លងកាត់ ។ បើផ្លូវមិនទំនេរត្រូវរង់ចាំដោយទុកឱ្យអ្នកបើកបរយានដែលមកពីទិសផ្ទុយ និងមកពីទិសខាងស្តាំទៅមុន ។

-ការបត់ឆ្វេងត្រូវធ្វើតាមបែបសៀវស្តាំគឺបត់ពីក្រោយចរាចរណ៍យានមកពីទិសផ្ទុយ លើកលែងតែមានការណែនាំពីនគរបាលចរាចរណ៍ ។

២-ការបត់ស្តាំ ៖

-មុននឹងធ្វើការបត់ស្តាំ ត្រូវក្រឡេកមើលតាមកញ្ចក់មើលក្រោយ ពិសេសតាមកញ្ចក់ខាងស្តាំ ដើម្បីទីតាំងនិងចលនាចរាចរណ៍យាននៅពីខាងក្រោយ

-បើគ្មានឧបសគ្គអ្វីទេ ត្រូវធ្វើសញ្ញាប្តូរទិសខាងស្តាំឱ្យបានចម្ងាយគ្រប់គ្រាន់ពីទីកន្លែង ដែលត្រូវបត់ និងបន្ថយល្បឿន ហើយបើកអែបមកស្តាំ

-នៅពេលរៀបនឹងបត់ស្តាំ ត្រូវមើលឆ្វេង ស្តាំ ហើយត្រូវមើលក្រោយតាមកញ្ចក់ខាងស្តាំម្តងទៀត ជាពិសេសត្រូវជឿជាក់ថាគ្មានឧបសគ្គនៅខាងស្តាំផ្នែកខាងក្រោយឡើយ ។ បើទំនេរ ត្រូវបើកឱ្យកៀកស្តាំបំផុតដែលអាចធ្វើទៅបាន និងត្រូវប្រុងប្រយ័ត្នចំពោះថ្មើរជើងដែលកំពុងឆ្លងកាត់ ។

៣-ការបត់ត្រឡប់ក្រោយ និងថយក្រោយ៖

-អ្នកបើកបរដែលមានបំណងបត់ត្រឡប់ក្រោយ ឬថយក្រោយ ត្រូវជឿជាក់ថាទង្វើនេះមិនធ្វើឱ្យរំខានខ្លាំង ឬបណ្តាលឱ្យមានគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ផ្លូវផ្សេងទៀតឡើយ

-ចំពោះការបើកបរថយក្រោយ អ្នកបើកបរត្រូវប្រុងប្រយ័ត្ន និងក្រឡេកមើលចលនាចរាចរណ៍ខាងក្រោយយានគ្រប់វិនាទី ពិសេសមុននឹងថយក្រោយ ត្រូវប្រុងប្រយ័ត្នមើលឱ្យបានសព្វជ្រុងជ្រោយ ចំពោះក្មេងតូចឬសត្វតូចៗនៅខាងក្រោយ

-ហាមបត់ត្រឡប់ក្រោយ នៅក្នុងករណីដូចខាងក្រោម :

-នៅជិតផ្លូវប្រសព្វ ឬជិតផ្លូវកាត់រថភ្លើង

-នៅត្រង់ផ្លូវកោងដែលអ្នកបើកបរមិនអាចមើលឃើញយានផ្សេងៗទៀតបានក្នុងចម្ងាយ ១៥០ម៉ែត្រ

-នៅជិតដល់កំពូលខ្ពស់ និងចុះពីកំពូលខ្ពស់

-នៅកន្លែងដែលមានសញ្ញាហាមបត់ត្រឡប់ក្រោយ

-នៅលើខ្លូងផ្លូវឯកទិស ។

**មាត្រា ២៧ .-**

នៅពេលមានថ្មើរជើងឆ្លងកាត់ អ្នកបើកបរត្រូវអនុវត្តដូចខាងក្រោម :

១-គ្រប់ករណីទាំងអស់ អ្នកបើកបរត្រូវតែឈប់នៅពេលថ្មើរជើងកំពុងឆ្លងកាត់ ឬរៀបនឹងឆ្លងកាត់នៅកន្លែងដែលមានគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់ ។

២-នៅត្រង់កន្លែងផ្លូវប្រសព្វ ឬនៅជិតកៀកផ្លូវប្រសព្វ អ្នកបើកបរត្រូវហាមឃាត់ក្នុងការធ្វើឱ្យអាក់ខាន ឬរាំងស្ទះដល់ថ្មើរជើង ដែលកំពុងឆ្លងកាត់ខ្លូងផ្លូវ ទោះជាគ្មានគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់ក៏ដោយ ។

៣-ក្នុងករណីមានគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់នៅត្រង់ផ្លូវប្រសព្វដែលមានភ្លើងសញ្ញាចរាចរណ៍ ឬមានភ្នាក់ងារបញ្ជាចរាចរណ៍នៅទីនោះ ទោះជាមានភ្លើងពណ៌បៃតង ឬមានបញ្ជាភ្នាក់ងារឱ្យទៅមុខក៏ដោយ អ្នកបើកបរមិនត្រូវធ្វើឱ្យរំខាន ឬធ្វើឱ្យស្ទះដល់ថ្មើរជើងដែលកំពុងឆ្លងកាត់នៅលើគំនូសសញ្ញាថ្មើរជើងឆ្លងកាត់ឡើយ ។ ចំពោះអ្នកបើកបរដែលបត់ចូលខ្លូងផ្លូវផ្សេងទៀត ហើយនៅខ្លូងផ្លូវនោះមានថ្មើរជើងកំពុងឆ្លងកាត់ អ្នកបើកបរត្រូវបន្ថយល្បឿនបើចាំបាច់ត្រូវឈប់ ដើម្បីផ្តល់សិទ្ធិឱ្យថ្មើរជើងឆ្លងកាត់រួចរាល់សិន ។

៤-ក្នុងករណីមានគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់នៅត្រង់ផ្លូវប្រសព្វដែលគ្មានភ្លើងសញ្ញាចរាចរណ៍ ឬគ្មានភ្នាក់ងារបញ្ជាចរាចរណ៍នៅទីនោះ អ្នកបើកបរត្រូវបន្ថយល្បឿន ឬ បើចាំបាច់ត្រូវឈប់ ដើម្បីផ្តល់សិទ្ធិឱ្យថ្មើរជើងដែលកំពុងឆ្លងកាត់ ឬរៀបនឹងឆ្លងកាត់ទៅមុន ។

# ជំពូកទី ៤
# ការប្រើភ្លើង និង សូរសំឡេងយានជំនិះ

**មាត្រា ២៨.-**

នៅពេលយប់ ឬពេលថ្ងៃ កាលណាមើលមិនឃើញច្បាស់គ្រប់គ្រាន់ដូចជានៅពេលភ្លៀងខ្លាំង ចុះអ័ព្ទ ឬឆ្លងកាត់ផ្លូវក្នុងរូង អ្នកបើកបរយាននៅលើទ្រូងផ្លូវ ត្រូវប្រើប្រាស់ភ្លើងសញ្ញាតាមល័ក្ខខ័ណ្ឌដូចខាងក្រោម :

១-ក្នុងករណីកំពុងបើកបរយានយន្ត :

ក-ភ្លើងហ្វា : នៅពេលយប់ នៅលើទ្រូងផ្លូវដែលគ្មានអគ្គិសនីបំភ្លឺ ជាទូទៅត្រូវប្រើភ្លើងហ្វា ដើម្បីមើលទៅមុខឱ្យបានឆ្ងាយ តែត្រូវប្រុងប្រយ័ត្នកុំឱ្យរំខានដល់ចរាចរណ៍ដែលមកពីទិសផ្ទុយ ។

ហាមបើកភ្លើងហ្វានៅក្នុងទីក្រុង ឬទីប្រជុំជនដែលមានភ្លើងអគ្គិសនីបំភ្លឺគ្រប់គ្រាន់ លើកលែងតែករណីធ្វើសញ្ញាសុំជែង ឬសុំបើកផ្លូវដោយប្រើឆ្លាស់គ្នាជាមួយភ្លើងកូត ។

ខ-ភ្លើងកូត : ត្រូវប្រើភ្លើងកូត ក្នុងករណីដូចខាងក្រោម :

-នៅពេលយប់ នៅក្នុងទីប្រជុំជន និងក្រៅទីប្រជុំជន ដែលមានភ្លើងអគ្គិសនីបំភ្លឺតាមផ្លូវ

-នៅពេលយប់ នៅក្រៅទីប្រជុំជនដែលគ្មានចង្កៀងអគ្គិសនីបំភ្លឺតាមផ្លូវ ក្នុងករណីរៀបនឹងជៀសយានមួយផ្សេងទៀត និងនៅពេលបើកបរពីក្រោយជិតយានជំនិះមួយទៀត

-នៅពេលថ្ងៃ កាលណាមើលមិនសូវច្បាស់ ដោយអាកាសធាតុមិនល្អដូចជានៅពេលភ្លៀងខ្លាំង ឬចុះអ័ព្ទ

-ភ្លើងកូតអាចប្រើប្រាស់ឆ្លាស់គ្នានឹងភ្លើងហ្វាធ្វើឱ្យមានពន្លឺភ្លឺបភ្លែតៗជាសញ្ញាជំនួសស៊ីផ្លេនៅពេលថ្ងៃ ។

គ-ភ្លើងទីតាំង : នៅពេលយប់ ក្នុងទីប្រជុំជន យានជំនិះទាំងឡាយដែលកំពុងបើកបរយ៉ាងហោចណាស់ក៏ត្រូវមានភ្លើងទីតាំងដែរ ដោយមិនចាំបាច់ប្រើភ្លើងកូត បើសិនជាទ្រូងផ្លូវមានពន្លឺភ្លើងអគ្គិសនីគ្រប់គ្រាន់ ។ ភ្លើងទីតាំងនេះប្រើប្រាស់សម្រាប់ប្រាប់វត្តមានយាន និងទំហំយានដល់អ្នកប្រើប្រាស់ផ្លូវដែលមើលពីមុខ ។

ឃ-ភ្លើងផ្សេងៗ : នៅពេលយប់ ឬនៅពេលថ្ងៃដែលមានអាកាសធាតុមិន

ល្អមិនអាចមើលទៅមុខឃើញច្បាស់ អ្នកបើកបរត្រូវប្រើ ៖

-ភ្លើងក្រហម ៖ សម្រាប់ប្រាប់វត្តមាននៃយានជំនិះ និងទំហំទទឹងយានដល់អ្នកប្រើប្រាស់ផ្លូវដែលមើលពីក្រោយ

-ភ្លើងបំភ្លឺផ្លាកលេខ ៖ សម្រាប់ឱ្យគេមើលលេខសម្គាល់យានជំនិះឃើញច្បាស់ពីខាងក្រោយ

-ភ្លើងទទឹងយាន ៖ បង្ហាញទំហំទទឹងយាន ឬបន្ទុកច្រេងច្រងាងដល់អ្នកប្រើប្រាស់ផ្លូវផ្សេងទៀត

-ភ្លើងសញ្ញាប្តូរទិស ៖ សម្រាប់ប្រាប់ដំណឹងដល់អ្នកប្រើប្រាស់ផ្លូវផ្សេងទៀត នៅពេលប្តូរទិសទៅឆ្វេង ឬទៅស្តាំ

-ភ្លើងសញ្ញាថយក្រោយ ៖ សម្រាប់ប្រាប់ដំណឹងដល់អ្នកប្រើប្រាស់ផ្លូវនៅខាងក្រោយយាន នៅពេលធ្វើចលនាថយក្រោយ

-ភ្លើងស្តុប ៖ សម្រាប់ប្រាប់ដំណឹងដល់អ្នកប្រើប្រាស់ផ្លូវខាងក្រោយយាននៅពេលជាន់ ឬចាប់ហ្វ្រាំង ដើម្បីបន្ថយល្បឿន ឬបញ្ឈប់យាន

-ភ្លើងសញ្ញាអាសន្ន ៖ សម្រាប់ប្រាប់ដំណឹងដល់អ្នកប្រើប្រាស់ផ្លូវផ្សេងទៀតនូវគ្រោះថ្នាក់ដែលអាចកើតមានឡើង ដូចជានៅពេលអ្នកបើកបរត្រូវបង្ខំចិត្តបើកបរក្នុងល្បឿនយឺត ដោយមូលហេតុអូសសណ្តោងរថយន្តខូច ឬផ្ទុកវត្ថុច្រេងច្រងាង និងនៅពេលឈប់ ឬចតលើទ្រូងផ្លូវក្រៅទីប្រជុំជន ដោយមូលហេតុយានខូច ឬជាប់ទាក់ទងនឹងគ្រោះថ្នាក់ ឬធ្លាក់ទំនិញមិនអាចលើកវិញបានភ្លាមៗ ។

-ភ្លើងចុះអ័ព្ទ៖ សម្រាប់ប្រើនៅពេលចុះអ័ព្ទ ឬភ្លៀងខ្លាំង ។ ភ្លើងចុះអ័ព្ទអាចប្រើដើម្បីជំនួសភ្លើងកូត ឬអាចប្រើបន្ថែមលើភ្លើងកូតបាន ។

២-ក្នុងករណីកំពុងបើកបរយានដែលមិនមែនយានយន្ត អ្នកបើកបរយានប្រភេទដូចខាងក្រោម ត្រូវអនុវត្តដូចតទៅនេះ ៖

-រទេះអូសទាញដោយមនុស្ស ត្រូវមានភ្លើង ឬកញ្ចក់ចាំងពន្លឺពណ៌ស ឬលឿងដាក់នៅខាងមុខ និងភ្លើង ឬកញ្ចក់ចាំងពន្លឺពណ៌ក្រហមមួយដាក់នៅខាងក្រោយ ។ ភ្លើងទាំងពីររនេះដាក់នៅជ្រុងឈមនឹងទ្រូងផ្លូវ

-រទេះអូសទាញដោយសត្វ ត្រូវមានភ្លើង ឬកញ្ចក់ចាំងពន្លឺពណ៌ស ឬលឿងពីរដាក់នៅខាងមុខជ្រុងសងខាង និងត្រូវមានភ្លើង ឬកញ្ចក់ចាំងពន្លឺពណ៌ក្រហមពីរដាក់នៅខាងក្រោយជ្រុងសងខាង

-ទោចក្រយាន និងត្រីចក្រយាន ត្រូវមានភ្លើង ឬកញ្ចក់ចាំងពន្លឺពណ៌ស យ៉ាងតិចមួយនៅខាងមុខ និងត្រូវមានភ្លើង ឬកញ្ចក់ចាំងពន្លឺពណ៌ក្រហមយ៉ាងតិចមួយ ឬភ្លើងក្រហមមួយនៅខាងក្រោយ

-រ៉ឺម៉កសណ្តោងដោយម៉ូតូ ឬដោយកង់ ត្រូវមានកញ្ចក់ចាំងពន្លឺ ឬភ្លើងពណ៌ក្រហមពីរដាក់នៅខាងក្រោយជ្រុងសងខាង

-យានប្រភេទទាំងនេះត្រូវឈប់ ឬចតតម្រៀបគ្នានៅជិតគែមបំផុតនៃទ្រូងផ្លូវ ។

៣-ក្នុងករណីឈប់ ឬ ចត យានយន្តនៅលើទ្រូងផ្លូវ ដែលគ្មានភ្លើងអគ្គិសនីសាធារណៈបំភ្លឺ ត្រូវប្រើ ៖

-ភ្លើងទីតាំង ៖ សម្រាប់ប្រាប់ដំណឹងដល់អ្នកប្រើប្រាស់ផ្លូវដែលមកពីខាងមុខនឹងពីវត្តមានយាន និងទំហំទទឹងយាន

-ភ្លើងក្រហម ៖ សម្រាប់ប្រាប់ដំណឹងដល់អ្នកប្រើប្រាស់ផ្លូវ ដែលមកពីខាងក្រោយនឹងពីវត្តមានយាន និងទំហំទទឹងយាន

-ភ្លើងបំភ្លឺផ្លាកលេខ ៖ សម្រាប់ឱ្យគេមើលលេខសម្គាល់យានជំនិះ ឃើញច្បាស់ពីខាងក្រោយ ។

នៅទីប្រជុំជន ការប្រើប្រាស់ភ្លើងសញ្ញាដែលបានចែងក្នុងវាក្យខណ្ឌនេះ មិនចាំបាច់ប្រើប្រាស់ទេ បើមានភ្លើងអគ្គិសនីបំភ្លឺតាមទ្រូងផ្លូវ ហើយមានពន្លឺគ្រប់គ្រាន់អាចឱ្យអ្នកប្រើប្រាស់ផ្លូវមើលយានបានច្បាស់ពីចម្ងាយដ៏សមល្មម ។

៤-ក្នុងករណី ចតរ៉ឺម៉ក ឬសីមីរ៉ឺម៉កដែលផ្តាច់ចេញពីរថយន្ត ត្រូវចតអែបចិញ្ចើមផ្លូវឬជាយផ្លូវ ហើយត្រូវប្រើភ្លើងស ឬលឿងមួយនៅខាងមុខ និងភ្លើងក្រហមមួយនៅខាងក្រោយ ។ ភ្លើងនីមួយៗ ត្រូវដាក់នៅជ្រុងនៃយាន "ជ្រុងរ៉ឺម៉ក" ដែលឈមមុខទៅនឹងទ្រូងផ្លូវ ដែលរ៉ឺម៉ក ឬ សីមីរ៉ឺម៉កតម្រៀបគ្នាតាមបណ្តោយនោះ ។

នៅក្នុងទីប្រជុំជន ការប្រើប្រាស់ភ្លើងនេះមិនចាំបាច់ទេ ប្រសិនបើមានភ្លើងអគ្គិសនីបំភ្លឺតាមទ្រូងផ្លូវដែលមានពន្លឺគ្រប់គ្រាន់ អាចឱ្យអ្នកប្រើប្រាស់ផ្លូវមើលឃើញយានជំនិះដែលចតនៅលើទ្រូងផ្លូវពីចម្ងាយសមល្មមបាន ។

៥-ក្នុងករណីយានជំនិះត្រូវបង្ខំឱ្យឈប់ ឬចតនៅលើទ្រូងផ្លូវដែលអាចបង្កជាឧបសគ្គ ឬគ្រោះថ្នាក់ចរាចរណ៍ ដូចជានៅជិតផ្លូវប្រសព្វ ផ្លូវបត់ ផ្លូវកោង ផ្លូវចុះទួល និងផ្លូវកាត់ផ្លូវរថភ្លើង ដោយមូលហេតុយានខូចគាំង ឬជាប់ទាក់ទិននឹងគ្រោះថ្នាក់ចរាចរណ៍ហើយ

មិនអាចរំកិលយានចេញពីផ្លូវបាននោះ អ្នកបើកបរត្រូវប្រាប់ដំណឹងអំពីឧបសគ្គដល់អ្នកបើកបរផ្សេងទៀតដោយប្រើភ្លើងសញ្ញាអាសន្ន ឬដាក់សញ្ញាត្រីកោណយ៉ាងតិចចម្ងាយ ៣០ ម៉ែត្រពីខាងក្រោយយាន ។ ចំពោះយានដែលមានទំនិញធ្លាក់លើផ្លូវហើយមិនអាចលើកទំនិញបានភ្លាមៗនោះត្រូវធ្វើសញ្ញាប្រាប់ដំណឹងដល់អ្នកបើកបរផ្សេងទៀត ដោយប្រើសញ្ញាត្រីកោណ និងភ្លើងសញ្ញាអាសន្នព្រមគ្នា ឬយ៉ាងហោចណាស់ក៏ប្រើសញ្ញាត្រីកោណមួយនៅចម្ងាយយ៉ាងតិច ៣០ ម៉ែត្រពីទំនិញនោះ ។

៦- ក្នុងករណីយាន បម្រើការនគរបាល យោធា អាវុធហត្ថ ពន្លត់អគ្គិភ័យ យានសង្គ្រោះរបស់មន្ទីរពេទ្យដែលកំពុងបំពេញភារកិច្ច អ្នកបើកបរមានសិទ្ធិប្រើប្រាស់ភ្លើងសញ្ញាពិសេសបានគ្រប់ពេលវេលា ។

**មាត្រា ២៩ .–**

ការប្រើប្រាស់ស្នូរស័ព្ទយានជំនិះ ត្រូវអនុវត្តដូចខាងក្រោម :

១-ការប្រើប្រាស់សញ្ញាស្នូរស័ព្ទ "ស៊ីផ្លេ" ត្រូវអនុញ្ញាតឱ្យប្រើប្រាស់តែនៅពេលថ្ងៃ ដើម្បីឱ្យដំណឹងដល់អ្នកប្រើប្រាស់ផ្លូវដទៃទៀត ដើម្បីជៀសវាងនូវគ្រោះថ្នាក់ដែលអាចកើតមានឡើងជាយថាហេតុ ។

២-នៅក្រៅទីប្រជុំជន សញ្ញាស្នូរស័ព្ទនេះ ត្រូវប្រើផងដែរសម្រាប់ឱ្យដំណឹងនៅពេលសុំជែង ។

៣-សញ្ញាស្នូរស័ព្ទ ត្រូវប្រើក្នុងរយៈពេលខ្លី គឺមិនយូរជាងការចាំបាច់ឡើយ ។

៤-ចាប់ពីពេលថ្ងៃលិចរហូតដល់ថ្ងៃរះ ការឱ្យដំណឹងដោយសញ្ញាស្នូរស័ព្ទត្រូវជំនួសដោយសញ្ញាភ្លើងកូត ហ្វាឆ្លាស់គ្នា ។

៥-នៅពេលយប់ ក្នុងទីប្រជុំជន សញ្ញាភ្លើងកូត ហ្វាឆ្លាស់គ្នាអាចប្រើផងដែរនៅពេលសុំជែង ។

៦-ចំពោះអ្នកបើកបរយានបម្រើការនគរបាល យោធា អាវុធហត្ថ ពន្លត់អគ្គិភ័យ យានសង្គ្រោះរបស់មន្ទីរពេទ្យដែលកំពុងបំពេញភារកិច្ច មានសិទ្ធិប្រើប្រាស់សញ្ញាស្នូរស័ព្ទពិសេសបានគ្រប់ពេលវេលា ។

៧-ហាមប្រើស៊ីផ្លេខ្យល់នៅក្នុងទីក្រុង ទីប្រជុំជន ឬនៅជិតមន្ទីរពេទ្យ ។

**មាត្រា ៣០ .–**

ការប្រើភ្លើងសញ្ញា និងស្នូរស័ព្ទពិសេស ត្រូវអនុវត្តដូចខាងក្រោម :

១-ភ្លើងសញ្ញាពិសេស គឺជាភ្លើងបន្ថែមមានជះពន្លឺផ្ទេកបន្ទោរភ្លឹបភ្លែតៗ វិលជុំវិញ និងមានច្រើនពណ៌ ដែលមានអត្ថន័យដូចខាងក្រោម ៖

ក-ភ្លើងសញ្ញាពិសេសពណ៌ខៀវ ឬក្រហម ត្រូវប្រើសម្រាប់តែយានដែលមានសិទ្ធិអាទិភាព ដូចជាយានបម្រើការនគរបាល យោធា អាវុធហត្ថ ពន្លត់អគ្គិភ័យ និងសង្គ្រោះបន្ទាន់របស់មន្ទីរពេទ្យនៅពេលកំពុងបំពេញភារកិច្ច ដើម្បីឱ្យដឹងពីវត្តមានយានដល់អ្នកប្រើប្រាស់ផ្លូវផ្សេងទៀត ។

ខ-ភ្លើងសញ្ញាពិសេសពណ៌លឿងទុំ ត្រូវប្រើសម្រាប់តែយានបម្រើការងារសាធារណៈ ដូចជាយានលាងសម្អាតផ្លូវ យានថែទាំជួសជុលផ្លូវ និងយានដឹកជញ្ជូនពិសេស ដែលបំពាក់ភ្លើងសញ្ញាពិសេសនេះ ហើយត្រូវបើកបរក្នុងល្បឿនយឺត ។

២-សញ្ញាសូរស័ព្ទពិសេស គឺជាសញ្ញាសូរស័ព្ទបន្ថែមដែលប្រើប្រាស់សម្រាប់យានមានសិទ្ធិអាទិភាព ដូចជាយានបម្រើការងារនគរបាល យោធា អាវុធហត្ថ ឬពន្លត់អគ្គិភ័យដែលមានបន្ថែមសំឡេងស៊ីរ៉ែនរោទិ៍ ។ ចំណែកឯយានសង្គ្រោះបន្ទាន់សម្រាប់មន្ទីរពេទ្យមានបន្ថែមសំឡេងរោទិ៍ពីរផងឡើងចុះៗ ។

៣-នៅពេលយានមានសិទ្ធិអាទិភាព ប្រើភ្លើងសញ្ញា និងសញ្ញាសូរស័ព្ទពិសេស អ្នកប្រើប្រាស់ផ្លូវផ្សេងទៀត ត្រូវបន្ថយល្បឿនអែបខាងស្តាំ ឬឈប់ដើម្បីទុកឱ្យយានទាំងនេះជែងជៀស ឬឆ្លងកាត់ដោយងាយស្រួល ។

ដោយឡែកនៅពេលកំពុងបំពេញភារកិច្ច អ្នកបើកបរយានមានសិទ្ធិអាទិភាពខាងលើនេះ អាចបើកបរ ៖

-បញ្ច្រាសទិសនៅលើផ្លូវឯកទិស

-នៅពេលភ្លើងសញ្ញាចរាចរណ៍ បញ្ចេញពន្លឺពណ៌ក្រហម

-ក្នុងល្បឿនមិនកំណត់

-ដោយមានសិទ្ធិអាទិភាពលើផ្លូវប្រសព្វ

-កាត់ ឬជាន់ខ្សែគំនូសបង្អួតជាប់ ។

ទោះបីក្នុងករណីណាក៏ដោយ អ្នកបើកបរយានប្រភេទនេះ ត្រូវបើកបរដោយប្រុងប្រយ័ត្នជានិច្ច ដើម្បីជៀសវាងគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ផ្លូវផ្សេងទៀត និងត្រូវគោរពសញ្ញាបញ្ជាដោយភ្នាក់ងារចរាចរណ៍ជាដាច់ខាត ។

**មាត្រា ៣១ .-**

ការបំពាក់សញ្ញាសូរស័ព្ទ ភ្លើងបំភ្លឺ ឬភ្លើងលំអផ្សេងៗទៀត ក្រៅពីការកំណត់លក្ខណៈបច្ចេកទេសរបស់យានជំនិះ ត្រូវហាមឃាត់ ។

## ជំពូកទី ៥
## ថ្មើរជើង និងអ្នកជិះ ឬអ្នកដឹកសត្វ

**មាត្រា ៣២ .-**

ថ្មើរជើង និងអ្នកអូស ឬអ្នករុញរទេះដៃត្រូវគោរពភ្លើងសញ្ញាចរាចរណ៍ ផ្លាកសញ្ញាចរាចរណ៍ ឬសញ្ញាបញ្ជារបស់ភ្នាក់ងារចរាចរណ៍ ។

ថ្មើរជើង ត្រូវអនុវត្តដូចខាងក្រោម :

១-ហាមប្រើប្រាស់ទ្រូងផ្លូវបើនៅសងខាងទ្រូងផ្លូវមានចិញ្ចើមផ្លូវ ឬជាយផ្លូវ ដែលជាកន្លែងបម្រុងទុកឱ្យថ្មើរជើងទៅមក ។

២-អនុញ្ញាតឱ្យប្រើប្រាស់ទ្រូងផ្លូវបើចិញ្ចើមផ្លូវ ឬជាយផ្លូវគ្មានលទ្ធភាពឱ្យថ្មើរជើងប្រើប្រាស់បាន ហើយត្រូវដើរឱ្យកៀកជិតចិញ្ចើមផ្លូវតាមទិសចរាចរណ៍ ។

៣-គ្រប់ថ្មើរជើងដែលមានបំណងឆ្លងកាត់ទ្រូងផ្លូវ មិនត្រូវឈានចូលទ្រូងផ្លូវដោយគ្មានការប្រុងប្រយ័ត្នឡើយ ។ ថ្មើរជើងត្រូវឆ្លងកាត់តាមគំនូសសញ្ញាសម្រាប់ថ្មើរជើង បើសិនជាមានគំនូសសញ្ញាសម្រាប់ថ្មើរជើងនៅជិតនោះ ។

៤-នៅកន្លែងដែលមានគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់ :

-ថ្មើរជើងត្រូវគោរពធ្វើតាមបញ្ជាភ្នាក់ងារនគរបាលចរាចរណ៍ ឬតាមសញ្ញាភ្លើងសញ្ញាចរាចរណ៍

-នៅកន្លែងដែលគ្មានភ្លើងសញ្ញាចរាចរណ៍ ឬគ្មានភ្នាក់ងារនគរបាលចរាចរណ៍បញ្ជាទេ ថ្មើរជើងមុននឹងឆ្លងកាត់ទ្រូងផ្លូវ ត្រូវប្រាកដថាការឆ្លងកាត់នេះពុំបណ្តាលឱ្យមានគ្រោះថ្នាក់អ្វីឡើយ ដោយប្រមាណគិតដល់ភាពមើលច្បាស់នូវចម្ងាយ និងល្បឿនរបស់យាន ដែលកំពុងរត់លើទ្រូងផ្លូវ ។

៥-នៅកន្លែងដែលគ្មានគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់ :

-ថ្មើរជើងមុននឹងឆ្លងកាត់ទ្រូងផ្លូវ ត្រូវជឿជាក់ថាទង្វើនេះអាចធ្វើទៅបានដោយគ្មានការរំខានចរាចរណ៍យាន ឬធ្វើឱ្យមានគ្រោះថ្នាក់អ្វីឡើយ

-នៅពេលឆ្លងកាត់ទ្រូងផ្លូវ ហាមថ្មើរជើងឆ្លងកាត់កន្លែងប្រសព្វនៃទ្រូងផ្លូវ ។ ថ្មើរជើង ត្រូវឆ្លងកាត់តាមបន្ទាត់កែងនៃអ័ក្សទ្រូងផ្លូវ និងហាមបង្អែបង្អង់ ឬឈប់នៅលើទ្រូងផ្លូវបើសិនគ្មានការចាំបាច់ ។

៦-ហាមកុំឱ្យក្មេងអាយុតិចជាង ៦ ឆ្នាំ ដើររហេតរហូតលើផ្លូវថ្នល់ ។

៧-ចំពោះជនងងឹតភ្នែកទាំងពីរ ដែលធ្វើដំណើរលើផ្លូវថ្នល់ និងឆ្លងកាត់ផ្លូវថ្នល់ត្រូវមានអ្នកនាំផ្លូវ ។

**មាត្រា ៣៣ .-**

ក្បួនដង្ហែផ្សេងៗដែលបានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច :

-ត្រូវហែនៅអែបទ្រូងផ្លូវខាងស្តាំតាមទិសចរាចរណ៍ ហើយត្រូវទុកទ្រូងផ្លូវផ្នែកខាងឆ្វេងឱ្យនៅទំនេរទាំងស្រុង ។

-អាចដើរហែជាក្បួនមានជាពីរបី ឬបួនជួរបាន ដោយប្រមាណដល់ទទឹងទ្រូងផ្លូវ ហើយត្រូវគោរពបទបញ្ជាចរាចរណ៍ ។

-ក្បួនដង្ហែត្រូវកាន់ភ្លើងពណ៌សនៅខាងមុខ និងត្រូវកាន់ភ្លើងពណ៌ក្រហមនៅខាងក្រោយនៅពេលយប់ ឬពេលថ្ងៃ កាលណាមើលមិនឃើញច្បាស់គ្រប់គ្រាន់ ។

**មាត្រា ៣៤ .-**

អ្នកជិះ ឬដឹកសត្វ ត្រូវអនុវត្តដូចខាងក្រោម :

១-អ្នកជិះ ដឹក ឬបរសត្វនៅលើទ្រូងផ្លូវ មិនត្រូវបង្កឱ្យមានឧបសគ្គ ឬគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ផ្លូវផ្សេងទៀត ដោយត្រូវដាក់ចំនួនមនុស្សដឹកឱ្យសមស្របនឹងចំនួនសត្វដែលអាចបញ្ជាសត្វឱ្យទៅ ឬឈប់បានគ្រប់គ្រាន់ និងទាន់ពេលវេលា ។

២-នៅពេលយប់ ឬពេលថ្ងៃ កាលណាមើលមិនឃើញច្បាស់ អ្នកដឹកសត្វពាហនៈត្រូវប្រើភ្លើងពណ៌សនៅខាងមុខ និងពណ៌ក្រហមនៅខាងក្រោយ ។

៣-ហាមលែងសត្វ ឱ្យដើររហេតរហូតលើផ្លូវថ្នល់ ។

៤-សត្វដែលឈប់នៅលើទ្រូងផ្លូវ មិនត្រូវបង្កឱ្យរំខានដល់យានជំនិះផ្សេងៗទៀតដែលកំពុងធ្វើចរាចរណ៍ ។

៥-នៅក្នុងទីប្រជុំជន អ្នកជិះ ដឹក ឬបរសត្វនៅលើទ្រូងផ្លូវត្រូវឈប់នៅតាមទិសដែលខ្លួនកំពុងធ្វើចរាចរណ៍ ដោយអនុវត្តដូចខាងក្រោម :

-ចំពោះផ្លូវផ្លូវដែលមានទិសចរាចរណ៍ពីរ ត្រូវឈប់ខាងស្តាំតាមទិសចរាចរណ៍របស់ខ្លួន
-ចំពោះផ្លូវផ្លូវឯកទិស ត្រូវឈប់ខាងស្តាំ ឬខាងឆ្វេងតាមទិសចរាចរណ៍ លើកលែងតែមានផ្លាកសញ្ញាផ្ទុយ ។

## ជំពូកទី ៦
## ករណីមានគ្រោះថ្នាក់ចរាចរណ៍

**មាត្រា ៣៥ .-**

គ្រប់ករណីគ្រោះថ្នាក់ចរាចរណ៍ ជាសមត្ថកិច្ចរបស់នគរបាលចរាចរណ៍ ។

នៅរាល់ករណីគ្រោះថ្នាក់ចរាចរណ៍ នគរបាលចរាចរណ៍ត្រូវខិតខំឱ្យអស់សមត្ថភាពដើម្បី :

១-រក្សាសណ្តាប់ធ្នាប់សាធារណៈ នៅកន្លែងកើតហេតុ ។

២-ចាត់វិធានការសង្គ្រោះជនរងគ្រោះជាបន្ទាន់ ។

៣-ចាត់វិធានការជំនាញ ប្រមូលភស្តុតាង និងព័ត៌មានដើម្បីធ្វើកំណត់ហេតុស្តីពីគ្រោះថ្នាក់ចរាចរណ៍ ។

៤-រក្សាសន្តិសុខឱ្យដល់គ្រប់ភាគីពាក់ព័ន្ធ ។

៥-កត់ត្រាអត្តសញ្ញាណ និងអាសយដ្ឋានរបស់គ្រប់ភាគីពាក់ព័ន្ធ ។

៦-ដោះស្រាយជម្លោះដែលបណ្តាលមកពីគ្រោះថ្នាក់ចរាចរណ៍នោះស្របតាមបញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៣៦ .-**

ក្នុងករណីមានគ្រោះថ្នាក់ចរាចរណ៍ អ្នកបើកបរ ឬអ្នកប្រើប្រាស់ផ្លូវគ្រប់រូបដែលពាក់ព័ន្ធនឹងគ្រោះថ្នាក់ ឬអ្នកដែលឃើញហេតុការណ៍នេះ ត្រូវអនុវត្តដូចខាងក្រោម :

១-បញ្ឈប់យានរបស់ខ្លួនជាបន្ទាន់ ដោយមិនធ្វើឱ្យរំខាន ឬបង្កឱ្យមានគ្រោះថ្នាក់ដល់អ្នកដទៃទៀត ។

២-ជូនដំណឹងជាបន្ទាន់ទៅអាជ្ញាធរដែនដី ឬនគរបាលចរាចរណ៍ ។

៣-ហាមប្រើហិង្សា ឬបង្កជម្លោះរវាងភាគីពាក់ព័ន្ធ ។

៤-ហាមចាកចេញពីកន្លែងកើតហេតុមុនការព្រមព្រៀងគ្នា ឬគ្មានការអនុញ្ញាតពីនគរបាលចរាចរណ៍ ។

**មាត្រា ៣៧ .-**

បើគ្រោះថ្នាក់កើតឡើងបណ្តាលឱ្យខូចខាតតែសម្ភារៈ ភាគីទាំងពីរអាចសម្រួលគ្នាបានដោយមិនចាំបាច់សុំអន្តរាគមន៍ពីមន្ត្រីនគរបាលចរាចរណ៍ឡើយ ។

**មាត្រា ៣៨ .-**

ក្នុងករណីមានមនុស្សរងរបួស ឬបាត់បង់ជីវិត អ្នកបើកបរ ឬអ្នកប្រើប្រាស់ផ្លូវគ្រប់រូបដែលពាក់ព័ន្ធនឹងគ្រោះថ្នាក់ ឬអ្នកដែលឃើញហេតុការណ៍នេះ ត្រូវអនុវត្តដូចខាងក្រោម :

១-ត្រូវផ្តល់ព័ត៌មានជាបន្ទាន់ដល់អាជ្ញាធរដែនដី ឬនគរបាលចរាចរណ៍ ដែលនៅជិតកន្លែងកើតហេតុបំផុត ។

២-ត្រូវចាត់ចែងជូនព័ត៌មាន ឬបញ្ជូនជនរងគ្រោះជាបន្ទាន់ទៅមន្ទីរពេទ្យដែលនៅជិតកន្លែងកើតហេតុបំផុត ។ ហាមអ្នកមានយានជំនិះគ្រប់ប្រភេទបដិសេធដោយឥតសមហេតុនូវសំណើជួយសង្គ្រោះនេះ ។

៣-ត្រូវសហការជួយធានាឱ្យមានសន្តិសុខដល់គ្រប់ភាគីពាក់ព័ន្ធ និងដល់កិច្ចដំណើរការចរាចរណ៍ទូទៅនៅជុំវិញកន្លែងកើតហេតុ ។

៤-ត្រូវជៀសវាងធ្វើឱ្យមានការប្រែប្រួលដល់ទីកន្លែងកើតហេតុ ឬឱ្យបាត់ដាន ឬស្នាម ដែលជាកត្តាមានប្រយោជន៍ដល់ការស្វែងរកអ្នកទទួលខុសត្រូវក្នុងរឿងគ្រោះថ្នាក់ ។

៥-ត្រូវរង់ចាំនៅនឹងកន្លែងកើតហេតុ រហូតដល់ភ្នាក់ងារនគរបាលចរាចរណ៍បានមកដល់ ។ ហាមអ្នកបង្កគ្រោះថ្នាក់ចាកចោលកន្លែងកើតហេតុមុនបានការអនុញ្ញាតពីភ្នាក់ងារនគរបាលចរាចរណ៍ ។

**មាត្រា ៣៩ .-**

ចំពោះគ្រោះថ្នាក់ចរាចរណ៍ដែលភាគីម្ខាងជាភ្នាក់ងារទូត ឬបេសកកម្មទូត ភ្នាក់ងារនគរបាលចរាចរណ៍ត្រូវធ្វើកំណត់ហេតុ និងរបាយការណ៍ស្តីពីគ្រោះថ្នាក់នេះផ្ញើទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិដើម្បីចាត់ចែងឱ្យអ្នកតំណាងមកចូលរួមសហការជាមួយភ្នាក់ងារនគរបាលចរាចរណ៍ ដើម្បីពិនិត្យ និងលើកវិធានការសម្រុះសម្រួល ។

# ជំពូកទី ៧
# ការគ្រប់គ្រងយាន និង ការដឹកជញ្ជូន

**មាត្រា ៤០ .-**

ប័ណ្ណបើកបរជាតិ និងអន្តរជាតិសម្រាប់យានយន្តគ្រប់ប្រភេទ ត្រូវចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន ។ ក្រសួងមហាផ្ទៃ ឬក្រសួងការពារជាតិ ត្រូវចេញប័ណ្ណបើកបរសម្រាប់អ្នកបើកបរយានយន្តពិសេសបម្រើជំនាញដូចជា រថក្រោះ រថពាសដែក រថយន្តបំពាក់យុទ្ធោបករណ៍ យានយន្តប្រដេញ ម៉ូតូកង់បី ម៉ូតូហែអម ដែលជាទ្រព្យសម្បត្តិរដ្ឋ ។

ប័ណ្ណបើកបរយានយន្តផ្លូវគោកនៃព្រះរាជាណាចក្រកម្ពុជាមាន ០៥ ប្រភេទដូចខាងក្រោម:

**ប្រភេទ ក** : សម្រាប់ទោចក្រយានយន្ត និងត្រីចក្រយានយន្តមាន :

**ក ១**- សម្រាប់ទោចក្រយានយន្តដែលមានទំហំស៊ីឡាំងចាប់ពី ៤៩ ដល់ ១២៥សង់ទីម៉ែត្រគូប ។

**ក២**- សម្រាប់ទោចក្រយានយន្តដែលមានទំហំស៊ីឡាំងលើសពី ១២៥សង់ទីម៉ែត្រគូប ។

- ទោចក្រយានយន្តមានសណ្ដោង និងត្រីចក្រយានយន្ត ។

**ប្រភេទ ខ** : សម្រាប់រថយន្តដឹកអ្នកដំណើរមិនលើសពី ០៩ នាក់ ដោយគិតទាំងអ្នកបើកបរ ។

- រថយន្តដឹកទំនិញដែលមានទម្ងន់សរុបអតិបរមាមិនលើសពី ៣,៥ តោន ។

- រថយន្តក្នុងប្រភេទខ នេះ អាចសណ្ដោងរ៉ឺម៉ក់ដែលមានទម្ងន់សរុបអតិបរមាមិនលើសពី ០,៧៥ តោន ។

**ប្រភេទ គ** : សម្រាប់រថយន្តដឹកទំនិញដែលមានទម្ងន់សរុបអតិបរមាលើសពី ៣,៥ តោន និងអាចមានសណ្ដោងរ៉ឺម៉ក់ ដែលមានទម្ងន់សរុបអតិបរមាមិនលើសពី ០,៧៥ តោន ។

**ប្រភេទ ឃ** : សម្រាប់រថយន្តដឹកអ្នកដំណើរ :

**ឃ ១** : សម្រាប់រថយន្តដឹកអ្នកដំណើរចាប់ពី ១០នាក់ ដល់ ២០នាក់ ដោយ

គិតទាំងអ្នកបើកបរ និងអាចមានសណ្តោងរ៉ឺម៉កដែលមានទម្ងន់សរុបអតិបរមាមិនលើសពី ០,៧៥ តោន ។

**ឃ ២ :** សម្រាប់រថយន្តដឹកអ្នកដំណើរលើសពី ២០នាក់ ដោយគិតទាំងអ្នកបើកបរ និងអាចមានសណ្តោងរ៉ឺម៉កដែលមានទម្ងន់សរុបអតិបរមា មិនលើសពី០,៧៥ តោន ។

**ប្រភេទ ង :** សម្រាប់រថយន្តប្រភេទ ខ គ និង ឃ មានសណ្តោងរ៉ឺម៉កដែលមានទម្ងន់សរុបអតិបរមាលើសពី ០,៧៥តោន ត្រូវចែកជាបីប្រភេទគឺប្រភេទ ង(ខ) ប្រភេទ ង(គ) និងប្រភេទ ង(ឃ) ។

**មាត្រា ៤១ .-**

លក្ខខណ្ឌផ្សេងៗទាក់ទងនឹងប័ណ្ណបើកបរ ត្រូវកំណត់ដូចខាងក្រោម :

១-អ្នកកាន់ប័ណ្ណបើកបរប្រភេទណា ត្រូវបើកបរយានយន្តប្រភេទនោះ ។ ចំពោះជនពិការមានសិទ្ធិបើកបរយានយន្តពិសេស និងមានប័ណ្ណបើកបរដែលមានលក្ខណៈពិសេសសម្រាប់តែជនពិការ ។

២-អ្នកកាន់ប័ណ្ណបើកបរ ត្រូវសុំបន្តសុពលភាពឱ្យបានមុនពេលកំណត់ ដែលប័ណ្ណបើកបរអស់សុពលភាព ។ ការមិនបានមកបន្តសុពលភាព ត្រូវទទួលការពិន័យតាមច្បាប់កំណត់ ។

៣-អាយុអ្នកបើកបរត្រូវកំណត់តាមប្រភេទប័ណ្ណបើកបរ ដូចខាងក្រោម :

-អាយុ ១៦ឆ្នាំយ៉ាងតិច ចំពោះប្រភេទ ក១

-អាយុ ១៨ឆ្នាំយ៉ាងតិច ចំពោះប្រភេទ ក២ និង ខ

-អាយុ ២២ឆ្នាំយ៉ាងតិច ចំពោះប្រភេទ គ និង ឃ១

-អាយុ ២៤ឆ្នាំយ៉ាងតិច ចំពោះប្រភេទ ឃ ២ និង ង

៤-អ្នកមានប័ណ្ណប្រភេទ ក២ អាចបើកបរយានយន្តប្រភេទ ក១ បាន ។

៥-អ្នកមានប័ណ្ណប្រភេទ ខ អាចបើកបរយានយន្តប្រភេទ ក១ យានយន្តកសិកម្ម ឬយានយន្តឧបករណ៍ដែលមានល្បឿនអតិបរមាមិនលើសពី ៤០ គីឡូម៉ែត្រក្នុងមួយម៉ោង តែមិនអាចបើកបរយានយន្តប្រភេទ ក២ ឬ គ ឬ ឃ១ ឬ ឃ ២ ឬ ង បានទេ ។

៦-ចំពោះអ្នកបើកបរយានយន្តឧបករណ៍ ដែលមានល្បឿនអតិបរមាលើសពី ៤០ គីឡូម៉ែត្រក្នុងមួយម៉ោង ត្រូវមានប័ណ្ណប្រភេទ គ ។

៧-ដើម្បីមានសិទ្ធិប្រឡងយកប័ណ្ណបើកបរប្រភេទ គ ត្រូវមានប័ណ្ណបើកបរប្រភេទ

ខ ឬឃ១ សិន ។

៨-អ្នកបើកបរយានយន្តប្រភេទគ ឬឃ១ ឬឃ២ អាចបើកបរយានយន្តប្រភេទខបាន ។

៩-អ្នកមានប័ណ្ណបើកបរប្រភេទគ មិនអាចបើកបរយានយន្តប្រភេទឃ២ បានទេ ប៉ុន្តែអ្នកមានប័ណ្ណបើកបរប្រភេទឃ២ អាចបើកបរយានយន្តប្រភេទខ ឬគ ឬឃ១ បាន ។

១០-ដើម្បីមានសិទ្ធិប្រឡងយកប័ណ្ណបើកបរប្រភេទ ឃ១ ត្រូវមានប័ណ្ណបើកបរប្រភេទខ សិន ។

១១-ដើម្បីមានសិទ្ធិប្រឡងយកប័ណ្ណបើកបរប្រភេទឃ២ ត្រូវមានប័ណ្ណបើកបរប្រភេទខ ឬគ ឬឃ១ សិន ។

១២-ដើម្បីមានសិទ្ធិប្រឡងយកប័ណ្ណបើកបរប្រភេទ ង ត្រូវមានប័ណ្ណបើកបរប្រភេទខ ឬគ ឬឃ១ ឬឃ២ សិន ។

១៣-អ្នកមានប័ណ្ណបើកបរប្រភេទង អាចមានសិទ្ធិបើកបររថយន្តសណ្តោងរ៉ឺម៉កដែលមានទម្ងន់សរុបអតិបរមាលើសពី ០,៧៥តោន បានទៅតាមប្រភេទប័ណ្ណបើកបរដូចជា ង(ខ) ឬង(គ) ឬង(ឃ១) ឬង(ឃ២) ។

**មាត្រា ៤២ .-**

រយៈពេលសុពលភាពនៃប័ណ្ណបើកបរមានដូចខាងក្រោម :

១-ប័ណ្ណបើកបរប្រភេទ ក និង ខ មានសុពលភាពរហូតដល់អ្នកកាន់ប័ណ្ណបើកបរមានអាយុដល់ ៦៥ ឆ្នាំ ប៉ុន្តែត្រូវពិនិត្យសុខភាព និងពន្យារប័ណ្ណបើកបរក្នុងរយៈពេល ៥ ឆ្នាំម្តង។

២-ប័ណ្ណបើកបរប្រភេទ គ ឃ និង ង មានសុពលភាពរយៈពេល ៣ ឆ្នាំ ។ អ្នកបើកបរត្រូវពន្យារសុពលភាពនៃប័ណ្ណបើកបររបស់ខ្លួនក្នុងរយៈពេល ៣ ឆ្នាំម្តង បន្ទាប់ពីការពិនិត្យសុខភាពដែលអនុញ្ញាតឱ្យបើកបរបាន ។

៣-ចាប់ពីអាយុ ៦៥ ឆ្នាំឡើងទៅអ្នកបើកបរដែលប្រើប្រាស់ប័ណ្ណ បើកបរគ្រប់ប្រភេទ ត្រូវត្រួតពិនិត្យសុខភាព ២ ឆ្នាំម្តងៗ ។ រីឯសុពលភាពនៃប័ណ្ណបើកបរត្រូវពន្យារពេល ២ ឆ្នាំម្តង ។

**មាត្រា ៤៣ .—**

គ្រប់ប័ណ្ណបើកបរត្រូវមានប័ណ្ណពិន្ទុដែលមានពិន្ទុសរុបចំនួន ១២ ពិន្ទុ ហើយចំនួនពិន្ទុនេះនឹងត្រូវកាត់បន្ថយនៅពេលប្រព្រឹត្តបទល្មើសចរាចរណ៍ ដែលមានដូចខាងក្រោម :

ក-ត្រូវកាត់បន្ថយ ១ ពិន្ទុ :

-មិនពាក់ខ្សែក្រវាត់ ឬមួកសុវត្ថិភាព

-ប្រើភ្លើងហ្វានៅពេលជួបយានមកពីទិសផ្ទុយ

-បើកបរជាន់តាមខ្សែគំនូសបង្ខូតកណ្តាលទ្រូងផ្លូវ

-បើកបរលើសល្បឿនកំណត់ចាប់ពី ១ ទៅ ១៩ គីឡូម៉ែត្រក្នុងមួយម៉ោង

-បើកបរនៅពេលយប់ដោយគ្មានភ្លើងគ្រប់គ្រាន់ តាមប្រភេទយានយន្ត

-ការផ្ទុកមនុស្សជិះលើសកំណត់ ។

ខ-ត្រូវកាត់បន្ថយ ២ ពិន្ទុ :

-បើកបរលើសល្បឿនកំណត់ចាប់ពី ២០ ទៅ ២៩ គីឡូម៉ែត្រក្នុងមួយម៉ោង

-បើកបរបង្កើនល្បឿន នៅពេលគេកំពុងជែងខ្លួន

-ការបត់ឆ្វេង ស្តាំ មិនបានត្រឹមត្រូវ

-ការបត់ត្រឡប់ក្រោយ នៅកន្លែងហាមឃាត់

-ការមិនគោរពល័ក្ខខ័ណ្ឌនៃប័ណ្ណបើកបរ

-ការបត់ឆ្វេង ស្តាំ ឬឈប់មិនបានឱ្យសញ្ញាជាដំណឹង

-ការជែង ឬជៀសមិនបានត្រឹមត្រូវ

-បើកបរដោយគ្មានទុកចន្លោះសុវត្ថិភាពត្រឹមត្រូវ

-បើកបរដោយធ្វេសប្រហែស ធ្វើឱ្យរំខានដល់អ្នកប្រើប្រាស់ផ្លូវដទៃទៀត

-មិនបានឱ្យសញ្ញាជាដំណឹងត្រឹមត្រូវនៅពេលចេញដំណើរ

-យានមានលក្ខណៈបច្ចេកទេសមិនត្រឹមត្រូវ

-ផ្ទុកទំនិញមិនបានត្រឹមត្រូវ

-ចតយាននៅលើគំនូសសម្រាប់ថ្មើរជើងឆ្លងកាត់

-ឈប់ ឬចតនៅលើកន្លែងគំនូសតម្រឹមទ្រូងផ្លូវ

-ដាក់ក្មេងអាយុក្រោម ១០ ឆ្នាំ ឱ្យអង្គុយនៅកៅអីផ្នែកខាងមុខនៃរថយន្ត ដោយគ្មានមនុស្សចាស់អង្គុយជាមួយ

-មិនបានដាក់ក្មេងអាយុក្រោម ៥ ឆ្នាំ អង្គុយក្នុងកៅអីពិសេសសម្រាប់ក្មេងអង្គុយ ឬដេក ។

គ-ត្រូវកាត់បន្ថយ ៣ ពិន្ទុ :

-ការឈប់ ឬចតនៅកន្លែងដែលគ្រោះថ្នាក់

-ការជែងដែលប្រកបដោយគ្រោះថ្នាក់

-បើកបរជែងគ្នានៅកន្លែងហាមឃាត់

-ការប្តូរទិសគ្មានឱ្យសញ្ញាជាមុន

-បើកបរឆ្លងកាត់គំនូសបង្ហូតជាប់កណ្តាលទ្រូងផ្លូវ

-បើកបរលើសល្បឿនកំណត់ចាប់ពី ៣០ ទៅ ៣៩គីឡូម៉ែត្រក្នុងមួយម៉ោង

-បើកបរក្នុងពេលមានអត្រាជាតិស្រវឹងចាប់ពី ០,២៥ ទៅ០,៣៩មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី ០,៥ ទៅ ០,៧៩ក្រាមក្នុងមួយលីត្រឈាម

-ប្រណាំងគ្នាតាមផ្លូវដោយគ្មានច្បាប់អនុញ្ញាត

-កំហុសនៃការឈប់ ឬមិនផ្តល់សិទ្ធិអាទិភាពនៅកន្លែងថ្មើរជើងឆ្លងកាត់

-មិនគោរពភ្លើងសញ្ញាចរាចរណ៍ពណ៌ក្រហម

-មិនគោរពផ្លាកសញ្ញាឈប់ ឬសញ្ញាសិទ្ធិអាទិភាព

-មិនគោរពសញ្ញាបញ្ជាចរាចរណ៍របស់នគរបាលចរាចរណ៍។

ឃ-ត្រូវកាត់បន្ថយ ៤ ពិន្ទុ :

-បើកបរលើសល្បឿនកំណត់ចាប់ពី ៤០ ទៅ ៤៩ គីឡូម៉ែត្រក្នុងមួយម៉ោង

-បើកបរមិនគោរពសិទ្ធិអាទិភាពនៅត្រង់ផ្លូវប្រសព្វ

-ការបើកបរទន្ទឹមគ្នា

-ការធ្វើឱ្យស្ទះចរន្តចរាចរណ៍

-មិនបានផ្តល់សិទ្ធិអាទិភាពឱ្យយានយន្តមានសិទ្ធិអាទិភាព

-ទំនិញធ្លាក់ពីលើយាន

-បើកបរបញ្ច្រាសទិសចរាចរណ៍

-បើកបរដែលប្រកបដោយគ្រោះថ្នាក់ ។

ង-ត្រូវកាត់បន្ថយ ៦ ពិន្ទុ :

-បើកបរលើសល្បឿនកំណត់ចាប់ពី៥០ គីឡូម៉ែត្រក្នុងមួយម៉ោងឡើងទៅ

-បើកបរក្នុងពេលមានអត្រាជាតិស្រវឹងចាប់ពី ០,៤០ មីលីក្រាមក្នុងមួយ

លើត្រឹមខ្យល់ ឬចាប់ពី ០,៨ ក្រាមក្នុងមួយលីត្រឈាមឡើងទៅ ឬមានឥទ្ធិពលគ្រឿងញៀន

-រត់គេចខ្លួនពេលមានគ្រោះថ្នាក់ចរាចរណ៍

-ការប្រើប្រាស់ផ្លាកលេខ និងប័ណ្ណសម្គាល់យានយន្តក្លែងក្លាយ

-បើកបរខុសច្បាប់ចរាចរណ៍ ហើយបង្កឱ្យមានអ្នករបួសដោយអចេតនា

-បើកបរខុសច្បាប់ចរាចរណ៍ ហើយបង្កឱ្យមានអ្នកស្លាប់ដោយអចេតនា

ក្នុងករណីប័ណ្ណបើកបរត្រូវព្យួរទុកដូចមានចែងក្នុងចំណុច២.ខ នៃមាត្រា ៦៥ នៃច្បាប់នេះ

-កំហុសនៃការប្រើប្រាស់ប័ណ្ណបើកបរជាដដែលៗ

-បដិសេធមិនឱ្យធ្វើតេស្តជាតិអាកុល ឬគ្រឿងញៀន

-រត់គេចពីមន្ត្រីនគរបាលចរាចរណ៍

-ផ្ទុកមនុស្សលើទំនិញដែលប្រកបដោយគ្រោះថ្នាក់ ។

**មាត្រា ៤៤ .-**

ករណីដែលពាក់ព័ន្ធនឹងប័ណ្ណពិន្ទុ :

-ក្នុងករណីអស់ពិន្ទុ ប័ណ្ណបើកបរត្រូវទុកជាមោឃៈ

-ក្នុងករណីប្រព្រឹត្តបទល្មើសម្តង ការកាត់ពិន្ទុមិនត្រូវឱ្យលើសពី ៨ ពិន្ទុឡើយ

-ក្នុងករណីពិន្ទុត្រូវបានកាត់បន្ថយមួយចំនួនហើយ ប៉ុន្តែបន្ទាប់ពីរយៈពេល ៣ ឆ្នាំ បន្ទាប់ពីការដកពិន្ទុចុងក្រោយ អ្នកបើកបរមិនបានធ្វើឱ្យមានកំហុសអ្វីមួយថែមទៀតដើម្បីឱ្យកាត់បន្ថយពិន្ទុនោះ អ្នកបើកបរនឹងត្រូវទទួលប័ណ្ណពិន្ទុថ្មីដែលមានចំនួន ១២ ពិន្ទុដោយស្វ័យប្រវត្តិ

-ក្នុងករណីពិន្ទុបានកាត់បន្ថយមួយចំនួនហើយ ប៉ុន្តែអ្នកបើកបរចង់បង្កើនពិន្ទុឡើងវិញ ត្រូវធ្វើការរៀនបំប៉នរយៈពេល២ថ្ងៃ ដែលរៀបចំឡើងដោយក្រសួងសាធារណការ និងដឹកជញ្ជូន ។ ក្នុងការរៀននេះ ពិន្ទុអាចកើនឡើង ៤ ពិន្ទុ ប៉ុន្តែមិនអនុញ្ញាតឱ្យចំនួនពិន្ទុសរុបលើសពី ១១ពិន្ទុឡើយ ។ អ្នកបើកបរអាចរៀនបង្កើនពិន្ទុក្នុងចន្លោះពេលយ៉ាងតិច ២ ឆ្នាំ

-ក្នុងករណីប័ណ្ណបើកបរត្រូវទុកជាមោឃៈដោយការកាត់បន្ថយពិន្ទុអស់ អ្នកបើកបរត្រូវរៀននិងប្រឡងយកប័ណ្ណបើកបរជាថ្មីឡើងវិញក្នុងរយៈពេល ៦ ខែ ដោយឆ្លងកាត់ការត្រួតពិនិត្យសុខភាព

-ក្នុងករណីប័ណ្ណបើកបរត្រូវទុកជាមោឃៈដោយអ្នកបើកបរបង្កឱ្យមានអ្នករង

របួសធ្ងន់ធ្ងរ ឬស្លាប់ដោយអចេតនា អ្នកបើកបរអាចរៀន និងប្រឡងយកប័ណ្ណបើកបរជាថ្មីឡើងវិញយ៉ាងតិច ៥ ឆ្នាំ ក្រោយពីការបង្កឱ្យមានគ្រោះថ្នាក់ ដោយឆ្លងកាត់ការត្រួតពិនិត្យសុខភាព ។

ទម្រង់បែបបទនៃការចេញប័ណ្ណពិន្ទុសម្រាប់ប័ណ្ណបើកបរ ត្រូវកំណត់ដោយប្រកាសក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ៤៥ ._**

លើកលែងតែមានកិច្ចព្រមព្រៀង ឬសន្ធិសញ្ញាអន្តរជាតិទទួលស្គាល់ប័ណ្ណបើកបរទៅវិញទៅមក ជាទ្វេភាគី ឬពហុភាគីជាមួយព្រះរាជាណាចក្រកម្ពុជា ជនបរទេសដែលជាជនអន្តោប្រវេសន៍ស្របច្បាប់ដែលមានបំណងបើកបរលើផ្លូវថ្នល់ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានប័ណ្ណបើកបររបស់កម្ពុជា តាមមធ្យោបាយពីរយ៉ាង :

១-ត្រូវប្រឡងយកប័ណ្ណបើកបរដូចប្រជាពលរដ្ឋខ្មែរដែរ ។

២-ត្រូវយកប័ណ្ណបើកបររបស់ប្រទេសខ្លួន មកប្តូរយកប័ណ្ណបើកបរខ្មែរដោយដាក់ពាក្យសុំនៅក្រសួងសាធារណការ និងដឹកជញ្ជូន និងត្រូវបំពេញល័ក្ខខ័ណ្ឌដូចខាងក្រោម :

ក-ត្រូវមានលិខិតឆ្លងដែន និងទិដ្ឋាការមានសុពលភាព ។

ខ-ប័ណ្ណបើកបរត្រូវមានសុពលភាព ។

គ-មានអាសយដ្ឋានច្បាស់លាស់ដោយមានសេចក្តីបញ្ជាក់របស់អាជ្ញាធរមានសមត្ថកិច្ច ។

ឃ-មានលិខិតបញ្ជាក់កាយសម្បទា និងបានរស់នៅក្នុងប្រទេសកម្ពុជាយ៉ាងតិច ៦ ខែ ។

ង-ក្នុងករណីប័ណ្ណបើកបរមិនសរសេរជាអក្សរអង់គ្លេស ឬបារាំងត្រូវតែបកប្រែជាភាសាអង់គ្លេស ឬបារាំងដោយមានការបញ្ជាក់ទទួលស្គាល់ពីស្ថានទូត ឬកុងស៊ុលរបស់ខ្លួន ឬស្ថាប័នមានសមត្ថកិច្ច ។

សុពលភាពប័ណ្ណបើកបររបស់ជនបរទេស ដែលត្រូវបានប្តូរមកប័ណ្ណបើកបររបស់កម្ពុ-ជាមានរយៈពេល ១ ឆ្នាំ ។ ចំពោះសុពលភាពប័ណ្ណបើកបររបស់ជនបរទេសដែលបានប្រឡងជាប់មានរយៈពេលដូចគ្នានឹងជនជាតិខ្មែរដែរ ។ ក្នុងករណីប័ណ្ណបើកបរជាតិរបស់ជនបរទេសអស់សុពលភាព សាមីខ្លួនត្រូវធ្វើការប្រឡងទាំងទ្រឹស្តីទាំងការអនុវត្តន៍ដែលចង្អុលឡើងវិញ ។

ជនបរទេសដែលមានប័ណ្ណបើកបរប្រភេទ គ ឃ និង ខ មិនអាចប្តូរយកប័ណ្ណបើកបររបស់កម្ពុជាប្រភេទ គ ឃ ឬ ខ បានឡើយ ប៉ុន្តែអាចប្តូរយកប័ណ្ណបើកបរប្រភេទ ក ឬ ខ បាន ។

**មាត្រា ៤៦.-**

គ្រប់សាលាបង្រៀនបើកបរ ត្រូវមានលិខិតអនុញ្ញាតធ្វើអាជីវកម្មបង្រៀនបើកបរនិង ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។

គ្រប់គ្រូបង្ហាត់នៅសាលាបង្រៀនបើកបរ ត្រូវមានវិញ្ញាបនប័ត្របញ្ជាក់សមត្ថភាព ដែល ចេញឱ្យដោយក្រសួងសាធារណការ និងដឹកជញ្ជូន ។ ក្រសួងសាធារណការ និងដឹកជញ្ជូនត្រូវ ចេញប្រកាសអំពីនីតិវិធីនៃការចេញប័ណ្ណបើកបរ ការធ្វើអាជីវកម្មសាលាបង្រៀនបើកបរ ល័ក្ខ-ខ័ណ្ឌប្រឡងយកវិញ្ញាបនប័ត្របញ្ជាក់សមត្ថភាពរបស់គ្រូបង្ហាត់ និងកម្មវិធីសិក្សានៅសាលា បង្រៀនបើកបរយានយន្ត ។

ក្នុងករណីចាំបាច់ ក្រសួងមហាផ្ទៃមានសិទ្ធិត្រួតពិនិត្យគ្រប់សាលារៀនបើកបរឯកជន ទាំងអស់ ។

**មាត្រា ៤៧.-**

គ្រប់យានយន្ត និងរ៉ឺម៉ក ឬសឺមីរ៉ឺម៉កមានទម្ងន់សរុបលើសពី ៧៥០ គក្រ មុននឹងដាក់ឱ្យ ធ្វើចរាចរណ៍លើផ្លូវថ្នល់ ត្រូវចុះបញ្ជីការសុំប័ណ្ណសម្គាល់យានយន្ត និងមានពាក់ផ្លាកលេខនៅ ក្រសួងសាធារណការ និងដឹកជញ្ជូន ។ យានយន្តដែលពុំទាន់ចុះបញ្ជីការសុំប័ណ្ណសម្គាល់ និង គ្មានពាក់ផ្លាកលេខ ត្រូវផ្ទុកលើយានដែលមានផ្លាកលេខ នៅពេលធ្វើចរាចរណ៍ ។

គ្រប់រថយន្ត ទោចក្រយានយន្ត ត្រីចក្រយានយន្ត និងគ្រឿងចក្រដែលជាទ្រព្យសម្បត្តិ របស់រដ្ឋសម្រាប់បម្រើការសន្តិសុខជាតិ សណ្តាប់ធ្នាប់សង្គម និងការពារជាតិនៅសមរភូមិគ្រប់ គ្រងដោយក្រសួងមហាផ្ទៃ ឬក្រសួងការពារជាតិត្រូវចុះបញ្ជីការ ផ្តល់ប័ណ្ណ សម្គាល់យានយន្ត ដោយក្រសួងមហាផ្ទៃ ឬ ក្រសួងការពារជាតិ ។

ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវផ្តល់បញ្ជីស្ថិតិយានយន្តគ្រប់ប្រភេទដែលបាន ចុះបញ្ជីការសុំប័ណ្ណសម្គាល់យានយន្ត មកក្រសួងមហាផ្ទៃ មួយសប្តាហ៍ម្តង ។

ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ក៏ត្រូវផ្តល់ព័ត៌មានអំពីចំនួនរថយន្ត ទោចក្រ យានយន្ត ត្រីចក្រយានយន្ត ឬគ្រឿងចក្រជាទ្រព្យសម្បត្តិរបស់រដ្ឋ ក្រោមការគ្រប់គ្រងរបស់ ខ្លួនជូនទៅក្រសួងសាធារណការ និងដឹកជញ្ជូន មួយសប្តាហ៍ម្តង ។

ការចុះបញ្ជីយានជំនិះ និងការចេញផ្លាកលេខសម្គាល់យានជំនិះ ត្រូវកំណត់ដោយអនុ-ក្រឹត្យ ។

**មាត្រា ៤៨ .-**

គ្រប់យានយន្ត រ៉ឺម៉ក សីមីរ៉ឺម៉ក ទោចក្រយានយន្ត ឬត្រីចក្រយានយន្តដែលធ្វើចរាចរណ៍លើផ្លូវថ្នល់ ត្រូវមានវិញ្ញាបនប័ត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ ចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន ឬក្រុមហ៊ុនដែលមានការអនុញ្ញាតពីក្រសួងសាធារណការ និងដឹកជញ្ជូន ។

សុពលភាពនៃវិញ្ញាបនប័ត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ត្រូវកំណត់ដូចខាងក្រោម :

១-រថយន្តធុនទេសចរណ៍ថ្មីដែលមិនទាន់ប្រើប្រាស់ ត្រូវមកទទួលយកវិញ្ញាបនប័ត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តលើកទី ១ ដែលមានសុពលភាព ៤ ឆ្នាំ ។ បន្ទាប់មកត្រូវមកធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសរៀងរាល់ ២ ឆ្នាំម្តង ។

២-រថយន្តធុនទេសចរណ៍ចាស់ ដែលបានប្រើប្រាស់រួចហើយ ត្រូវមកធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេស រៀងរាល់ ២ ឆ្នាំម្តង ។

៣-រថយន្តថ្មីធ្វើអាជីវកម្មដឹកអ្នកដំណើរ ដឹកទំនិញ និងរថយន្តប្បការណ៍ថ្មីដែលមិនទាន់ប្រើប្រាស់ត្រូវមកទទួលយកវិញ្ញាបនប័ត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តលើកទី ១ ដែលមានសុពលភាព ២ ឆ្នាំ ។ បន្ទាប់មកត្រូវមកធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសរៀងរាល់ ១ឆ្នាំ ម្តង ។

៤-រថយន្តចាស់ធ្វើអាជីវកម្មដឹកអ្នកដំណើរ ដឹកទំនិញ និងរថយន្តប្បការណ៍ចាស់ដែលបានប្រើប្រាស់រួចហើយ ត្រូវមកធ្វើការត្រួតពិនិត្យបច្ចេកទេសរៀងរាល់ ១ ឆ្នាំម្តង ។

៥-រ៉ឺម៉កថ្មី និងសីមីរ៉ឺម៉កថ្មីដែលមិនទាន់ប្រើប្រាស់ ត្រូវមកទទួលយកវិញ្ញាបនប័ត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តដែលមានសុពលភាព ២ ឆ្នាំ ។ បន្ទាប់មកត្រូវមកធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសរៀងរាល់ ១ ឆ្នាំម្តង ។

៦-រ៉ឺម៉កចាស់ និងសីមីរ៉ឺម៉កចាស់ដែលបានប្រើប្រាស់រួចហើយ ត្រូវមកធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសរៀងរាល់ ១ ឆ្នាំម្តង ។

៧-គ្រប់យានយន្ត រ៉ឺម៉ក និងសីមីរ៉ឺម៉ក ដែលទើបបានកែច្នៃក្នុងប្រទេសរួច មុននឹងធ្វើការចុះបញ្ជីផ្តល់ផ្លាកលេខ និងប័ណ្ណសម្គាល់យានយន្ត ត្រូវមកធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសជាមុនសិន បន្ទាប់មកត្រូវធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសរៀងរាល់ ១ ឆ្នាំម្តង ។

៨-ទោចក្រយានយន្ត និងត្រីចក្រយានយន្តថ្មីដែលមិនទាន់ប្រើប្រាស់ ត្រូវមកទទួលយកវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ដែលមានសុពលភាព ៤ឆ្នាំ ។ បន្ទាប់មក ត្រូវមកធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសរៀងរាល់ ២ ឆ្នាំម្តង ។

៩-ទោចក្រយានយន្ត និងត្រីចក្រយានយន្តចាស់ដែលបានប្រើប្រាស់រួចហើយ ត្រូវមកធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តជារៀងរាល់ ២ ឆ្នាំម្តង ។

១០-រ៉ឺម៉កទោចក្រយានយន្ត ត្រូវមកធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសរៀងរាល់ ២ ឆ្នាំម្តង ។

ការកំណត់លក្ខណៈបច្ចេកទេសយានជំនិះ និងការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះគ្រប់ប្រភេទ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ៤៩ .-**

គ្រប់យានដ្ឋានផ្គុំសផ្គុំលយានយន្តនិងយានដ្ឋានកែច្នៃតម្លើងយានយន្ត ត្រូវមានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មដែលចេញឱ្យដោយក្រសួងសាធារណការ និងដឹកជញ្ជូន និងក្នុងករណីចាំបាច់ត្រូវមានការត្រួតពិនិត្យពីក្រសួងមហាផ្ទៃ ។

ទម្រង់បែបបទនៃការចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មយានដ្ឋានផ្គុំសផ្គុំល និងយានដ្ឋានកែច្នៃយានយន្ត ព្រមទាំងបទដ្ឋានបច្ចេកទេសកែច្នៃយានយន្ត ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥០ .-**

ការគ្រប់គ្រងការដឹកជញ្ជូន ត្រូវកំណត់ដូចខាងក្រោម :

១-គ្រប់ក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនក្នុងប្រទេស ឬ ឆ្លងដែន និងភ្នាក់ងារផ្តល់សេវាដឹកជញ្ជូនឯកត្តបែប ឬពហុបែប ត្រូវមានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មដែលចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន ។

២-បែបបទនៃការគ្រប់គ្រងអាជីវករដឹកជញ្ជូន និងអ្នកផ្តល់សេវាដឹកជញ្ជូន ត្រូវកំណត់ដោយអនុក្រឹត្យ ។

៣-ការគ្រប់គ្រងការដឹកជញ្ជូនទំនិញ និងអ្នកដំណើរ ត្រូវកំណត់ដោយអនុក្រឹត្យ ។

៤-ការដឹកជញ្ជូនទំនិញមានគ្រោះថ្នាក់ និងទំនិញងាយខូចគុណភាព ត្រូវកំណត់ដោយអនុក្រឹត្យ ។

៥-កិច្ចសន្យាដឹកជញ្ជូនទំនិញ ឬអ្នកដំណើរតាមផ្លូវគោក ត្រូវមានចែងក្នុងច្បាប់មួយដោយឡែក ។

៦-ការដឹកជញ្ជូនអន្តរជាតិតាមផ្លូវគោក ត្រូវអនុវត្តតាមកិច្ចព្រមព្រៀងអន្តរជាតិ នៅពេលព្រះរាជាណាចក្រកម្ពុជាបានចូលជាភាគី ។

**មាត្រា ៥១ .-**

គ្រប់រថយន្តរ៉ឺម៉ក ឬសីមីរ៉ឺម៉កដែលធ្វើអាជីវកម្មដឹកជញ្ជូនទំនិញ និងអ្នកដំណើរ ត្រូវមាន លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មដែលចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន ។

លិខិតអនុញ្ញាតឱ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូន មានសុពលភាពមួយឆ្នាំ ។ ម្ចាស់ យានយន្តត្រូវមកបន្តសុពលភាពមួយឆ្នាំម្តងៗ បើយឺតយ៉ាវនឹងត្រូវពិន័យ ។ ក្រសួងសាធារណ ការ និងដឹកជញ្ជូនត្រូវចេញប្រកាសណែនាំលម្អិតអំពីការផ្តល់លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម ដឹកជញ្ជូន ។

**មាត្រា ៥២ .-**

នៅពេលកំពុងធ្វើសកម្មភាពអាជីវកម្មដឹកជញ្ជូន មធ្យោបាយដឹកជញ្ជូននីមួយៗត្រូវមាន លិខិតស្នាម ដែលចេញឱ្យដោយក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងពាក់ព័ន្ធផ្សេងៗ ទៀត ដូចខាងក្រោម :

ក - ប័ណ្ណសម្គាល់យានយន្ត និងផ្លាកលេខ ។

ខ - ប័ណ្ណបើកបរត្រឹមត្រូវតាមប្រភេទយានយន្ត ។

គ - វិញ្ញាបនប័ត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ។

ឃ- លិខិតអនុញ្ញាតឱ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូន ។

ង - លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មដឹកជញ្ជូន ។

ច - លិខិតធានារ៉ាប់រងចេញដោយក្រុមហ៊ុនធានារ៉ាប់រង ។

ឆ - លិខិតអនុញ្ញាតផ្សេងៗចេញដោយស្ថាប័នមានសមត្ថកិច្ចផ្សេងៗទៀត ។

**មាត្រា ៥៣ .-**

ការរៀបចំផ្ទុកទំនិញ និងមនុស្ស ត្រូវអនុវត្តដូចខាងក្រោម :

១-ការផ្ទុកទំនិញលើយានជំនិះ ត្រូវរៀបចំឱ្យត្រឹមត្រូវដើម្បីការពារ :

-ការបង្កគ្រោះថ្នាក់ដល់មនុស្ស ឬធ្វើឱ្យខូចទ្រព្យសម្បត្តិសាធារណៈ ឬ ឯកជនដោយការអូស ឬ ធ្លាក់តាមផ្លូវ

-ការបាំងភ្នែកអ្នកបើកបរ ឬការធ្វើឱ្យអន់ថយ នូវលំនឹងយាន និងការបើក បរយាន

-ការបង្កឱ្យមានសំឡេង ឬ ការបង្កើនធូលី ឬ ការធ្វើឱ្យរំខានផ្សេងៗទៀត ដែលអាចជៀសវាងបាន

-ការធ្វើឱ្យបាំងភ្លើងស្តុប ភ្លើងសញ្ញាប្តូរទិស កញ្ចក់ចាំងពន្លឺ និងផ្លាកលេខយានយន្ត ។

២-គ្រប់ឧបករណ៍ការពារបន្ថែមដូចជាខ្សែនីឡុង ខ្សែកាបច្រវ៉ាក់ និងកម្រាលសំពត់តង់ ដែលប្រើប្រាស់សម្រាប់សុវត្ថិភាព ឬការពារទំនិញ ត្រូវគ្របនិងចងឱ្យបានជាប់ល្អ ។

៣-គ្រប់ករណីនៃការផ្ទុកឈើហ៊ុប ឬ វត្ថុផ្សេងៗទៀត ដែលមានបណ្តោយវែងបន្ទុក នោះមិនត្រូវឱ្យលួតហួសពីគែមខាងមុខយាន និងមិនត្រូវឱ្យហួសពីគែមខាងក្រោយនៃយានចំនួន ៣ ម៉ែត្រ ឬ ធ្លាក់អូសដីឡើយ ។

៤-បើសិនជាបន្ទុកត្រូវលួតហួស ១ ម៉ែត្រពីគែមខាងក្រោយយាន ពេលថ្ងៃត្រូវចងក្រណាត់ពណ៌ក្រហម ពេលយប់ត្រូវដាក់កញ្ចក់ចាំងពន្លឺពណ៌ក្រហមនៅចុងបន្ទុក ។ ចំពោះទទឹងបន្ទុកមិនត្រូវឱ្យលើសហួសពីគែមទទឹងយាន ហើយកម្ពស់មិនត្រូវឱ្យហួសលើសពីដំបូលយានដែលរោងចក្រផលិតយានកំណត់ឡើយ លើកលែងតែរថយន្តផ្ទុកមនុស្សចំនួនអតិបរមាត្រឹម ២០ នាក់ ហើយដែលអាចផ្ទុកទំនិញកម្ពស់អតិបរមាត្រឹម ០,៥០ ម៉ែត្រពីលើដំបូល និងត្រូវមានជើងទម្រ ឬរនាំងចាប់ភ្ជាប់ដំបូលយ៉ាងរឹងមាំ ។

៥-ក្នុងករណីផ្ទុកទំនិញគ្រោះថ្នាក់ត្រូវរៀបចំទុកដាក់ ឬ វេចខ្ចប់ឱ្យមានសុវត្ថិភាពល្អ ហើយត្រូវសរសេរឈ្មោះប្រភេទ និងបិទផ្លាកសញ្ញាសម្គាល់វត្ថុគ្រោះថ្នាក់នោះ ។

៦-បច្ចេកទេសផ្ទុក វេចខ្ចប់ទំនិញ ត្រូវកំណត់ដោយប្រកាសក្រសួងសាធារណការ និងដឹកជញ្ជូន ។

៧-ការដឹកជញ្ជូនមនុស្សត្រូវមានកៅអីអង្គុយ ឬ មានបង្កាន់ដៃ ឬ ប្រដាប់តោងឈររឹងមាំ ហើយត្រូវឱ្យមានផាសុខភាពល្អ ។

ការផ្ទុកមនុស្សត្រូវហាមឃាត់ ដូចខាងក្រោម :

-ហាមផ្ទុកមនុស្សលើសពីចំនួនកន្លែងអង្គុយ ដែលកំណត់ដោយរោងចក្រផលិតយាន ឬ កំណត់ដោយក្រសួងសាធារណការ និងដឹកជញ្ជូន

-ហាមផ្ទុកមនុស្សនៅលើដំបូលកាប៊ីន ឬ ដំបូលរថយន្ត

-ហាមតោងពីមុខ ពីក្រោយ ឬ ពីចំហៀងរថយន្ត

-ហាមផ្ទុកមនុស្សនៅលើរ៉ឺម៉កឬ សឺមីរ៉ឺម៉ក

-ហាមផ្ទុកវត្ថុដែលមានក្លិនអាក្រក់ ឬ មានជាតិពុលក្នុងរថយន្តដឹកមនុស្ស ។



45/63

**មាត្រា ៥៤ .–**

ការផ្ទុកទំនិញលើរថយន្តរ៉ឺម៉ក ឬសីមីរ៉ឺម៉កមិនត្រូវឱ្យលើសទម្ងន់អតិបរមាសង្កត់លើភ្លៅ និងទម្ងន់សរុបអតិបរមារបស់យានដែលកំណត់ដោយរោងចក្រផលិតយានឡើយ និងមិនត្រូវលើសទម្ងន់អនុញ្ញាតដូចខាងក្រោម :

១-ការកម្រិតទម្ងន់អតិបរមាសង្កត់លើភ្លៅរថយន្តរ៉ឺម៉ក ឬ សីមីរ៉ឺម៉កត្រូវកំណត់ត្រឹម :

-៦ តោន សម្រាប់ភ្លៅទោល ដែលមានកង់ ២ ស្ថិតនៅផ្នែកចង្កូតរថយន្ត

-១១ តោន សម្រាប់ភ្លៅភ្លោះ ដែលមានកង់ ៤ ស្ថិតនៅផ្នែកចង្កូតរថយន្ត

-១០ តោន សម្រាប់ភ្លៅទោល ដែលមានកង់ ៤

-១៩ តោន សម្រាប់ភ្លៅភ្លោះ ដែលមានកង់ ៨

-២៤ តោន សម្រាប់ភ្លៅ ៣ ជិតគ្នាដែលមានកង់ ១២ ។

២-ការកម្រិតទម្ងន់សរុបអនុញ្ញាតអតិបរមារបស់រថយន្តត្រូវកំណត់ត្រឹម :

-១៦ តោន សម្រាប់រថយន្តដែលមានភ្លៅ ២ គឺភ្លៅទោលផ្នែកខាងមុខរថយន្តដែលមានកង់ ២ និងភ្លៅទោលខាងក្រោយរថយន្តដែលមានកង់ ៤

-២៥ តោន សម្រាប់រថយន្តដែលមានភ្លៅ ៣ គឺភ្លៅទោលផ្នែកខាងមុខរថយន្ត ដែលមានកង់ ២ និងភ្លៅភ្លោះផ្នែកខាងក្រោយរថយន្តដែលមានកង់ ៨

-៣០ តោន សម្រាប់រថយន្តដែលមានភ្លៅ ៤ គឺភ្លៅភ្លោះផ្នែកខាងមុខរថយន្តដែលមានកង់ ៤ និងភ្លៅភ្លោះផ្នែកខាងក្រោយរថយន្តដែលមានកង់ ៨ ។

៣-ការកម្រិតទម្ងន់សរុបអនុញ្ញាតអតិបរមារបស់រថយន្តសណ្តោងរ៉ឺម៉ក ត្រូវកំណត់ត្រឹម :

-៣៥ តោន សម្រាប់រថយន្តសណ្តោងរ៉ឺម៉កដែលមានភ្លៅ ៤ គឺភ្លៅទោលផ្នែកខាងមុខរថយន្ត ដែលមានកង់ ២ ភ្លៅទោលផ្នែកខាងក្រោយរថយន្តដែលមានកង់ ៤ ភ្លៅទោលផ្នែកខាងមុខរ៉ឺម៉កដែលមានកង់ ៤ និងភ្លៅទោលផ្នែកខាងក្រោយរ៉ឺម៉ក ដែលមានកង់ ៤

-៤០ តោន សម្រាប់រថយន្តសណ្តោងរ៉ឺម៉កដែលមានភ្លៅចាប់ពី ៥ ឡើងទៅ ។

៤-ការកម្រិតទម្ងន់សរុបអនុញ្ញាតអតិបរមារបស់រថយន្តសណ្តោងសីមីរ៉ឺម៉ក ត្រូវកំណត់ត្រឹម :

-៣៥ តោន សម្រាប់រថយន្តសណ្តោងសីមីរ៉ឺម៉កដែលមានភ្លៅ ៤ គឺភ្លៅទោល

ផ្នែកខាងមុខរថយន្តដែលមានកង់ ២ ភ្លៅទោលផ្នែកខាងក្រោយរថយន្តដែលមានកង់ ៤ និងភ្លៅភ្លោះផ្នែកខាងក្រោយសីមីរ៉ឺម៉កដែលមានកង់ ៨

-៤០តោនសម្រាប់រថយន្តសណ្ដោងសីមីរ៉ឺម៉ក ដែលមានភ្លៅចាប់ពី ៥ឡើងទៅ ។

ចំពោះទម្ងន់រថយន្ត និងរថយន្តសណ្ដោងរ៉ឺម៉ក ឬ សីមីរ៉ឺម៉កដែលគ្មានចែងនៅក្នុងចំណុចខាងលើនេះ ត្រូវសុំលិខិតអនុញ្ញាតពិសេសពីក្រសួងសាធារណការ និងដឹកជញ្ជូន ។

នៅពេលឆ្លងកាត់ស្ពាន គ្រប់អ្នកបើកបររថយន្ត រថយន្តសណ្ដោងរ៉ឺម៉ក ឬ សីមីរ៉ឺម៉កត្រូវគោរពតាមទម្ងន់សរុបអនុញ្ញាតអតិបរមាដែលកំណត់ក្នុងផ្លាកសញ្ញាដាក់តាំងនៅពីមុខស្ពាន ។

ចំពោះទំហំរថយន្ត និងរថយន្តសណ្ដោងរ៉ឺម៉ក ឬសីមីរ៉ឺម៉ក ដែលគ្មានបន្ទុកត្រូវកំណត់ដូចខាងក្រោម :

-ប្រវែងទទឹងអតិបរមាមិនត្រូវឱ្យលើសពី ២,៥០ ម៉ែត្រ លើកលែងតែយានយន្ត-បករណ៍ មិនត្រូវឱ្យលើសពី ៣ ម៉ែត្រ

-ប្រវែងកម្ពស់អតិបរមាមិនត្រូវឱ្យលើសពី ៤,២០ ម៉ែត្រ

-ប្រវែងបណ្ដោយអតិបរមានៃរថយន្តនីមួយៗមិនត្រូវឱ្យលើសពី ១២,២០ ម៉ែត្រ

-ប្រវែងបណ្ដោយអតិបរមានៃរថយន្តដែលមានសណ្ដោងសីមីរ៉ឺម៉កនីមួយៗ មិនត្រូវឱ្យលើសពី ១៦ ម៉ែត្រ

-ប្រវែងបណ្ដោយអតិបរមា នៃរថយន្តដែលមានសណ្ដោងរ៉ឺម៉កនីមួយៗ មិនត្រូវឱ្យលើសពី ១៨ ម៉ែត្រ ។

បទដ្ឋានបច្ចេកទេសស្ដីពីទំហំ និងទម្ងន់យានជំនិះផ្សេងទៀតត្រូវកំណត់ដោយប្រកាសក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ៥៥ .-**

ការបង់ប្រាក់សម្រាប់ថ្លៃសេវាចេញប័ណ្ណបើកបរ ប័ណ្ណសម្គាល់ ផ្លាកលេខ ត្រួតពិនិត្យលក្ខណៈបច្ចេកទេស និងលិខិតអនុញ្ញាតឱ្យយានយន្តធ្វើអាជីវកម្ម ប្រាក់ពិន័យក្នុងការឃឹតយ៉ាងផ្សេងៗ និងសេវាផ្សេងៗត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន ។

## ជំពូកទី ៨
## គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក

**មាត្រា ៥៦ .-**

ត្រូវបង្កើតគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ដែលមានភារកិច្ចសម្របសម្រួលប្រមូលកម្លាំង និងបង្កើនកិច្ចសហការរវាងក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងពាក់ព័ន្ធផ្សេងៗ សមាគមអ្នកដឹកជញ្ជូន អង្គការក្រៅរដ្ឋាភិបាល និងអង្គការឯកជនផ្សេងទៀត ដើម្បីចាត់វិធានការណ៍កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ក្នុងទិសដៅការពារអាយុជីវិតប្រជាជន ការពារការខូចខាតទ្រព្យសម្បត្តិរដ្ឋ ឯកជន និងធានាឱ្យបានរឹងមាំនូវសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពចរាចរណ៍ផ្លូវគោកនៅតាមផ្លូវថ្នល់ ។

សមាសភាព តួនាទី ភារកិច្ច និងការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥៧ .-**

គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ត្រូវមានថវិកាដោយឡែកដែលជាឧបសម្ព័ន្ធរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងថវិការបស់ដៃគូសុវត្ថិភាពផ្លូវគោក សម្រាប់ប្រើប្រាស់លើវិធានការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ។

## ជំពូកទី ៩
## សមត្ថកិច្ចរបស់មន្ត្រីអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក

**មាត្រា ៥៨ .-**

មន្ត្រីអនុវត្តច្បាប់ចរាចរណ៍មានពីរក្រុមគឺ អង្គភាពនគរបាលចរាចរណ៍ និងក្រុមត្រួតពិនិត្យចម្រុះ :

១-អង្គភាពនគរបាល ដែលទទួលបន្ទុករៀបចំសណ្តាប់ធ្នាប់សុវត្ថិភាពចរាចរណ៍មានភារកិច្ច :

-ចាត់ចែងចរាចរណ៍ឱ្យមានសណ្តាប់ធ្នាប់ល្អ

-តាមដាន ល្បាត និងពិនិត្យអំពើល្មើសនឹងបទប្បញ្ញត្តិចរាចរណ៍

-ធ្វើរបាយការណ៍ស្តីពីសភាពការណ៍សណ្តាប់ធ្នាប់ចរាចរណ៍ បទល្មើស

ចរាចរណ៍ និងគ្រោះថ្នាក់ចរាចរណ៍ ដែលកើតមានឡើង

-ធ្វើការពិន័យជាប្រាក់ចំពោះបទល្មើសដែលត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍

-សម្រុះសម្រួលក្នុងករណីគ្រោះថ្នាក់ចរាចរណ៍ ដូចមានចែងក្នុងមាត្រា ៦៤

-ត្រួតពិនិត្យ និងកត់ត្រាដំណើររឿងហេតុនៅពេលមានគ្រោះថ្នាក់ចរាចរណ៍ ក្នុងករណីចាំបាច់ធ្វើការដកហូតជាបណ្តោះអាសន្ននូវប័ណ្ណបើកបរ និងឃាត់យានជំនិះតាមមាត្រា ៦១ មាត្រា ៦៥ និងមាត្រា ៦៦

-ធ្វើកំណត់ហេតុដោយមានភ្ជាប់ជាមួយនូវសំណុំរឿងបញ្ជូនទៅតុលាការ ក្នុងករណីកំណត់ដោយច្បាប់នេះ ។

២-ក្រុមត្រួតពិនិត្យចម្រុះដែលមានមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងពាក់ព័ន្ធមានភារកិច្ចត្រួតពិនិត្យលើបទល្មើសចរាចរណ៍ក្នុងករណីចាំបាច់ ។ តួនាទីភារកិច្ចរបស់ក្រុមត្រួតពិនិត្យចម្រុះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥៩ .-**

ជនប្រព្រឹត្តបទល្មើសមានសិទ្ធិប្តឹងតវ៉ាទៅតុលាការ ក្នុងករណីដែលខ្លួនកើតទុក្ខមិនសុខចិត្តចំពោះសេចក្តីសម្រេចមិនត្រឹមត្រូវ អំពីការពិន័យលើបទល្មើសនោះ ។

**មាត្រា ៦០ .-**

ក្នុងការឃាត់យានជំនិះដើម្បីត្រួតពិនិត្យ នគរបាលចរាចរណ៍ត្រូវអនុវត្តដោយជៀសវាងការធ្វើឱ្យស្ទះចរាចរណ៍ ឬ បង្កឱ្យមានគ្រោះថ្នាក់ចរាចរណ៍ ។

**មាត្រា ៦១ .-**

មន្ត្រីនគរបាលចរាចរណ៍មានសិទ្ធិដកប័ណ្ណបើកបរឃ្លាំទុក ក្នុងរយៈពេលមិនលើសពី ១ ខែយ៉ាងយូរ គិតទាំងការដកពិន្ទុដែលមានចែងក្នុងមាត្រា ៤៣ នៃច្បាប់នេះ ចំពោះបទល្មើសណាមួយដូចខាងក្រោម :

១-បើកបរខុសទិសចរាចរណ៍ ឬ បើកបរតាមទិសចរាចរណ៍ ដែលមានដាក់សញ្ញាហាមឃាត់ ។

២-បើកបរដោយល្បឿនលើស ៤០ គីឡូម៉ែត្រក្នុងមួយម៉ោងពីល្បឿនដែលបានកំណត់ក្នុងច្បាប់នេះ ។

៣-មិនគោរពសិទ្ធិអាទិភាព ។

ፉ

៤-មិនគោរពផ្លាកសញ្ញាឈប់ ឬ ភ្លើងសញ្ញាចរាចរណ៍ពណ៌ក្រហម ឬ ពណ៌ក្រហមភ្លឹបភ្លែតៗ ។

៥-បើកបរយានដែលមានកង់ច្រវាក់ដែកផ្ទាល់នៅលើផ្លូវថ្នល់ក្រាលកៅស៊ូ ។

មន្ត្រីនគរបាលចរាចរណ៍ មិនត្រូវដកហូតប័ណ្ណសម្គាល់យានយន្ត ឬ ប័ណ្ណបើកបរ នៅក្នុងករណីដែលពុំមានចែងក្នុងច្បាប់នេះឡើយ ។

**មាត្រា ៦២ .-**

ក្នុងករណីមានគ្រោះថ្នាក់ចរាចរណ៍អាស្រ័យទៅតាមករណីនីមួយៗនោះ ការឃាត់យានជំនិះ ការឃាត់ខ្លួនអ្នកបើកបរដើម្បីសាកសួរព័ត៌មាននិងធ្វើកំណត់ហេតុកត់ត្រា ជាសមត្ថកិច្ចរបស់មន្ត្រីនគរបាលចរាចរណ៍នៅកន្លែងកើតហេតុ ។ ក្នុងករណីអ្នកបើកបរស្ថិតនៅក្រោមឥទ្ធិពលជាតិស្រវឹង ឬ គ្រឿងញៀន មន្ត្រីនគរបាលយុត្តិធម៌ផ្នែកចរាចរណ៍ត្រូវប្រគល់ភារកិច្ចនេះជូនមន្ទីរពេទ្យពិនិត្យនិងចេញលិខិតបញ្ជាក់អត្រាជាតិស្រវឹង ឬ គ្រឿងញៀន ដើម្បីភ្ជាប់ជាមួយកំណត់ហេតុគ្រោះថ្នាក់ទៅតុលាការ ។

**មាត្រា ៦៣ .-**

បទល្មើសចរាចរណ៍ដែលត្រូវផ្តន្ទាទោសជាប់ពន្ធនាគារ និងផ្តន្ទាទោសពិន័យជាប្រាក់ជាសមត្ថកិច្ចរបស់តុលាការ ។ ក្នុងករណីនេះ មន្ត្រីនគរបាលចរាចរណ៍នៅខេត្ត ក្រុង ត្រូវបញ្ជូនតាមឋានានុក្រមទៅសាលាជម្រះក្តីនៃកន្លែងកើតហេតុនូវកំណត់ហេតុរៀបរាប់ពីហេតុការណ៍ដោយត្រូវភ្ជាប់ជាមួយនូវចម្លើយរបស់អ្នកបើកបរ និងអ្នករងគ្រោះ ឬ ចម្លើយរបស់សាក្សីដែលធ្វើឡើងដោយមន្ត្រីនគរបាលចរាចរណ៍ ។ សំណុំរឿងដែលប្រមូលបានមកនេះ គប្បីមានព័ត៌មានច្បាស់លាស់គ្រប់គ្រាន់ដើម្បីបញ្ជូនទៅតុលាការ ។

**មាត្រា ៦៤ .-**

បទល្មើសចរាចរណ៍ដែលមានលក្ខណៈជាបទលហុដែលត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់មន្ត្រីនគរបាលចរាចរណ៍ ។

មន្ត្រីនគរបាលចរាចរណ៍មានសិទ្ធិសម្រុះសម្រួល ក្នុងករណីមានគ្រោះថ្នាក់ដែលបណ្តាលឱ្យសងតែសំណងខូចខាត ។ បើសិនជាការសម្រុះសម្រួលមិនបានសម្រេច មន្ត្រីនគរបាលចរាចរណ៍ ត្រូវបញ្ជូនសំណុំរឿងនេះទៅតុលាការ ។

**មាត្រា ៦៥ .-**

មន្ត្រីនគរបាលចរាចរណ៍ត្រូវរៀបចំសំណុំរឿងបទប្តឹងទៅតុលាការចំពោះគ្រប់អ្នកបើកបរដែលប្រព្រឹត្តបទល្មើសចរាចរណ៍ ដើម្បីទុកប័ណ្ណបើកបរជាមោឃៈ ឬ ត្រូវព្យួរទុកប័ណ្ណបើកបរមួយរយៈពេលដូចខាងក្រោម :

១-ការព្យួរទុកប័ណ្ណបើកបរក្នុងរយៈពេលមិនលើសពី ១ ឆ្នាំដោយគិតទាំងការដកពិន្ទុ ដូចមានចែងក្នុងមាត្រា ៤៣ នៃច្បាប់នេះ :

ក-បើកបរនៅពេលស្រវឹងដែលមានអត្រាជាតិអាកុលចាប់ពី ០,៤០ មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬ ចាប់ពី ០,៨ ក្រាមក្នុងមួយលីត្រឈាមឡើងទៅឬ ស្ថិតក្រោមឥទ្ធិពលគ្រឿងញៀន ឬ ប្រកែកមិនព្រមឱ្យគេធ្វើការពិនិត្យអត្រាជាតិអាកុល ឬ គ្រឿងញៀន ។

ខ-រត់គេចខ្លួននៅពេលបង្កឱ្យមានគ្រោះថ្នាក់ចរាចរណ៍ ។

គ-មិនព្រមគោរពតាមបញ្ជាឃាត់យានជំនិះ ឬ ប្រកែកមិនព្រមឱ្យត្រួតពិនិត្យយានជំនិះ ។

ឃ-ប្រើប្រាស់ផ្លាកលេខ ប័ណ្ណសម្គាល់យានជំនិះ ឬ លិខិតក្លែងក្លាយដើម្បីធ្វើចរាចរណ៍ ។

២-ប្រកាសប័ណ្ណបើកបរជាមោឃៈ ឬ ព្យួរទុកក្នុងរយៈពេលមិនលើស ២ ឆ្នាំ ដោយគិតទាំងការដកពិន្ទុ ដូចមានចែងក្នុងមាត្រា ៤៣ នៃច្បាប់នេះ :

ក-បើកបរមិនគោរពច្បាប់ចរាចរណ៍ ហើយបង្កឱ្យមនុស្សមានរបួសធ្ងន់ធ្ងរដោយអចេតនា ។

ខ-បើកបរមិនគោរពច្បាប់ចរាចរណ៍ ហើយបង្កឱ្យមនុស្សស្លាប់ដោយអចេតនា ។

ក្នុងករណីអ្នកបើកបរប្រព្រឹត្តបទល្មើស ដែលមានចែងក្នុងចំណុច ១ និង ២ ខាងលើនេះ ប្រធានអង្គភាពនគរបាលចរាចរណ៍ខេត្ត ក្រុង មានសិទ្ធិសម្រេចព្យួរប័ណ្ណបើកបរដែលមានរយៈពេលរហូតដល់ ១ ឆ្នាំដើម្បីរង់ចាំតុលាការវិនិច្ឆ័យ ។ នៅពេលតុលាការសម្រេចរឿងក្តីជាស្ថាពរួចហើយ សេចក្តីសម្រេចខាងលើត្រូវជំនួសដោយសេចក្តីសម្រេចរបស់សាលក្រម ឬសាលដីកា ។



51/63

**មាត្រា ៦៦ .-**

មន្ត្រីនគរបាលចរាចរណ៍ ត្រូវឃាត់យានជំនិះមិនឱ្យធ្វើចរាចរណ៍ ឬឃាំងទុកយានយន្ត រហូតពេលបង់ប្រាក់ពិន័យ ដើម្បីធ្វើការពិន័យទៅតាមករណីដែលអ្នកបើកបរ បានប្រព្រឹត្ត ល្មើសនឹងបទប្បញ្ញត្តិចរាចរណ៍ដូចខាងក្រោម :

១-យានជំនិះដែលអ្នកបើកបរកំពុងស្ថិតនៅក្នុងភាពស្រវឹង ដោយមានអត្រាជាតិ អាកុលចាប់ពី ០,២៥ មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬ ចាប់ពី ០,៥ ក្រាមក្នុងមួយលីត្រឈាម ឡើងទៅ ឬ ស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងញៀន ។

២-យានជំនិះដែលអ្នកបើកបរប្រកែកមិនព្រមឱ្យគេត្រួតពិនិត្យអត្រាជាតិអាកុល ឬ គ្រឿងញៀន ។

៣-យានជំនិះដែលផ្ទុកទំនិញ ឬមនុស្សហួសកម្រិតកំណត់ ។

៤-យានជំនិះដែលអ្នកបើកបរគ្មានប័ណ្ណបើកបរ ឬ មានប័ណ្ណបើកបរមិនត្រឹម ត្រូវតាមប្រភេទយានជំនិះ ។

៥-យានជំនិះដែលមានលក្ខណៈបច្ចេកទេសមិនគ្រប់គ្រាន់ អាចបង្កឱ្យមានគ្រោះ ថ្នាក់ចរាចរណ៍ ។

៦-យានជំនិះដែលបញ្ចេញផ្សែងខ្លាំង ឬ សំឡេងខ្លាំងលើសពីស្តង់ដារកំណត់ធ្វើ ឱ្យរំខានដល់អ្នកប្រើប្រាស់ផ្លូវផ្សេងទៀត ឬអ្នកដែលរស់នៅជាប់ផងផ្លូវផ្ទាល់ ។

៧-យានជំនិះដែលធ្វើចរាចរណ៍ ដោយគ្មានផ្លាកលេខ និងប័ណ្ណសម្គាល់យាន យន្ត ឬ លិខិតអនុញ្ញាតផ្សេងៗដើម្បីធ្វើចរាចរណ៍ ។

៨-យានជំនិះដែលផ្ទុកទំនិញ ឬ អ្នកដំណើរនាំឱ្យ បាំង ឬ ទើសទែងដល់អ្នកបើក បរ ។

៩-យានជំនិះដែលចតធ្វើឱ្យរំខាន ឬ នាំឱ្យមានគ្រោះថ្នាក់ដល់យានដទៃ ។

១០-យានជំនិះដែលចតចោលនៅលើថ្នល់ផ្លូវក្នុងទីប្រជុំជនលើសពី ៧២ ម៉ោង ។

១១-ក្នុងករណីយានយន្តមិនបានចូលត្រួតពិនិត្យលក្ខណៈបច្ចេកទេសតាមពេល កំណត់ ឬ មិនបានបង់សុពលយាន តាមពេលកំណត់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ៦៧ .-**

មន្ត្រីនគរបាលចរាចរណ៍ ត្រូវឃាត់យានជំនិះដែលបង្កគ្រោះថ្នាក់ចរាចរណ៍ទុក និង រៀបចំសំណុំរឿងបញ្ជូនទៅតុលាការដើម្បីធ្វើការវិនិច្ឆ័យ ចំពោះអ្នកបើកបរដែលបានប្រព្រឹត្ត បទល្មើសចរាចរណ៍ដូចខាងក្រោម :

១-យានជំនិះដែលពាក់ព័ន្ធនឹងគ្រោះថ្នាក់ចរាចរណ៍ ។

២-យានជំនិះដែលមានផ្លាកលេខ ឬ ប័ណ្ណសម្គាល់យានយន្ត ឬ លិខិតអនុញ្ញាតក្លែងក្លាយ ។

៣-យានជំនិះដែលផ្ទុកទំនិញ ឬ មនុស្សហួសកម្រិតកំណត់ទម្ងន់ ហើយធ្វើឱ្យខូចហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ ស្ពានជាក់ស្តែង ។

**មាត្រា ៦៨ .-**

សមត្ថកិច្ចរៀបចំបែបបទពិនិត្យអង្កេតកត់ត្រាបទល្មើស មានដូចខាងក្រោម :

១-បែបបទនៃការពិនិត្យអង្កេតកត់ត្រាបទល្មើស ការប្រើប្រាស់សៀវភៅមានគល់បញ្ជី និងការធ្វើកំណត់ហេតុគ្រោះថ្នាក់ចរាចរណ៍ និងបញ្ជូនលិខិត ឬសំណុំឯកសារទៅសមត្ថកិច្ចបន្ទាប់ ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ និងក្រសួងសាធារណការ និងដឹកជញ្ជូន ។

២-បែបបទនៃការបង់ប្រាក់ពិន័យ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យ និងការគ្រប់គ្រងប្រាក់ចំណូលបានមកពីការពិន័យ ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន ។

## ជំពូកទី ១០

## ទោសប្បញ្ញត្តិ

**មាត្រា ៦៩ .-**

អ្នកបើកបរអាចត្រូវទទួលខុសត្រូវទាំងផ្នែកព្រហ្មទណ្ឌ ទាំងផ្នែករដ្ឋប្បវេណីចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្តក្នុងការបើកបរយានជំនិះ ។

ការរំលោភលើរាងកាយ កិត្តិយស សេចក្តីថ្លៃថ្នូរ និងសមត្ថកិច្ចរបស់ភ្នាក់ងារនគរបាលចរាចរណ៍ ដែលកំពុងបំពេញភារកិច្ច ត្រូវទទួលទោសតាមច្បាប់ ។

**មាត្រា ៧០ .-**

កម្មសិទ្ធិករ ឬ អ្នកគ្រប់គ្រងយានជំនិះគ្រប់ប្រភេទ ត្រូវទទួលខុសត្រូវផ្នែករដ្ឋប្បវេណីក្នុងករណីមានគ្រោះថ្នាក់បណ្តាលឱ្យមានការខូចខាតដែលបង្កឡើងដោយយានជំនិះដែលខ្លួនមានជាកម្មសិទ្ធិ ឬ គ្រប់គ្រង ។

**មាត្រា ៧១ .-**

គ្រប់បទល្មើសចរាចរណ៍ត្រូវបញ្ជូនទៅតុលាការ លើកលែងតែបទល្មើសមានលក្ខណៈជាបទលហុ ដែលត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ ឬ ករណីដែលមានចែងក្នុងមាត្រា ៦៤ ឬ អំពើល្មើសដែលត្រូវទទួលការព្រមាន ។

**មាត្រា ៧២ .-**

មន្ត្រី ឬ ភ្នាក់ងារនគរបាលទទួលបន្ទុកសណ្តាប់ធ្នាប់ចរាចរណ៍ណា ដែលប្រើសិទ្ធិអំណាចដោយរំលោភក្នុងការដកហូតយកប័ណ្ណបើកបរ ផ្លាកលេខ ប័ណ្ណសម្គាល់យាន ឬ ឃាត់ទុកយានរបស់អ្នកបើកបរ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីប្រាំមួយ(៦)ថ្ងៃ ទៅ មួយ(១)ខែ ឬ/និងពិន័យជាប្រាក់ពីពីរម៉ឺនប្រាំពាន់(២៥.០០០)រៀល ទៅ ម្ភៃម៉ឺន (២០០.០០០)រៀល ។

ក្នុងករណីដែលមានការខូចខាត ឬ បាត់បង់ផ្នែកណាមួយនៃយាន បណ្តាលមកពីការឃាត់ទុក អង្គភាពសាមីត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតនោះ ។ ប្រសិនបើកម្រិតនៃការបំពានករណីយកិច្ចរបស់មន្ត្រី ឬ ភ្នាក់ងារទទួលបន្ទុកសណ្តាប់ធ្នាប់ចរាចរណ៍ក្នុងការបញ្ចៀសនូវលទ្ធផលមានភាពធ្ងន់ធ្ងរ នោះអង្គភាពអាចទាមទារសំណងពីមន្ត្រី ឬ ភ្នាក់ងារនោះបាន ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី មួយ (១)ឆ្នាំ ទៅ បី(៣)ឆ្នាំ ឬ/និងពិន័យជាប្រាក់ពីពីរលាន(២.០០០.០០០)រៀល ទៅប្រាំមួយលាន(៦.០០០.០០០)រៀល ចំពោះមន្ត្រី ឬ ភ្នាក់ងារទទួលបន្ទុកសណ្តាប់ធ្នាប់ចរាចរណ៍ណាដែល :

-បង្ខំទារប្រាក់ពិន័យមិនត្រឹមត្រូវតាមច្បាប់កំណត់

-ទទួលប្រាក់ដោយការប្រើប្រាស់ក្បាលសៀវភៅសម្រាប់ពិន័យ ដែលមានគល់បញ្ជីមិនត្រឹមត្រូវ ឬដោយមិនចេញបង្កាន់ដៃប្រាក់ពិន័យឱ្យអ្នកបើកបរដែលត្រូវពិន័យ ។

-ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី មួយ(១)ឆ្នាំ ទៅបី(៣)ឆ្នាំ ឬ/និងពិន័យជាប្រាក់ពីពីរលាន (២.០០០.០០០)រៀល ទៅប្រាំមួយលាន (៦.០០០.០០០)រៀល ចំពោះមន្ត្រីរាជការ ឬ បុគ្គលិកដែលធ្វើការងារផ្ទាល់ ឬមានសមត្ថកិច្ច ឬមានភារកិច្ច ដែលធ្វើការងារក្នុងការគ្រប់គ្រងសាលាបើកបរ ឬ ការងារចេញប័ណ្ណបើកបរ ឬ ការងារចុះបញ្ជីការចេញប័ណ្ណសម្គាល់យានយន្ត ហើយដែលបានប្រព្រឹត្តផ្ទុយនឹងមាត្រា ៤០ ឬ មាត្រា ៤៨ នៃច្បាប់នេះ ។

**មាត្រា ៧៣ .-**

ក្នុងករណីប័ណ្ណបើកបរត្រូវរឹបអូសទុក ឬ ទុកជាមោឃៈ ហើយសាមីខ្លួនមិនព្រមប្រគល់ប័ណ្ណបើកបរតាមពេលកំណត់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ(១)ថ្ងៃ ទៅ ប្រាំ(៥)ថ្ងៃ ឬ/និងពិន័យជាប្រាក់ពីប្រាំពាន់(៥.០០០)រៀល ទៅពីរម៉ឺនប្រាំពាន់(២៥.០០០)រៀល ។

**មាត្រា ៧៤ .–**

ជនណាបើកបរយានដោយគ្មានប័ណ្ណបើកបរ ឬ ក្នុងរយៈពេលដែលប័ណ្ណបើកបរត្រូវបានដកហូតឬរក្សាទុក ឬ ទុកជាមោឃៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីប្រាំមួយ(៦)ថ្ងៃ ទៅមួយ(១) ខែ ឬ/និងពិន័យជាប្រាក់ពីពីរម៉ឺនប្រាំពាន់(២៥.០០០)រៀល ទៅម្ភៃម៉ឺន(២០០.០០០)រៀល ។

**មាត្រា ៧៥ .–**

ជនណារារាំងដល់ការឃាត់យានជំនិះ ឬ មិនព្រមបញ្ឈប់យានជំនិះតាមការបញ្ជារបស់នគរបាលមានសមត្ថកិច្ច ឬប្រកែកមិនព្រមឱ្យធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់យាន ឬប្រកែកមិនព្រមដាក់ខ្លួនឱ្យធ្វើតេស្តពិនិត្យជាតិអាកុល ឬគ្រឿងញៀន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីប្រាំមួយ (៦)ថ្ងៃ ទៅមួយ(១)ខែ ឬ/និងពិន័យជាប្រាក់ពីពីរម៉ឺនប្រាំពាន់(២៥.០០០)រៀល ទៅម្ភៃម៉ឺន (២០០.០០០)រៀល ។

**មាត្រា ៧៦ .–**

ជនណាបើកបរយានជំនិះនៅពេលដែលខ្លួនស្ថិតនៅក្នុងភាពស្រវឹងដោយមានជាតិអាកុលចាប់ពី ០,៤០ មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី ០,៨ ក្រាមក្នុងមួយលីត្រឈាមឡើងទៅត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីប្រាំមួយ(៦)ថ្ងៃ ទៅប្រាំមួយ(៦)ខែ ឬ/និងពិន័យជាប្រាក់ពីពីរម៉ឺនប្រាំពាន់(២៥.០០០)រៀល ទៅមួយលាន(១.០០០.០០០)រៀល ។

**មាត្រា ៧៧ .–**

ជនណាបានប្រើប្រាស់ប័ណ្ណបើកបរ ប័ណ្ណសម្គាល់យាន ផ្លាកលេខសម្គាល់យាន ឬ លិខិតអនុញ្ញាតផ្សេងៗដោយដឹងថាជាវត្ថុក្លែងក្លាយ និងជនក្លែងប័ណ្ណបើកបរ ប័ណ្ណសម្គាល់យាន ឬ លិខិតអនុញ្ញាតផ្សេងៗ ដើម្បីចរាចរយាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីពីរ (២)ឆ្នាំ ទៅប្រាំ(៥)ឆ្នាំ ឬ/និងផ្តន្ទាទោសពិន័យជាប្រាក់ពីបួនលាន (៤.០០០.០០០)រៀល ទៅដប់លាន (១០.០០០.០០០)រៀល ។

**មាត្រា ៧៨ .–**

ជនណាបានប្រើប្រាស់មធ្យោបាយណាមួយ ដើម្បីជាឧបសគ្គដល់ចរាចរណ៍សាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ(១)ខែ ទៅមួយ(១)ឆ្នាំ ឬ/និងផ្តន្ទាទោសពិន័យជាប្រាក់ពីម្ភៃម៉ឺន(២០០.០០០)រៀល ទៅពីរលាន(២.០០០.០០០)រៀល ។

**មាត្រា ៧៩ .–**

ជនណាប្រើប្រាស់យានជំនិះដោយគ្មានប័ណ្ណសម្គាល់យាន និងគ្មានផ្លាកលេខសម្គាល់យាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីប្រាំមួយ(៦)ថ្ងៃ ទៅមួយ(១)ខែ ឬ/និងផ្តន្ទាទោសពិន័យជាប្រាក់ពីពីរម៉ឺនប្រាំពាន់(២៥.០០០)រៀល ទៅម្ភៃម៉ឺន (២០០.០០០)រៀល ។

**មាត្រា ៨០ .–**

ជនណាបើកបរបង្កឱ្យមានរបួសដល់អ្នកដទៃដោយអចេតនា ហើយដែលបណ្តាលឱ្យមានអសមត្ថភាពធ្វើការងារស្មើ ឬ លើសពីប្រាំបី(៨) ថ្ងៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីប្រាំមួយ (៦)ថ្ងៃ ទៅមួយ(១)ឆ្នាំ ឬ/និងផ្តន្ទាទោសពិន័យជាប្រាក់ពីពីរម៉ឺនប្រាំពាន់(២៥.០០០)រៀល ទៅពីរលាន(២.០០០.០០០)រៀល ។

ត្រូវផ្តន្ទាទោសដល់កម្រិតអតិបរមាក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយក្នុងចំណោមស្ថានភាពដូចខាងក្រោម:

ក-បើកបរដោយគ្មានប័ណ្ណបើកបរ ឬមានប័ណ្ណបើកបរ តែមិនត្រឹមត្រូវតាមការកំណត់ ។

ខ-ស្ថិតក្នុងស្ថានភាពស្រវឹង ដោយមានអត្រាជាតិអាកុលចាប់ពី ០,៤០ មីលីក្រាម ក្នុងមួយលីត្រខ្យល់ ឬចាប់ពី ០,៨០ក្រាម ក្នុងមួយលីត្រឈាមឡើងទៅ ។

គ-បណ្តាលឱ្យមានរបួសមនុស្សច្រើននាក់ ។

ឃ-រត់គេចខ្លួនពីកន្លែងកើតហេតុក្នុងគោលបំណងគេចវេសពីការទទួលខុសត្រូវ ។

**មាត្រា ៨១ .–**

ជនណាបើកបរដែលបង្កឱ្យមានរបួសដល់អ្នកដទៃ បណ្តាលឱ្យពិការអចិន្ត្រៃយ៍ដោយអចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ(១) ឆ្នាំ ទៅបី(៣)ឆ្នាំ ឬ/និងផ្តន្ទាទោសពិន័យជាប្រាក់ពី ពីរលាន(២.០០០.០០០)រៀល ទៅប្រាំមួយលាន(៦.០០០.០០០)រៀល ។

ត្រូវផ្តន្ទាទោសដល់កម្រិតអតិបរមា ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយក្នុងចំណោមស្ថានភាពដូចខាងក្រោម:

ក-បើកបរដោយគ្មានប័ណ្ណបើកបរ ឬមានប័ណ្ណបើកបរ តែមិនត្រឹមត្រូវតាមការកំណត់ ។

ខ-ស្ថិតក្នុងស្ថានភាពស្រវឹង ដោយមានអត្រាជាតិអាកុលចាប់ពី ០,៤០ មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី ០,៨០ ក្រាមក្នុងមួយលីត្រឈាមឡើងទៅ ។

គ-បណ្ដាលឱ្យមានរបួសមនុស្សច្រើននាក់ ។

ឃ-រត់គេចខ្លួនពីកន្លែងកើតហេតុក្នុងគោលបំណងគេចវេសពីការទទួលខុសត្រូវ ។

**មាត្រា ៨២ .-**

ជនណាបើកបរដោយបង្កឱ្យស្លាប់ដល់អ្នកដទៃដោយអចេតនា ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពីមួយ(១)ឆ្នាំ ទៅបី(៣)ឆ្នាំ ឬ/និងផ្ដន្ទាទោសពិន័យជាប្រាក់ពីពីរលាន (២.០០០.០០០) រៀល ទៅប្រាំមួយលាន(៦.០០០.០០០)រៀល ។

ត្រូវផ្ដន្ទាទោសដល់កម្រិតអតិបរមា ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយក្នុងចំណោមស្ថានភាពដូចខាងក្រោម :

ក-បើកបរដោយគ្មានប័ណ្ណបើកបរ ឬ មានប័ណ្ណបើកបរ តែមិនត្រឹមត្រូវតាមការកំណត់ ។

ខ-ស្ថិតក្នុងស្ថានភាពស្រវឹង ដោយមានអត្រាជាតិអាកុលចាប់ពី ០,៤០ មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី ០,៨០ក្រាម ក្នុងមួយលីត្រឈាមឡើងទៅ ។

គ-បណ្ដាលឱ្យមានរបួសមនុស្សច្រើននាក់ ។

ឃ-រត់គេចខ្លួនពីកន្លែងកើតហេតុក្នុងគោលបំណងគេចវេសពីការទទួលខុសត្រូវ ។

**មាត្រា ៨៣ .-**

ជនណាបើកបរដែលបានបង្កឱ្យអ្នកដទៃមានរបួស ពិការ ឬ ស្លាប់ដោយចេតនា ត្រូវផ្ដន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៨៤ .-**

ការផ្ទុកទម្ងន់អតិបរមានៃភ្លៅ និងទម្ងន់សរុបអតិបរមាយានយន្តដឹកជញ្ជូនដែលលើសកម្រិតកំណត់ ត្រូវទទួលទណ្ឌកម្មដូចខាងក្រោម :

១-មិនលើស ៥ ％ ត្រូវធ្វើការព្រមានជាលាយលក្ខណ៍អក្សរ ដោយមិនពិន័យ ។

២-លើសពី ៥ ％ ទៅ ១០ ％ ត្រូវ :

ក-ពិន័យជាប្រាក់ចំនួនដប់ម៉ឺន (១០០.០០០)រៀល ក្នុងមួយតោន ។



57/63

ខ-ពីទំនិញចេញ និងឃាត់យានជំនិះចំនួនដប់(១០)ថ្ងៃ ។

គ-ដកប័ណ្ណបើកបរ ព្យួរទុកចំនួនដប់(១០)ថ្ងៃ ។

៣-លើសពី ១០ % ទៅ ២០ % ត្រូវ :

ក-ពិន័យជាប្រាក់ចំនួនម្ភៃម៉ឺន(២០០.០០០)រៀល ក្នុងមួយតោន ។

ខ-ពីទំនិញចេញ និងឃាត់យានជំនិះចំនួនមួយ(១)ខែ ។

គ-ដកប័ណ្ណបើកបរព្យួរទុកចំនួនប្រាំមួយ(៦)ខែ ។

៤-លើសពី ២០ % ត្រូវ :

ក-ពិន័យជាប្រាក់ចំនួនសាមសិបម៉ឺន(៣០០.០០០)រៀល ក្នុងមួយតោន ។

ខ-ពីទំនិញចេញ និងឃាត់យានជំនិះចំនួនមួយ(១)ឆ្នាំ ។

គ-ដកប័ណ្ណបើកបរព្យួរទុកចំនួនពីរ(២)ឆ្នាំ ។

ក្នុងករណីមានអំពើល្មើសលើការផ្ទុកទម្ងន់សរុប ថែមទាំងអំពើល្មើសលើការផ្ទុកទម្ងន់អតិបរមានៃភ្លៅនោះ ត្រូវធ្វើការផាកពិន័យទាំងពីរករណី ។

ក្នុងករណីមិនរាងចាល ការពិន័យត្រូវទ្វេគុណ និងបញ្ឈប់អាជីវកម្មដឹកជញ្ជូនរបស់ក្រុមហ៊ុនចំនួនមួយ(១)ឆ្នាំ ។ ម្ចាស់យានយន្តត្រូវទទួលខុសត្រូវលើការលើកដាក់ទំនិញនិងបង់ថ្លៃឈ្នួលកន្លែងទុកដាក់ថែទាំទំនិញ និងយានជំនិះរបស់ខ្លួន ។

ទណ្ឌកម្មខាងលើមិនមែនជាឧបសគ្គដល់ការដាក់ទណ្ឌកម្មឱ្យសងការខូចខាត ដែលត្រូវសម្រេចដោយតុលាការឡើយ នៅក្នុងករណីដែលមានការខូចខាតហេដ្ឋារចនាសម្ព័ន្ធជាក់ស្តែងបណ្តាលមកពីការផ្ទុកលើសទម្ងន់កំរិតកំណត់ ។

**មាត្រា ៨៥ .-**

ជនជាអាណាព្យាបាលបណ្តោយឱ្យក្មេងមានអាយុតិចជាង ៦ឆ្នាំ ដើររហេតរហូតលើផ្លូវថ្នល់ បណ្តាលឱ្យមានគ្រោះថ្នាក់ចរាចរណ៍ ត្រូវទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ។

**មាត្រា ៨៦ .-**

ជនលែងសត្វដែលខ្លួនចិញ្ចឹម ឱ្យដើររហេតរហូតលើផ្លូវថ្នល់ បណ្តាលឱ្យមានគ្រោះថ្នាក់ចរាចរណ៍ ត្រូវទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ។

**មាត្រា ៨៧ .-**

មន្ត្រីរាជការដែលមិនបានអនុវត្តតាមមាត្រា ៤៧ នៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មតាមច្បាប់រដ្ឋបាល ។

**មាត្រា ៨៨ .-**

បទលហុមាន ៤ ថ្នាក់ គិតតាមចំនួនទឹកប្រាក់ពិន័យអន្តរការណ៍ ដោយគិតទាំងការដកពិន្ទុ ដូចមានចែងក្នុងមាត្រា ៨៣ នៃច្បាប់នេះ តាមកម្រិតដូចខាងក្រោម :

១-បទលហុថ្នាក់លេខ ១ :

ក-បើកបរដោយប្រើសញ្ញាសូរស័ព្ទ មិនត្រឹមត្រូវតាមបទប្បញ្ញត្តិ ។

ខ-បើកបរដោយមិនពាក់ខ្សែក្រវាត់ការពារ ឬ មួកការពារសុវត្ថិភាព ។

គ-បើកបរដាក់ក្មេងអាយុតិចជាង ១០ ឆ្នាំជិះនៅកៅអីខាងមុខរថយន្តដោយគ្មានមនុស្សចាស់ការពារ ឬ និងដោយគ្មានពាក់ខ្សែក្រវាត់សុវត្ថិភាព ។

ឃ-អំពើល្មើសនឹងចំណុចទី ៧ និងចំណុចទី ៨ នៃមាត្រា ៩ ។

ង-ឈប់ ឬ ចតដោយរំលោភ ឬ រំខាន ។

ច-បើកបរដោយកុងទ័រល្បឿនមិនដំណើរការ ។

ឆ-បើកបរហួសល្បឿនកំណត់ ចាប់ពី ១ទៅ ១៩ គីឡូម៉ែត្រក្នុងមួយម៉ោង ។

ជ-ប្រើប្រាស់ទូរស័ព្ទគ្មានឧបករណ៍ភ្ជាប់ទំនាក់ទំនងនៅពេលកំពុងបើកបរ ។

ឈ-អំពើល្មើសនឹងមាត្រា ១៥ ។

បទល្មើសខាងលើនេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់តាមប្រភេទយានយន្ត ដូចខាងក្រោម :

-ទោចក្រ ឬ ត្រីចក្រយានយន្តចំនួនប្រាក់បីពាន់(៣.០០០)រៀល

-យានយន្តធុនស្រាលចំនួនប្រាក់ប្រាំពាន់(៥.០០០)រៀល

-យានយន្តធុនធ្ងន់ចំនួនប្រាក់មួយម៉ឺន(១០.០០០)រៀល ។

២-បទលហុថ្នាក់លេខ ២ :

ក-ការផ្ទុកទំនិញ ដែលមានប្រវែងទទឹង បណ្តោយ ឬ កម្ពស់ខុសបទប្បញ្ញត្តិច្បាប់នេះ ។

ខ-ការផ្ទុកទំនិញមិនត្រឹមត្រូវ តាមលក្ខណៈបច្ចេកទេស ។

គ-អំពើល្មើសទាក់ទងការរៀបចំដាក់តាំងភ្លើង និងភ្លើងសញ្ញានៃយានជំនិះមិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ។

ឃ-អំពើល្មើសទាក់ទងនឹងម៉ាស៊ីនដែលបញ្ចេញសម្លេងខ្លាំង ឬផ្សែងច្រើន ។

ង-អំពើល្មើសទាក់ទងនឹងការរៀបចំតាក់តែងបរិធានបើកបរ ។

ច-បើកបរហួសល្បឿនកំណត់ចាប់ពី ២០ ទៅ ២៩ គីឡូម៉ែត្រក្នុងមួយម៉ោង ។

បទល្មើសខាងលើនេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់តាមប្រភេទយានយន្ត ដូចខាងក្រោម :

-ទោចក្រយានយន្ត ឬ ត្រីចក្រយានយន្តចំនួនប្រាក់បួនពាន់(៤.០០០)រៀល

-យានយន្តធុនស្រាលចំនួនប្រាក់ប្រាំបីពាន់(៨.០០០)រៀល

-យានយន្តធុនធ្ងន់ចំនួនប្រាក់មួយម៉ឺនប្រាំពាន់(១៥.០០០)រៀល ។

៣-បទលហុថ្នាក់លេខ ៣ :

ក-បើកបរខុសទិសដែលតម្រូវឱ្យធ្វើចរាចរណ៍ ឬបើកបរជាន់គំនូសបង្អួតកណ្តាលទ្រូងផ្លូវ ។

ខ-បើកបរហួសល្បឿនកំណត់ចាប់ពី ៣០ ទៅ ៣៩ គីឡូម៉ែត្រក្នុងមួយម៉ោង ។

គ-អំពើល្មើសទាក់ទងនឹងការជៀស និងការជែង ។

ឃ-អំពើល្មើសទាក់ទងនឹងអាទិភាពនៅផ្លូវប្រសព្វ ។

ង-អំពើល្មើសទាក់ទងនឹងការប្រើប្រាស់ភ្លើង និងភ្លើងសញ្ញានៃយានជំនិះ ។

ច-បើកបរមិនគោរពភ្លើងសញ្ញាចរាចរណ៍ពណ៌ក្រហម ឬ ក្រហមភ្លឹបភ្លែតៗ ។

ឆ-បើកបរមិនគោរពផ្លាកសញ្ញាហាមឃាត់ ។

ជ-មិនរាងចាលដោយប្រព្រឹត្តដដែលនូវអំពើល្មើសស្តីពីការឈប់ ឬ ចត ។

ឈ-ប្រើប្រាស់សម្បកកង់មិនត្រឹមត្រូវ តាមបទប្បញ្ញត្តិច្បាប់ ។

ញ-បើកបរដោយពុំមានលិខិតត្រួតពិនិត្យលក្ខណៈបច្ចេកទេសយាន ។

ដ-បើកបរដោយពុំមានលិខិតអនុញ្ញាតធ្វើអាជីវកម្ម ។

ឋ-មិនគោរពសញ្ញាបញ្ជាចរាចរណ៍ របស់ភ្នាក់ងារនគរបាលចរាចរណ៍ ។

បទល្មើសខាងលើនេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់តាមប្រភេទយានយន្ត ដូចខាងក្រោម :

-ទោចក្រយានយន្ត ឬត្រីចក្រយានយន្តចំនួនប្រាក់ប្រាំពាន់(៥.០០០)រៀល

-យានយន្តធុនស្រាលចំនួនប្រាក់មួយម៉ឺន(១០.០០០)រៀល

-យានយន្តធុនធ្ងន់ចំនួនប្រាក់ពីរម៉ឺន(២០.០០០)រៀល ។

៤-បទលហុផ្ទាក់លេខ ៤ :

ក-បើកបរដោយប្រើប្រាស់ប័ណ្ណបើកបរ មិនត្រឹមត្រូវតាមប្រភេទយានជំនិះ ។

ខ-បើកបរយានដែលមានកង់ច្រវាក់ដែកផ្ទាល់នៅលើថ្នល់ផ្លូវថ្នល់ក្រាលកៅស៊ូ ។

គ-បើកបរហួសល្បឿនកំណត់ចាប់ពី ៤០គីឡូម៉ែត្រក្នុងមួយម៉ោងឡើងទៅ ។

ឃ-ប្រើប្រាស់ផ្លាកលេខសម្គាល់យានដែលរចនាខុសពីលក្ខណៈដើម ឬ វលុបលេខ ឬបាក់ផ្លាកបាត់លេខ ។

ង-បើកបរដោយប្រើប័ណ្ណបើកបរហួសសុពលភាព ។

ច-បើកបរមិនគោរពតាមលក្ខខណ្ឌសុខភាពដែលតម្រូវឱ្យពាក់វ៉ែនតា ។

ឆ-បើកបរដោយមានអត្រាជាតិអាកុលចាប់ពី០,២៥ ទៅ ០,៣៩ មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី ០,៥ ទៅ ០,៧៩ក្រាម ក្នុងមួយលីត្រឈាម ។

ជ-ការបត់ឆ្វេង ឬ ស្តាំ មិនត្រឹមត្រូវតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

ឈ-ឱ្យមនុស្សជិះលើយាន ឬរ៉ឺម៉កដែលកំពុងសណ្តោង ក្រៅពីអ្នកបើកបរ ។

ញ-ផ្ទុកមនុស្សលើសចំនួនកំណត់

ដ-រៀបចំ ចាត់ចែង ឬប្រណាំងយានដោយគ្មានការអនុញ្ញាតលើផ្លូវសម្រាប់ធ្វើចរាចរណ៍ជាសាធារណៈ ។

បទល្មើសខាងលើនេះ ត្រូវពិន័យជាប្រាក់តាមប្រភេទយានយន្ត ដូចខាងក្រោម :

-ទោចក្រយានយន្ត ឬ ត្រីចក្រយានយន្តចំនួនប្រាក់ប្រាំមួយពាន់(៦.០០០) រៀល

-យានយន្តធុនស្រាលចំនួនប្រាក់មួយម៉ឺនពីរពាន់(១២.០០០)រៀល

-យានយន្តធុនធ្ងន់ចំនួនប្រាក់ពីរម៉ឺនប្រាំពាន់(២៥.០០០)រៀល ។

ក្នុងករណីដែលជនល្មើសមិនបានបង់ប្រាក់ពិន័យក្នុងរយៈពេល ៣០ ថ្ងៃ គិតពីថ្ងៃដែលបានទទួលប័ណ្ណពិន័យចំនួនទឹកប្រាក់ពិន័យនេះនឹងត្រូវតម្លើងជាពីរដងបើលើសពី ៦០ថ្ងៃ ចំនួននៃប្រាក់ពិន័យនឹងត្រូវតម្លើងជាបីដង ។ បើផុតរយៈពេល ៩០ថ្ងៃ មន្ត្រីនគរបាលចរាចរណ៍ត្រូវរៀបចំសំណុំឯកសារបញ្ជូនទៅតុលាការ ។

**មាត្រា ៨៩ .-**

រាល់អំពើល្មើសនឹងបទប្បញ្ញត្តិចរាចរណ៍ ដែលពុំមានចែងក្នុងមាត្រា ៨៨ ខាងលើនឹងត្រូវធ្វើការព្រមាន ។

**មាត្រា ៩០ .-**

ចំពោះទោសដែលជាពិន័យអន្តរការណ៍ អាចអនុញ្ញាតឱ្យអ្នកប្រព្រឹត្តល្មើសជៀសផុតពីបណ្តឹងអាជ្ញាបាន ។

## ជំពូកទី ១១
## អន្តរប្បញ្ញត្តិ

**មាត្រា ៩១ .-**

យានយន្តជាកម្មសិទ្ធិរបស់ឯកជនដែលបានពាក់ផ្លាកលេខរដ្ឋ នគរបាល និង ខេមរភូមិន្ទ ត្រូវធ្វើបែបបទសុំប្តូរពីផ្លាកលេខរដ្ឋ នគរបាល និង ខេមរភូមិន្ទ មកផ្លាកលេខឯកជនឱ្យបានចប់សព្វគ្រប់ក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីថ្ងៃដែលច្បាប់នេះចូលជាធរមាន ។

**មាត្រា ៩២ .-**

ជំពូកទី ១០ ស្តីពីទោសប្បញ្ញត្តិ ត្រូវចាប់អនុវត្តប្រាំមួយ(៦)ខែ ក្រោយពេលច្បាប់នេះចូលជាធរមាន លើកលែងតែបទប្បញ្ញត្តិដែលមានចែងក្នុងមាត្រា ៧៧ មាត្រា ៧៩ និង មាត្រា ៨៤ នៃច្បាប់នេះ ។

**មាត្រា ៩៣ .-**

បទប្បញ្ញត្តិដែលមានចែងក្នុងចំណុចទី ៧ និងទី ៨ នៃមាត្រា ៩ ជំពូកទី ៣ នៃច្បាប់នេះ ត្រូវចាប់អនុវត្តប្រាំ(៥)ឆ្នាំ ក្រោយពេលច្បាប់នេះចូលជាធរមាន ។

**មាត្រា ៩៤ .-**

បទប្បញ្ញត្តិដែលមានចែងក្នុងមាត្រា ៤៣ និងមាត្រា ៤៤ ជំពូកទី ៧ នៃច្បាប់នេះ ត្រូវចាប់អនុវត្តប្រាំ(៥)ឆ្នាំ ក្រោយពេលច្បាប់នេះចូលជាធរមាន ។

## ជំពូកទី ១២
## អវសានប្បញ្ញត្តិ

**មាត្រា ៩៥ .-**

ក្រឹត្យលេខ ៦៨ ក្រ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស.រកម.០២០៧.០៦១

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

**ហត្ថលេខា**

**ស៊ុន ចាន់ថុល**

លេខៈ ៧០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញៈ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

**ឃុន ឋិនកេន**